ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

# គោលការណ៍ណែនាំស្តីពី ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត គោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍



រៀបរៀងដោយនាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ
នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**លេខាធិការដ្ឋាន ក.ជ.វ.ប.ន.**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

គេហទំព័រ៖ https://www.misti.gov.kh

ការបោះពុម្ពជាសៀវភៅអេឡិចត្រូនិកលើកទី១៖ ២០២៣
លេខចុះបញ្ជីរបស់បណ្ណាល័យជាតិ
ISBN: 978-9924-6000-6-0 (ភាសាខ្មែរ)

ISBN 978-9924-600-06-0

© ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២៣

គោលការណ៍ណែនាំស្ដីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត គោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នេះ ជាកម្មសិទ្ធិរបស់អ្នកនិពន្ធ និងរក្សាសិទ្ធិគ្រប់យ៉ាងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ គ្មានផ្នែកណាមួយនៃគោលការណ៍ណែនាំនេះអាចត្រូវបានផលិតឡើងវិញ ចែកចាយ ឬបញ្ជូនតាមទម្រង់ ឬមធ្យោបាយណាមួយ ឬរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យ ឬប្រព័ន្ធដែលអាចទាញយកបានដោយគ្មានការអនុញ្ញាតជា

លាយលក្ខណ៍អក្សរជាមុនពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ។ អ្នកបោះពុម្ពផ្សាយ អ្នករៀបរៀង និងនិពន្ធនាយកសន្មតថា អនុសាសន៍ និងព័ត៌មាននៅក្នុងគោលការណ៍ណែនាំនេះ មានភាពជាក់លាក់ និងត្រឹមត្រូវនៅថ្ងៃនៃការបោះពុម្ពផ្សាយ។ ទាំងអ្នកបោះពុម្ពផ្សាយ អ្នករៀបរៀង ឬនិពន្ធនាយកពុំជានានូវការបង្ហាញ ឬការបញ្ជាក់ទាក់ទងនឹងព័ត៌មាន និងទិន្នន័យយោងដែលមាននៅក្នុងគោលការណ៍ណែនាំនេះ ឬកំហុសឆ្គង ឬការលុបណាមួយដែលអាចកើតឡើងដោយប្រការណាមួយនោះទេ។

អាសយដ្ឋានរបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ អគារលេខ ១១៥៧ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ អគារលេខ ៤៥ មហាវិថី ព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ១២០២០៣ ព្រះរាជាណាចក្រកម្ពុជា

# **អារម្ភកថា**

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកការអភិវឌ្ឍវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**វ.ប.ន.**) ជាអាទិភាពសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ឈានឆ្ពោះទៅសម្រេចមហិច្ឆតាក្នុងការប្រែខ្លួនទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីឈានទៅសម្រេចវត្ថុបំណងនេះ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ជ.វ.ប.ន.**) ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ក្នុងគោលបំណងជំរុញកិច្ចអភិវឌ្ឍ **វ.ប.ន.** ឱ្យកាន់តែរីកចម្រើន ដោយមានអគ្គនាយកដ្ឋាន **វ.ប.ន.** នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ឧ.វ.ប.ន.**) ជាលេខាធិការដ្ឋាន។

នៅឆ្នាំ ២០២០ ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ ក្រសួង **ឧ.វ.ប.ន.** បានកសាងឡើងនូវ «ផែនទីបង្ហាញផ្លូវ **វ.ប.ន.** កម្ពុជា ២០៣០» ដែលជាឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពី **វ.ប.ន.** ឆ្នាំ២០២០-២០៣០។ ជាមួយគ្នានេះផងដែរ គោលការណ៍ណែនាំស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ **វ.ប.ន.** ត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ដែលជាតួអង្គជំនាញស្ថិតក្រោមឱវាទ អគ្គនាយកដ្ឋាន **វ.ប.ន.**។ គោលការណ៍ណែនាំនេះ បានឆ្លងកាត់ការប្រជុំត្រួតពិនិត្យកម្រិតអគ្គនាយកដ្ឋាន ព្រមទាំង ទទួលបានធាតុចូលពីក្រសួងស្ថាប័នពាក់ព័ន្ធតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ផងដែរ។ គោលការណ៍ណែនាំនេះ ជាឯកសារគោលមួយដើម្បីជាជំនួយក្នុងការគាំទ្រ លើកកម្ពស់ បង្កើនប្រសិទ្ធភាព និងជាជំនួយក្នុងការកសាងឯកសារផ្សេងៗដែលទាក់ទងនឹងការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ **វ.ប.ន.** យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ គម្រោងផ្សេងៗ ក្នុងគោលបំណងជំរុញការអភិវឌ្ឍវិស័យ **វ.ប.ន.** ជាតិ ដែលជាចំណែកមួយក្នុងការឈានទៅសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០ និង២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជា។ ខ្ញុំសង្ឃឹម យ៉ាងមុតមាំថា គោលការណ៍ណែនាំនេះនឹងផ្តល់ជាប្រយោជន៍ដល់តួអង្គពាក់ព័ន្ធទាំងអស់សម្រាប់សិក្សា រៀនសូត្រ ស្វែងយល់បន្ថែមពីយន្តការ និងសារៈសំខាន់នៃការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីរួមគ្នាជំរុញការអភិវឌ្ឍវិស័យ **វ.ប.ន.** នៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារលេខាធិការដ្ឋាននៃ **ក.ជ.វ.ប.ន.** ជាពិសេស ក្រុមអ្នករៀបរៀង និងក្រុមនិពន្ធនាយកដែលបានចងក្រងឯកសារគោលការណ៍ណែនាំដ៏មានសារៈសំខាន់នេះឡើង។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**
**និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

| **អ្នករៀបរៀង** | |
|---|---|
| ឯកឧត្តមបណ្ឌិត **ហ៊ុល សៀងហេង** | ប្រធាន |
| លោកបណ្ឌិត **ជាតិ សុផល** | អនុប្រធាន |
| លោក **លឹម យ៉ុងហួត** | សមាជិក |
| លោក **ខៀវ ធី** | សមាជិក |
| កញ្ញា **ឈុំ មួយនី** | សមាជិក |
| លោក **សឿ ជំនិត** | សមាជិក |
| លោក **ថូ ចន្ទតារារិទ្ធ** | សមាជិក |
| លោក **ថៃ ហាក់** | សមាជិក |
| លោក **តួង សុដានីត** | សមាជិក |
| លោកស្រី **ម៉េង សោភ័ណ្ឌ** | សមាជិក |
| លោក **ខឹម ដាវីត** | សមាជិក |
| លោក **អ៊ុង ពុទ្ធានី** | សមាជិក |

| **ក្រុមនិពន្ធនាយក** | |
|---|---|
| លោកបណ្ឌិត **ជាតិ សុផល** | ប្រធាននិពន្ធនាយក |
| លោក **សឿ ជំនិត** | អនុប្រធាននិពន្ធនាយក |
| លោក **ថូ ចន្ទតារារិទ្ធ** | និពន្ធនាយក |

**បោះពុម្ពផ្សាយ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

## មាតិកា


*បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ* .......... *xi*

*ខ្លឹមសារសង្ខេបប្រតិបត្តិ* .......... *xii*

*ជំពូកទី១៖ សេចក្តីផ្តើម* .......... ១

១.១. សាវតារ .......... ១

១.២. សារៈប្រយោជន៍នៃ ត.ត.វ. .......... ២

១.៣. ខ្លឹមសារទូទៅនៃ ត.ត.វ. .......... ៤

*១.៣.១. ការតាមដាន និងត្រួតពិនិត្យ* .......... ៤

*១.៣.២. ការវាយតម្លៃ* .......... ៥

១.៤. ភាពខុសគ្នា និងដូចគ្នារវាង ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ... ៧

១.៥. មូលដ្ឋាននៃ ត.ត.វ .......... ១០

១.៦. វំហូរនៃការផ្សព្វផ្សាយសេចក្តីណែនាំ និងការសម្របសម្រួលព័ត៌មាន .. ១១

*ជំពូកទី២៖ គោលការណ៍ណែនាំស្តីពីការបង្កើតប្រព័ន្ធ ត.ត.វ. ការអនុវត្ត គោលនយោបាយ វ.ប.ន.* .......... ១៣

២.១. សេចក្តីផ្តើមនៃប្រព័ន្ធ ត.ត.វ. នៃការអនុវត្ត គោលនយោបាយ វ.ប.ន. ១៣

២.២. គោលការណ៍ទូទៅក្នុងការបង្កើតប្រព័ន្ធ ត.ត.វ. នៃការអនុវត្ត គោលនយោបាយ វ.ប.ន. .......... ១៤

*២.២.១. តម្លៃបន្ថែម* .......... ១៤

*២.២.២. ការតាំងចិត្ត ឬប្តេជ្ញាចិត្ត ដើម្បីបង្ហាញនូវលទ្ធផល* .......... ១៤

*២.២.៣. ពង្រឹងការសម្រេចចិត្ត និងគណនេយ្យភាព* .......... ១៤

*២.២.៤. ប្រសិទ្ធភាពចំណាយ* .......... ១៥

*២.២.៥. ការភ្ជាប់គ្នាគ្រប់កម្រិតផែនការ ..................................................១៥*

*២.២.៦. ការផ្សារភ្ជាប់គ្រប់តួអង្គពាក់ព័ន្ធ ................................................១៥*

*២.២.៧. ការអភិវឌ្ឍកើនឡើង ......................................................................១៥*

*២.២.៨. ការរៀនសូត្រ ឬការចែករំលែកបទពិសោធន៍ ......................... ១៦*

*២.២.៩. ក្រមសីលធម៌ និងសុចរិតភាព ........................................... ១៦*

**២.៣. ធាតុសំខាន់ៗសម្រាប់រៀបចំប្រព័ន្ធតួនាទី ភារកិច្ចរបស់ ត.ត.វ. ........ ១៦**

*២.៣.១. ការគ្រប់គ្រង ................................................................................. ១៦*

*២.៣.២. ការថែទាំប្រព័ន្ធ ....................................................................... ១៧*

*២.៣.៣. ភាពជឿជាក់................................................................................. ១៧*

**២.៤. ផែនការកសាងប្រព័ន្ធ ត.ត.វ ............................................................ ១៨**

*២.៤.១. អ្វីទៅជាផែនការ ត.ត.វ.................................................................. ១៨*

*២.៤.២. ហេតុអ្វីបានជាត្រូវបង្កើតផែនការ ត.ត.វ. ..............................១៩*

**២.៥. ធាតុសំខាន់នៃផែនការកសាងប្រព័ន្ធ ត.ត.វ. ................................ ១៩**

*២.៥.១. បរិបទ និងគោលបំណង...................................................................១៩*

*២.៥.២. វិធីសាស្ត្រ និងក្របខ័ណ្ឌក្រសួង ស្ថាប័ន មន្ទីរ .........................២០*

*២.៥.៣. កែសម្រួលក្របខ័ណ្ឌតក្កភាព (Logical Framework) និង សូចនាករអនុវត្តន៍......................................................................................២០*

*២.៥.៤. ប្រព័ន្ធព័ត៌មាន ត.ត.វ. និងរបាយការណ៍............................. ២១*

*២.៥.៥. ផែនការសកម្មភាព ត.ត.វ.................................................... ២១*

*២.៥.៦. សមត្ថភាព និងលក្ខខណ្ឌចាំបាច់ក្នុងការអនុវត្ត ត.ត.វ. .......... ២២*

*២.៥.៧. ថវិកាសម្រាប់ ត.ត.វ........................................................ ២២*

**២.៦. ដំណាក់កាល និងធាតុសំខាន់ដែលមាននៅក្នុងប្រព័ន្ធ ត.ត.វ......... ២៣**

*ជំពូកទី៣៖ មធ្យោបាយ និងយន្តការ ត.ត.វ.*

*ការអនុវត្តគោលនយោបាយ វ.ប.ន.* ........................................................ ២៤

**ផ្នែកទី១៖ ផែនការសម្រាប់ ត.ត.វ.** ................................................ ២៤

**៣.១. ផែនការសម្រាប់ ត.ត.វ** ........................................................ ២៤

*៣.១.១. គោលការណ៍សំខាន់ៗសម្រាប់ធ្វើផែនការ* ............................ ២៤

*៣.១.២. ផែនការសម្រាប់តាមដាន* ................................................ ២៧

*៣.១.៣. ផែនការសម្រាប់វាយតម្លៃ* .............................................. ២៩

*៣.១.៤. ផែនការការងារគម្រោង* .................................................. ៣១

**ផ្នែកទី២៖ ការតាមដាន ត្រួតពិនិត្យ** ................................................ ៣២

**៣.២. ដំណើរការនៃការតាមដាន ត្រួតពិនិត្យ** ........................................ ៣២

*៣.២.១. គោលការណ៍សំខាន់ៗសម្រាប់តាមដាន ត្រួតពិនិត្យ ការអនុវត្ត*

*គោលនយោបាយ វ.ប.ន.* .......................................................... ៣២

*៣.២.២. ទំហំនៃការតាមដាន ត្រួតពិនិត្យ* ...................................... ៣៤

*៣.២.៣. ការទទួលខុសត្រូវសម្រាប់ការតាមដាន ត្រួតពិនិត្យ* ............... ៣៥

*៣.២.៤. ការជ្រើសរើសឧបករណ៍ និងយន្តការ ដែលត្រឹមត្រូវសម្រាប់*

*តាមដាន ត្រួតពិនិត្យ* ............................................................. ៣៧

*៣.២.៥. ការផ្តល់ ផ្សព្វផ្សាយ ឬប្រើប្រាស់ព័ត៌មានតាមដាន ត្រួតពិនិត្យ*.៤០

**ផ្នែកទី៣៖ ការវាយតម្លៃ** ........................................................... ៤០

*៣.៣.១. គោលបំណង និងគោលការណ៍នៃការវាយតម្លៃ* ........................ ៤០

*៣.៣.២. ទំហំនៃការវាយតម្លៃ* ....................................................... ៤៨

*៣.៣.៣. បង្កើតកម្រងសំណួរដើម្បីវាយតម្លៃ* ...................................... ៤៩

*៣.៣.៤. ការរៀបចំការវាយតម្លៃ* ..................................................... ៥១

*៣.៣.៥ ដំណើរការនៃការវាយតម្លៃ* ................................................. ៥២

**ផ្នែកទី៤៖ យន្តការ ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន.** ................ ៥៣

*៣.៤.១. ក្របខ័ណ្ឌតក្កភាពនៃអន្តរាគមន៍* ........................................ ៥៣

*៣.៤.២. ខ្សែច្រវាក់លទ្ធផល ឬទ្រឹស្ដីផ្លាស់ប្ដូរ* .................................... ៥៤

*៣.៤.៣. ក្របខ័ណ្ឌតក្កភាព នៃយន្តការ ត.ត.វ. នៃ ការអនុវត្ត គោលនយោបាយ វ.ប.ន.* ............................................................ ៥៥

*៣.៤.៤. ទំនាក់ទំនងលទ្ធផល និងប្រព័ន្ធ ត.ត.វ.* ................................ ៥៩

*៣.៤.៥. ការជ្រើសរើសសូចនាករ* .................................................... ៥៩

*៣.៥.៦. ក្របខ័ណ្ឌលទ្ធផលដើម្បីពិនិត្យតាមដាន* .............................. ៦៣

*៣.៤.៧. ការបញ្ចូលទិន្នន័យ* ........................................................ ៦៥

*៣.៤.៨. តួនាទី និងប្រព័ន្ធរាយការណ៍តាមអង្គភាពរាយការណ៍* ........... ៦៧

***ឯកសារយោង*** ....................................................................... ៧៦

# បញ្ជីតារាង

តារាងទី១៖ តួនាទីបំពេញគ្នាទៅវិញទៅមករបស់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....៨
តារាងទី២៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃធ្វើបាន និងមិនអាចធ្វើបាន............ ៩
តារាងទី៣៖ វំហ្សរក្នុងការបង្កើតគោលការណ៍ណែនាំ .................................... ១២
តារាងទី៤៖ ដំណាក់កាល និងធាតុសំខាន់ដែលមាននៅក្នុងប្រព័ន្ធ ត.ត.វ................ ២៣
តារាងទី៥៖ តារាងផែនការសម្រាប់ការតាមដាន ........................................ ២៨
តារាងទី៦៖ ការទទួលខុសត្រូវតាមកម្រិតសម្រាប់ការតាមដាន ត្រួតពិនិត្យ............ ៣៥
តារាងទី៧៖ រូបមន្តគណនាប្រសិទ្ធភាព ....................................................៤៧
តារាងទី៨៖ រូបមន្តគណនាប្រសិទ្ធផល .....................................................៤៧
តារាងទី៩៖ ការបង្កើតកម្រងសំណួរដើម្បីវាយតម្លៃ .......................................៥០
តារាងទី១០៖ តារាងម៉ាទ្រីសសម្រាប់វាយតម្លៃ ...........................................៥១
តារាងទី១១៖ ដំណើរការនៃការវាយតម្លៃ ..................................................៥២
តារាងទី១២៖ ទំនាក់ទំនងលទ្ធផលរបស់គម្រោង និងប្រព័ន្ធ ត.ត.វ. ............... ៥៩
តារាងទី១៣៖ ឧទាហរណ៍ក្របខ័ណ្ឌលទ្ធផលផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ .៦៤
តារាងទី១៤៖ ក្របខ័ណ្ឌពេលវេលាសម្រាប់ការផ្តល់របាយការណ៍ ................. ៧២

# បញ្ជីរូបភាព


រូបភាពទី១៖ ផែនការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....................២៥
រូបភាពទី២៖ លទ្ធផលនិងការវាយតម្លៃផលជះ..........................................៤៦
រូបភាពទី៣៖ ក្របខ័ណ្ឌតក្កភាពនៃអន្តរាគមន៍ .......................................... ៥៣
រូបភាពទី៤៖ ខ្សែប្រវាក់លទ្ធផល...............................................................៥៥
រូបភាពទី៥៖ ក្របខ័ណ្ឌតក្កភាព នៃយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ..........៥៦
រូបភាពទី៦៖ សូចនាករ និងទំនាក់ទំនងសកម្មភាព.................................... ៦២
រូបភាពទី៧៖ រំហូរនៃរបាយការណ៍.........................................................៧៣
រូបភាពទី៨៖ វដ្តនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ.............................៧៥

# បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ

| អក្សរកាត់ និងពាក្យគន្លឹះ | ការពន្យល់ន័យ |
|---|---|
| ក.ជ.វ.ប.ន. | ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ត.ត.វ. | ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ |
| ត.ត.វ.គ. | នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ |
| វ.ប.ន. | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| Sida | Swedish International Development Cooperation Agency |
| SMART | Specific, Measurable, Achievable, Relevant and Time-bound |
| STEM | Science, Technology, Engineering and Mathematics |
| STEP | Skills for Trade and Economic Diversification |
| UNCTAD | United Nations Conference on Trade and Development |
| UNDP | United Nations Development Program |
| UNESCAP | United Nations Economic and Social Commission for Asia and the Pacific |

# ខ្លឹមសារសង្ខេបប្រតិបត្តិ

គោលការណ៍ណែនាំស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត គោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) ត្រូវបាន រៀបរៀងឡើង ដើម្បីលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (ត.ត.វ.) ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ គម្រោង[1]វ.ប.ន. ថ្នាក់ជាតិ និងក្រោមជាតិ ដែលមានវិសាលភាព គ្របដណ្តប់ដល់គ្រប់ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។

គោលនយោបាយ ផែនទីបង្ហាញផ្លូវ ផែនការយុទ្ធសាស្ត្រ យុទ្ធសាស្ត្រ និង គម្រោង វ.ប.ន. នឹងត្រូវគ្រោងកម្មវិធី សកម្មភាពគោល និងសូចនាករ គាំទ្រសម្រាប់ រយៈពេលខ្លី មធ្យម និងវែង ត្រូវបានកំណត់ជាផ្នែកមួយនៃគោលការណ៍ណែនាំនេះ ផងដែរ។ គោលការណ៍នេះជាឧបករណ៍ស្នូល ឬគោលមួយក្នុងការតាក់តែង សៀវភៅណែនាំ ឬឯកសារផ្សេងៗ ស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការ អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និង គម្រោងសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផ្ទាល់របស់ ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយ វ.ប.ន. ដើម្បីទទួលបានប្រសិទ្ធភាពកាន់តែប្រសើរក្នុងការប្រើប្រាស់ធនធាន ផលិតភាព ទំនើបកម្មនៃបច្ចេកវិទ្យា ក្នុងការបង្កើននូវលទ្ធភាពប្រកួតប្រជែងទាំងក្នុងប្រទេស តំបន់ និងអន្តរជាតិ។

**គោលការណ៍ណែនាំស្តីពី ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត គោលនយោបាយ វ.ប.ន.** មាន ៣ ជំពូក ដូចខាងក្រោម៖

---

[1] សូមអានប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ជំពូកទី១** ពណ៌នាពីសាវតារ សារៈប្រយោជន៍ ខ្លឹមសារទូទៅ ភាពខុសគ្នានិងដូចគ្នា និងរំហូរនៃគោលការណ៍ណែនាំស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ វ.ប.ន.។

**ជំពូកទី២** បង្ហាញពីគោលការណ៍ណែនាំស្តីពីការបង្កើតប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. ដោយបញ្ជាក់ពីរបៀបរៀបចំប្រព័ន្ធ ត.ត.វ.។

**ជំពូកទី៣** ពន្យល់ពីមធ្យោបាយ និងយន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. ដោយចែកចេញជា ៤ ផ្នែក សំខាន់ដូចតទៅ៖ ផ្នែកទី១. ផែនការ ត.ត.វ. ផ្នែកទី២. ការតាមដាន ត្រួតពិនិត្យ ផ្នែកទី៣. ការវាយតម្លៃ និងផ្នែកទី៤. យន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.។

# ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.១. សាវតារ

របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពទទួលស្គាល់ថា វ.ប.ន. ជាកត្តាជំរុញដ៏សំខាន់ក្នុងការបើក និងពន្លឿនការផ្លាស់ប្ដូរពិភពលោកឆ្ពោះទៅរកសេដ្ឋកិច្ចរីកចម្រើន បរិយាបន្ន និងនិរន្តរភាពបរិស្ថានក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ដូចគ្នា[2]។ ដោយឃើញថា វ.ប.ន. ជាផ្នែកមួយដ៏សំខាន់ក្នុងការបង្កើនល្បឿនសេដ្ឋកិច្ចជាតិ ហើយវាក៏ជាកាតាលីករជំរុញឱ្យមានការរីកចម្រើនដល់វិស័យផ្សេងៗ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកំពុងយកចិត្តទុកដាក់គាំទ្រគ្រប់ផ្នែកពាក់ព័ន្ធ ហើយក៏បានដាក់ចេញនូវ **គោលនយោបាយជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២០-២០៣០**[3]។ ដើម្បីគាំទ្រ និងអនុវត្តឱ្យសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលចង់ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.)** បានកសាង **ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០**។ ក្នុងផែនទីនេះក៏បានផ្ដល់អនុសាសន៍ណែនាំឱ្យបង្កើត ត.ត.វ. នៃការអនុវត្តផែនទីបង្ហាញផ្លូវនេះដែរ[4]។ ដើម្បីសម្រេចបាននូវផែនទីនេះ **អគ្គនាយកដ្ឋាន វ.ប.ន.** ដែលមាន**នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ (ត.ត.វ.គ.)** ដោយបានសហការជាមួយ **នាយកដ្ឋានគោលនយោបាយ វ.ប.ន.** បានកសាងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

---

[2] ( UNCTAD, 2019 )

[3] គោលនយោបាយនេះជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍ឱ្យបានផលិតផលកាន់តែប្រសើរ និងវិធីសាស្ត្រដែលលើកកម្ពស់ផលិតភាព និងសេវាកម្មដែលមានការពេញចិត្ត ដោយផ្ដល់អាទិភាពលើការអភិវឌ្ឍធនធានមនុស្ស ពង្រឹងមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងប្រព័ន្ធអេកូនវានុវត្តន៍ជាតិប្រកបដោយកម្លាំងប្រកួតប្រជែង។

[4] សូមអានឯកសារផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០។

ការតាក់តែង ការកំណត់ទិសដៅ និងការដាក់ឱ្យអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងគម្រោងនានារបស់ផ្នែកពាក់ព័ន្ធ ពិតជាត្រូវការជាចាំបាច់នូវ ត.ត.វ. មួយដែលមានយន្តការប្រតិបត្តិ និងយន្តការស្ថាប័ន ជាក់លាក់ និងច្បាស់លាស់ ព្រោះថាលទ្ធផលដែលទទួលបានត្រូវតែបង្ហាញពីការ ពិតភាពជាក់ស្តែង ដើម្បីជាភស្តុតាងសម្រាប់ប្រៀបធៀប ឬវាស់វែងនូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងគម្រោងដែលបានកំណត់ ដោយសូចនាករនៃក្របខ័ណ្ឌលទ្ធផលផ្សេងៗ។ ត.ត.វ. គឺមានសារៈសំខាន់ក្នុងវដ្ត នៃការកសាងគោលនយោបាយទាំងឡាយ។ លទ្ធផលនៃ ត.ត.វ. នេះ នឹងជា ធាតុចូលដ៏សំខាន់ក្នុងការរៀបចំ និងកែលម្អគោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងគម្រោងទាំងឡាយតាមការចាំបាច់ និង បរិការណ៍របស់សង្គមជាតិ។

ដូចនេះហើយ **គោលការណ៍ណែនាំ នៃ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.** ចាំបាច់ត្រូវតែបង្កើត ដើម្បីជាឧបករណ៍ណែនាំក្នុងការបង្កើតសៀវភៅ ណែនាំស្តីពី ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន. សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ និងតួអង្គពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយផ្សេងៗរបស់ វ.ប.ន.។ អគ្គនាយកដ្ឋាន វ.ប.ន. ដែលមាននាយកដ្ឋាន ត.ត.វ.គ. ជាអង្គភាពបច្ចេកទេស មានតួនាទីតាមដានការអនុវត្ត ណែនាំ រៀបចំយន្តការ ផែនការសកម្មភាព ផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវវិធីសាស្ត្រ បូកសរុបរបាយការណ៍[5]ត.ត.វ. ជូន ក្រសួង ស្ថាប័ន មន្ទីរ និងតួអង្គពាក់ព័ន្ធទាំងអស់តាមការចាំបាច់។

## ១.២. សារៈប្រយោជន៍នៃ ត.ត.វ.

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគឺជាដំណើរការមួយដែលមាន គោលបំណងច្បាស់លាស់ ដើម្បីជួយឱ្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ

[5] សូមអានប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគោលនយោបាយ

ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងគម្រោងផ្សេងៗប្រសើរឡើង និងសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុក ឬរំពឹងទុកតាមរយៈការគ្រប់គ្រងការតាមដានជាប្រចាំនូវធាតុចូល សកម្មភាព ដែលគាំទ្រធាតុចេញ ឬលទ្ធផលតាមឆ្នាំ និងវាយតម្លៃវឌ្ឍនភាព លទ្ធផលចុងក្រោយ និងផលជះនៃគោលនយោបាយ ផែនទីបង្ហាញផ្លូវ យុទ្ធសាស្ត្រ ផែនការ គម្រោង ឬកម្មវិធី របស់ក្រសួង ស្ថាប័ន មន្ទីរ និងបុគ្គលម្នាក់ៗ[6] ។ ត.ត.វ. ជោគជ័យបាន លុះត្រាតែមានការចូលរួមពីតួអង្គពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍[7]។ ត.ត.វ. គួរតែត្រូវបានបញ្ចូលទៅក្នុងគ្រប់គោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ផែនទីបង្ហាញផ្លូវ និងគម្រោងនៅក្នុងដំណាក់កាលនៃការកសាងកិច្ចការទាំងនោះ។ គោលបំណងសំខាន់ៗនៃ ត.ត.វ. គឺដើម្បី[8]៖

១. ភ្ជាប់ ត.ត.វ. ជាមួយលទ្ធផលផ្អែកលើការគ្រប់គ្រង
២. គាំទ្រ ឬធ្វើឱ្យក្រសួង ស្ថាប័នប្រតិបត្តិ មានគណនេយ្យភាពទាំងក្នុង និងក្រៅ
៣. បង្កើនសមត្ថភាពក្រសួង ស្ថាប័ន គណៈគ្រប់គ្រង និងមន្ត្រី ដែលបានអនុវត្ត
៤. ជំរុញអំណាចនៃអ្នកដែលទទួលផលប្រយោជន៍ពីគោលនយោបាយ និងគម្រោង វ.ប.ន. ផ្សេងៗ
៥. ជំរុញបរិយាកាសនៃការវាយតម្លៃ និងការសិក្សាជុំវិញលទ្ធផលនៃដំណើរការប្រតិបត្តិ
៦. ធ្វើឱ្យដឹងពីប្រសិទ្ធភាព និងប្រសិទ្ធផល ភាពទាក់ទង និងនិរន្តរភាពនៃគោលនយោបាយ និងគម្រោង ឬកម្មវិធីដែលបានដាក់ឱ្យអនុវត្ត
៧. ធានាការផ្តល់ព័ត៌មានដល់ការសម្រេចចិត្ត និងធ្វើឱ្យប្រសើរឡើងក្នុងការដាក់ចេញនូវគោលនយោបាយបន្ទាប់ដោយផ្អែកលើបញ្ហា និងដំណោះស្រាយពីគោលនយោបាយមុនៗ
៨. ផ្តល់ជាមេរៀន ឬបទពិសោធន៍សម្រាប់ស្វែងយល់បន្ទាប់ពីបានអនុវត្តរួច ឬកំពុងអនុវត្ត។

---

[6] ( UNDP, 2002 )

[7] Dmunds & Marchant, 2008 cited in IDEA PPTs, ( 2021 )

[8] Sports and Development Organization & Edmunds & Marchant, 2008 cited in IDEA PPTs, ( 2021 )

## ១.៣. ខ្លឹមសារទូទៅនៃ ត.ត.ទ.[9]

### ១.៣.១. ការតាមដាន និងត្រួតពិនិត្យ

ការតាមដាន ត្រួតពិនិត្យ គឺជាការពិនិត្យ ប្រមូល វិភាគ និងប្រើព័ត៌មានសម្រាប់អង្កេត និងកត់ត្រានូវវឌ្ឍនភាព ភាពរាំងស្ទះ ឬឧបសគ្គ[10]និងលទ្ធផលទៅតាមផែនការសកម្មភាពដែលបានកំណត់។ វាគឺជាផ្នែកមួយនៃការគ្រប់គ្រងគោលនយោបាយ គម្រោង ឬផែនការ ដោយពិនិត្យគ្រប់ទិដ្ឋភាពនៃការអនុវត្ត តាមរយៈប្រព័ន្ធផ្តល់ព័ត៌មានត្រឡប់ជាប្រចាំ ដើម្បីធានាការសម្រេចឱ្យបាននូវសូចនាករគោលដៅ ដែលមាននៅក្នុងគោលនយោបាយ ឬគម្រោងផ្សេងៗ[11]។ ការតាមដាន ត្រួតពិនិត្យ ប្រព្រឹត្តទៅក្នុងដំណាក់កាលនៃការប្រមូលធាតុចូល ការអនុវត្តសកម្មភាព និងធាតុចេញ ឬលទ្ធផលសម្រេចបានក្នុងឆ្នាំ។ ការតាមដាន ត្រួតពិនិត្យមានដូចតទៅ៖

**ការតាមដាន ត្រួតពិនិត្យជាប្រចាំ៖** ការតាមដាន ត្រួតពិនិត្យជាប្រចាំ ជាការតាមដានប្រចាំខែ ទៅលើផែនការសកម្មភាពរបស់នាយកដ្ឋានទទួលបន្ទុកនៃក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ ផែនការ គម្រោង និងកម្មវិធីផ្សេងៗដោយនាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរ។ ក្រសួង ស្ថាប័ន ឬមន្ទីរទាំងនោះ ត្រូវរាយការណ៍ជាប្រចាំខែពីលទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាពជូននាយកដ្ឋាន ត.ត.វ.គ. សម្រាប់ផ្តល់ព័ត៌មានដែលមានតម្លៃ និងសម្រាប់ជាឯកសារវាយតម្លៃពាក់កណ្តាលអាណត្តិ។ ការវាយតម្លៃដែលមានប្រសិទ្ធភាព គឺជាធាតុដ៏សំខាន់សម្រាប់ការរៀនសូត្រ ឬជាគំនិតផ្តួចផ្តើមនិរន្តរភាពនៃការរៀនសូត្រ។[12]

**ការតាមដាន ត្រួតពិនិត្យពីវឌ្ឍនភាព៖** ការតាមដាន ត្រួតពិនិត្យពីវឌ្ឍនភាពនឹងប្រព្រឹត្តទៅតាមត្រីមាស ឆមាស និងឆ្នាំដោយផ្អែកលើធាតុចូលរបស់នាយកដ្ឋាន

---

[9] Nepalese Monitoring and Evaluation Guidelines, (2013).

[10] UNDP, 2002: Handbook on Monitoring and Evaluation for Results

[11] CHAB DAI, 2018: Project Monitoring and Evaluation

[12] Marriott, N. & Goyder, H. (2009): Manual for Monitoring and Evaluation Education Partnerships

ទទួលបន្ទុកនៃក្រសួង ស្ថាប័ន និងមន្ទីរ ដែលពាក់ព័ន្ធនឹងសូចនាករដែលមាននៅក្នុងគោលនយោបាយ គម្រោង និង កម្មវិធីផ្សេងៗដែលត្រូវអនុវត្ត។ របាយការណ៍នេះនឹងត្រូវបានប្រមូល និងរៀបចំដោយនាយកដ្ឋាន ត.ត.វ.គ. ដើម្បីដាក់ជូនដល់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ជ.វ.ប.ន.) ដើម្បីពិនិត្យពិភាក្សា និងផ្តល់អនុសាសន៍។

**ការតាមដាន ត្រួតពិនិត្យការអនុវត្ត៖** ការតាមដាន ត្រួតពិនិត្យ ជាពេលដ៏សំខាន់មួយ ដែលទាមទារឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ យកចិត្តទុកដាក់នូវអ្វីដែលសម្រេចបាន និងមិនបានក្នុងការអនុវត្តគោលនយោបាយ និងផែនការនានា។ ការតាមដាន ត្រួតពិនិត្យនេះ ផ្តោតលើការចូលរួមក្នុងការកសាង និងការអនុវត្តយុទ្ធសាស្ត្រ គម្រោង និងកម្មវិធីដៃគូ ជំនួយការក្នុងការផ្តល់យោបល់ ការពិភាក្សា ការសម្របសម្រួលលើគោលនយោបាយ ដែលផ្តល់ដោយតួអង្គពាក់ព័ន្ធខាងក្រៅក្នុងការបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ គម្រោង និងកម្មវិធីអនុវត្តន៍នានា។ ដើម្បីធ្វើឱ្យការតាមដាននេះមានប្រសិទ្ធភាព អ្នកគ្រប់គ្រងកម្មវិធីត្រូវតែបង្កើតបន្ទាត់មូលដ្ឋាន ជ្រើសរើសសូចនាករលទ្ធផល បង្កើតយន្តការដែលបញ្ចូលផែនការសកម្មភាព ដូចជាការចុះផ្ទាល់ ការប្រជុំជាមួយតួអង្គពាក់ព័ន្ធ ការធ្វើរបាយការណ៍ និងការវិភាគជាប្រព័ន្ធ។[13]

### ១.៣.២. ការវាយតម្លៃ

ការវាយតម្លៃ គឺជាការវិនិច្ឆ័យ និងការផ្តល់តម្លៃបែបវិទ្យាសាស្ត្រ ដើម្បីវាស់វែងឥទ្ធិពល និងផលជះនៃការអនុវត្តគោលនយោបាយ និងផែនការផ្សេងៗរបស់ វ.ប.ន. បន្ទាប់ពីបានដាក់ឱ្យប្រើប្រាស់។ ការប្រព្រឹត្តទៅនៃការវាយតម្លៃតែងតែធ្វើឡើងនៅពាក់កណ្តាល និងចុងបញ្ចប់នៃការអនុវត្តគោលនយោបាយ និងផែនការ ឬធ្វើឡើងក្នុងពេលវេលាជាក់លាក់ណាមួយ ដែលបានកំណត់ក្នុងគោលនយោបាយ និងផែនការនោះ។ ការវាយតម្លៃ នឹងផ្តល់ជាពិន្ទុ ឬការវាស់ស្ទង់ និងអនុសាសន៍ ដើម្បីយកទៅអនុវត្តបន្ត ឬកែលម្អ ឱ្យសម្រេចលទ្ធផលតាមផែនការ គោលដៅ និងប្រើធនធានឱ្យមានប្រសិទ្ធភាព ហើយអ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រង

---

[13] UNDP, 2002: Handbook on Monitoring and Evaluation for Results

ត្រូវយកលទ្ធផលនេះមកឆ្លុះបញ្ចាំងពីលទ្ធភាពដែលអាចធ្វើឱ្យកាន់តែប្រសើរឡើង និងកែសម្រួលគោលនយោបាយ ឱ្យមានភាពបន្សុីជាមួយតថភាពជាក់ស្តែងនៃសង្គម និងការអនុវត្ត។ ការវាយតម្លៃមានដូចតទៅ៖

**ការវាយតម្លៃដំណើរការ៖** ការវាយតម្លៃនេះចង់ដឹង ថាតើយន្តការនៃការអនុវត្តកម្មវិធីដែលបានកំណត់នៅក្នុងគោលនយោបាយ ផែនការ អាចសម្រេចគោលបំណងនៃគោលនយោបាយ និងផែនការដែរឬទេ។ ការវាយតម្លៃនេះអាចជាការវាយតម្លៃទោល ឬមានលក្ខណៈធំ (ទូលំទូលាយ) ដើម្បីរករូបភាពទូទៅនៃការអនុវត្តកម្មវិធី និងគោលនយោបាយ។ លទ្ធផលនៃការវាយតម្លៃនេះអាចជួយបុគ្គលិកផ្នែកកម្មវិធី និងគោលនយោបាយ ក្នុងការអនុវត្តកម្មវិធីដែលបានកែលម្អដោយផ្ទាល់។ ការវាយតម្លៃនេះ អាចបង្ហាញពីបញ្ហាប្រឈមនៅក្នុងការកសាងគោលនយោបាយ និងគម្រោងតាំងពីដំបូង។ ការវាយតម្លៃនេះ ជាផ្នែកដែលសំខាន់នៃការវាយតម្លៃផលជះដែលផ្តោតលើការវាស់វែងលទ្ធផលជាក់លាក់ ដែលមិនអាចសម្រេចបានច្រើនដូចការវាយតម្លៃដំណើរការទេ។ ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការដើម្បីរៀបចំការវាយតម្លៃនេះមានដូចតទៅ៖ ១) ផែនការ ២) ការបង្ហាញកម្មវិធីដល់តួអង្គពាក់ព័ន្ធ ៣) សំណើសម្រាប់អត្ថប្រយោជន៍ ៤) ការជ្រើសរើសអ្នកទទួលបាននូវផលប្រយោជន៍ ៥) ផលិតផល និងការចូលរួមរបស់អ្នកទទួលផលប្រយោជន៍ ៦)ការបែងចែកអត្ថប្រយោជន៍ ៧)អ្នកទទួលអត្ថប្រយោជន៍ ៨) តាមដានពីភាពត្រឹមត្រូវនៃការប្រើប្រាស់ប្រយោជន៍ ៩) គណនេយ្យភាពនៃអ្នកទទួលផល ១០) ការគ្រប់គ្រង និងតាមដាន និង ១១) ផ្សេងៗ។ [14]

**ការវាយតម្លៃផលជះ៖** ការវាយតម្លៃផលជះផ្តោតលើការវិភាគគោលនយោបាយ គម្រោង និងកម្មវិធីក្នុងការសម្រេចបានដោយជោគជ័យនូវគោលបំណងរយៈពេលមធ្យម និងវែង។ ដោយឡែកពីនេះ ការវាយតម្លៃ និងវិភាគផលជះ ដែលចង់ឱ្យសម្រេចបាន ត្រូវប៉ាន់ប្រមាណទាំងផលជះ និងការចែករំលែកក្នុងចំណោមក្រុមគោលដៅ។ ការវាយតម្លៃនេះត្រូវបានប្រើប្រាស់ច្រើនសម្រាប់

[14] THE WORLD BANK, Planning, Monitoring and Evaluation: Methods and Tools for Poverty and Inequality Reductions Programs

ដំណើរការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ។ ហើយការវាយតម្លៃនេះ អាចផ្តល់ព័ត៌មានដល់អ្នកគ្រប់គ្រងកម្មវិធីក្នុងការកែលម្អកម្មវិធី នៅពេលដែលលទ្ធផលបង្ហាញថាមិនសម្រេចតាមការគ្រោងទុក។ លើសពីនេះទៅទៀត ការវាយតម្លៃផលជះ ត្រូវបានគេគិតថាជាភស្តុតាងដ៏សំខាន់សម្រាប់គ្រប់ការវាយតម្លៃ។[15]

**ការវាយតម្លៃប្រតិបត្តិ៖** ការវាយតម្លៃប្រតិបត្តិជួយអ្នកបង្កើតគោលនយោបាយ ពិនិត្យទៅលើការអនុវត្តកម្មវិធីតាំងពីការបង្កើត រៀបចំផែនការយុទ្ធសាស្ត្រប្រតិបត្តិ និងលទ្ធផលដែលចាត់ទុកជាផ្នែកមួយនៃភាពជោគជ័យរបស់កម្មវិធី។ ការវាយតម្លៃនេះត្រូវបានបញ្ចប់ក្នុងពេលខ្លីណាមួយតាមថវិកាកំណត់។ វាផ្តោតលើការផ្តល់ទិដ្ឋភាពទូទៅនៃព័ត៌មានអនុវត្តន៍ជាជាងការវិភាគពិស្តារ។ តម្លៃបន្ថែមមួយទៀតនៃការវាយតម្លៃនេះគឺ វាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការគណនេយ្យភាពក្នុងស្ថាប័នច្បាប់ និងសាធារណៈ។ ការវាយតម្លៃប្រតិបត្តិ គឺមិនគ្រប់គ្រាន់សម្រាប់វិភាគគណនេយ្យភាពបានទេ ព្រោះមានរយៈពេលវែង និងមានលក្ខណៈបច្ចេកទេសសម្រាប់អ្នកមិនមានជំនាញ ប៉ុន្តែវាអាចជួយក្នុងការជជែកពីលទ្ធផលជាមួយតួអង្គពាក់ព័ន្ធបាន។

## ១.៤. ភាពខុសគ្នា និងដូចគ្នារវាង ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យអាចធ្វើឡើង នៅក្នុងកម្រិតគម្រោង កម្មវិធី និងគោលនយោបាយ។ បើត្រឹមកម្រិតគម្រោង ត្រូវពិនិត្យទៅលើការយល់ដឹងនៅកម្រិតគោលដៅ។ សម្រាប់កម្រិតកម្មវិធី ការតាមដាន ត្រួតពិនិត្យ គឺដើម្បីប្រាកដថាព័ត៌មានដែលទទួលបានអាចសម្រេចតាមគោលដៅ។ បើជាកម្រិតគោលនយោបាយ គឺជាការពិនិត្យទៅលើទិដ្ឋភាពទូទៅ។ ត.ត.វ. គឺអាច ធ្វើឡើងនៅកម្រិតគោលនយោបាយ និងគម្រោងដូចគ្នា។

---

[15] THE WORLD BANK, Planning, Monitoring and Evaluation: Methods and Tools for Poverty and Inequality Reductions Programs

**តារាងទី១៖** តួនាទីបំពេញគ្នាទៅវិញទៅមករបស់ការតាមដាន ត្រួតពិនិត្យ និង
វាយតម្លៃ

| ការតាមដាន ត្រួតពិនិត្យ | ការវាយតម្លៃ |
|---|---|
| អះអាងបញ្ជាក់ពីគោលបំណងរបស់កម្មវិធី | វិភាគហេតុអ្វីលទ្ធផលដែលគ្រោងមិនសម្រេច ឬសម្រេច |
| ភ្ជាប់សកម្មភាព និងធនធានរបស់វាទៅនឹងគោលបំណង | វាយតម្លៃបុព្វហេតុរួមចំណែកជាក់លាក់នៃសកម្មភាពដើម្បីសម្រេចលទ្ធផល |
| បកប្រែគោលបំណងឱ្យទៅជាសូចនាករអនុវត្តន៍ និងកំណត់គោលដៅ | ពិនិត្យដំណើរការអនុវត្តន៍ |
| ប្រមូលទិន្នន័យគ្រប់សូចនាករជាប្រចាំ ប្រៀបធៀបលទ្ធផលពិត និងគោលដៅ | ស្វែងរកលទ្ធផលដែលចង់បាន ឬគ្រោង |
| រាយការណ៍ពីវឌ្ឍនភាពជូនអ្នកគ្រប់គ្រង និងរាយការណ៍ពីភាពរាំងស្ទះ ឬបញ្ហាប្រឈម | ផ្តល់មេរៀន បង្ហាញពីសមិទ្ធផលសំខាន់ៗ ឬកម្មវិធីដែលមានសក្តានុពល និងផ្តល់អនុសាសន៍សម្រាប់កែលម្អ |

**តារាងទី២៖** ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃធ្វើបាន និងមិនអាចធ្វើបាន[16]

| ធ្វើបាន | មិនអាចធ្វើបាន |
|---|---|
| ១. សូមបញ្ចូល ត.ត.វ. នៅគ្រប់ដំណាក់-កាលនៃការធ្វើកម្មវិធី ឬផែនការ។<br>២. ទោះបីជា ត.ត.វ. ត្រូវប្រើប្រាស់ថវិកា ពេលវេលា ធនធានមនុស្ស ក៏ព្រោះតែដើម្បីឱ្យកម្មវិធី ឬគម្រោងជោគជ័យ។<br>៣. សូមប្រាកដថាអ្នកដែលចូលរួមក្នុងកិច្ចការ ត.ត.វ. ត្រូវតែទទួលបានការបណ្តុះបណ្តាល និងយល់ពីសារៈសំខាន់នៃ ត.ត.វ. ។<br>៤. គួរបញ្ចូលតួអង្គពាក់ព័ន្ធច្រើនតាមដែលអាចធ្វើបានទៅក្នុង ត.ត.វ.។<br>៥. កុំបញ្ចូលអ្នកដែលរៀនសូត្រទៅក្នុងដំណើរការវាយតម្លៃ។<br>៦. ត្រូវប្រាកដថារាល់ឧបករណ៍ត.ត.វ. ត្រូវតែធ្វើការសាកល្បងយ៉ាងយកចិត្តទុកដាក់។<br>៧. ត្រូវប្រាកដថា អ្នកអាចជំរុញគំនិតថា ត.ត.វ. គឺការរៀនសូត្រពីបទពិសោធន៍នៃកម្មវិធីមួយ។ | ១. កុំធ្វើ ត.ត.វ. ធម្មតាៗ កុំវាស់វែងគ្រាន់តែដើម្បីវាស់វែង។<br>២. កុំបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងមួយដែលប្រើប្រាស់ ត.ត.វ. ជាវិធានក្នុងការរិះគន់អវិជ្ជមាន លើការអនុវត្តកម្មវិធី និងគោលនយោបាយ។<br>៣. កុំចាប់ផ្តើម ត.ត.វ. លុះត្រាតែមានការផ្តល់មូលនិធិគ្រប់គ្រាន់។<br>៤. កុំផ្តោតលើបច្ចេកវិទ្យាទាំងស្រុង។<br>៥. កុំអនុញ្ញាតឱ្យការរាយការណ៍ដោយខ្លួនឯងជាមធ្យោបាយតែមួយគត់ដើម្បីអះអាងថាការរៀនសូត្រជាគោលដៅធំ ហើយកុំប្រើតែមនុស្សខាងក្រៅសម្រាប់ ត.ត.វ.។<br>៦. កុំភ្លេចពីវប្បធម៌ចម្រុះ។<br>៧. កុំភ្លេចពិចារណាលទ្ធផល ដែលមិនបានរំពឹងទុកនៃកម្មវិធី។<br>៨. កុំភ្លេចលែលកឱ្យភាគីពាក់ព័ន្ធទិញ ឬចាប់អារម្មណ៍ផលិតផល ឬសេវាកម្ម ត.ត.វ.។<br>៩. កុំភ្លេចអំពីសារៈសំខាន់នៃការប្រែប្រួលតាមបរិបទនិងភូមិសាស្ត្រ។ |

[16]Wagner, et al.  2005

| | |
|---|---|
| ៨. ត្រូវតែផ្សព្វផ្សាយលទ្ធផល ដូច្នេះ អ្នកដទៃអាចទាញប្រយោជន៍ពី បទពិសោធន៍នេះ។<br>៩. ត្រូវចងចាំថា ត្រូវរក្សាគោល-នយោបាយ វ.ប.ន. នៅក្នុងចិត្ត ដោយ យោងតាមគោលនយោបាយផ្សេងៗ តាមភាពចាំបាច់ និងផ្តល់អាទិភាព។<br>១០. ត្រូវតែបង្កើតឧបករណ៍តាមដាន ត្រួតពិនិត្យ ដែលគាំទ្រឬអាចប្រើបាន គ្រប់គោលនយោបាយ។ | ១០. កុំព្រួយបារម្ភណ៍ប្រសិនបើធ្វើ មិនត្រូវលើកដំបូង។<br>១១. កុំទុកការពិភាក្សាយុទ្ធសាស្ត្រ អនុវត្តន៍ វ.ប.ន. របស់អ្នកដោយគ្មាន ការត្រួតពិនិត្យ និងវាយតម្លៃដំណើរការ សមាសធាតុដែលផ្តល់មូលនិធិ។ |

## ១.៥. មូលដ្ឋាននៃ ត.ត.វ.

**កម្រិតអន្តរក្រសួង៖** ត.ត.វ. នឹងធ្វើការលើគោលនយោបាយជាតិផ្សេងៗ ស្តីពី វ.ប.ន. ដែលដឹកនាំ និងសម្របសម្រួលដោយ ក.ជ.វ.ប.ន. ដែលមាន អគ្គនាយកដ្ឋាន វ.ប.ន. ជាលេខាធិការដ្ឋាន។ ឧទាហរណ៍៖ ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ ផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាសុខាភិបាល ផែនទីបង្ហាញផ្លូវ បច្ចេកវិទ្យាអបរំ ផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាកសិកម្ម ជាអាទិ៍។

**កម្រិតក្រសួង៖** ត.ត.វ. មានវិសាលភាពលើគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ ផែនការ និងផែនការថវិការយៈពេលវែង មធ្យម និងខ្លីរបស់ក្រសួង ឧ.វ.ប.ន. ដូចជា៖ ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឬ១០ឆ្នាំ ផែនការ៣ឆ្នាំរំកិល ផែនការប្រចាំឆ្នាំ និងគម្រោងផ្សេងៗដែលទាក់ទងទៅនឹងវិស័យ វ.ប.ន.។

**កម្រិតក្រោមជាតិ(មន្ទីរ)៖** ត.ត.វ. នឹងពិនិត្យលើរាល់ផែនការ និង ផែនការថវិការបស់មន្ទីរ ដែលមានទំនាក់ទំនងជាមួយគោលនយោបាយ ផែនការមេ និងគម្រោងទាំងឡាយរបស់ក្រសួង ឧ.វ.ប.ន. ដែលតម្រូវឱ្យអនុវត្ត ដើម្បីសម្រេច គោលបំណងរួមរបស់ក្រសួង ឧ.វ.ប.ន.។

## ១.៦. រំហូរនៃការផ្សព្វផ្សាយសេចក្តីណែនាំ និងការសម្របសម្រួលព័ត៌មាន

នៅក្នុងមាត្រា៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ឧ.វ.ប.ន. តម្រូវឱ្យក្រសួងរៀបចំ ដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍន៍ក្នុងវិស័យ ឧ.វ.ប.ន. រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត។[17] ដោយពិនិត្យឃើញថា គោលនយោបាយ វ.ប.ន. មានលក្ខណៈទូលំទូលាយ និងមានវិសាលភាពគ្របដណ្តប់លើការអនុវត្តរបស់ស្ថាប័នជាតិ និងក្រោមជាតិ ដែលលើកកម្ពស់ការប្រើប្រាស់ វ.ប.ន. សម្រាប់ការរីកចម្រើនគ្រប់វិស័យ រាជរដ្ឋាភិបាលបានបង្កើត ក.ជ.វ.ប.ន. ដើម្បីសម្របសម្រួល ដឹកនាំការងារ វ.ប.ន. ក្នុងក្របខ័ណ្ឌអន្តរក្រសួង ស្ថាប័ន ក្នុងគោលបំណង ត.ត.វ. ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោង ឬកម្មវិធី វ.ប.ន. ហើយធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល[18]។ អគ្គនាយកដ្ឋាន វ.ប.ន. មាននាយកដ្ឋាន ត.ត.វ.គ. ជាអ្នកអនុវត្តផ្ទាល់នូវការងារនេះ។ ដើម្បីធានាឱ្យការងារ ត.ត.វ. ការអនុវត្តគោលនយោបាយមានប្រសិទ្ធភាព និងប្រសិទ្ធផល របាយការណ៍ដែលចេញដោយនាយកដ្ឋាន ត.ត.វ.គ. ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ក្នុងគោលបំណងស្វែងរកការគាំទ្រពីគ្រប់ផ្នែកពាក់ព័ន្ធ និងកុំឱ្យនីតិវិធីមានភាពចម្រូងចម្រាសពេលអនុវត្តជាក់ស្តែង។

ខាងក្រោមនេះ ជារំហូរក្នុងការបង្កើតគោលការណ៍ណែនាំនេះ ឱ្យទទួលបានធាតុចូលពីស្ថាប័នពាក់ព័ន្ធ និងទទួលបានការគាំទ្រក្នុងការអនុវត្តជាក់ស្តែង៖

---

[17] សូមអានអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[18] សូមអានព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**តារាងទី៣៖** រំហូរក្នុងការបង្កើតគោលការណ៍ណែនាំ

| រំហូរ | សកម្មភាព | ដោយ |
|---|---|---|
| ១. | ព្រាងឯកសារគោលការណ៍ណែនាំស្តីពី ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន. | នាយកដ្ឋាន ត.ត.វ.គ. |
| ២. | ធ្វើបទបង្ហាញ និងទទួលយកធាតុចូលក្នុងអគ្គនាយកដ្ឋាន | នាយកដ្ឋាន ត.ត.វ.គ. |
| ៣. | ព្រាងឯកសារគោលការណ៍ណែនាំស្តីពី ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. ចុងក្រោយកម្រិតអគ្គនាយកដ្ឋាន | នាយកដ្ឋាន ត.ត.វ.គ. |
| ៤. | ធ្វើបទបង្ហាញនិងទទួលយកធាតុចូលកម្រិតក្រសួង | អគ្គនាយកដ្ឋាន វ.ប.ន. |
| ៥. | កែសម្រួលឯកសារ និងរៀបចំសម្រាប់ការធ្វើបទបង្ហាញតាមរយៈសិក្ខាសាលាទៅកាន់ក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីទទួលធាតុចូល | អគ្គនាយដ្ឋាន វ.ប.ន. នាយកដ្ឋានត.ត.វ.គ. |
| ៦. | ការកែសម្រួលឯកសារចុងក្រោយសម្រាប់ផ្សព្វផ្សាយនិងអនុវត្ត | អគ្គនាយក វ.ប.ន. |

# ជំពូកទី២៖ គោលការណ៍ណែនាំស្តីពីការបង្កើតប្រព័ន្ធ ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន.

## ២.១. សេចក្តីផ្តើមនៃប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.

ប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្រ្ត ផែនការមេ ផែនការសកម្មភាព គម្រោង និងកម្មវិធី វ.ប.ន. របស់ក្រសួង ឧ.វ.ប.ន. ស្ថិតនៅក្រោមអគ្គនាយកដ្ឋាន វ.ប.ន. ដែលមាននាយកដ្ឋាន ត.ត.វ.គ. ជាអង្គភាពបច្ចេកទេសប្រតិបត្តិផ្ទាល់។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដោយសំណុំនៃសកម្មភាពដែលប្រទាក់ក្រឡាគ្នា ដែលត្រូវតែអនុវត្តក្នុងវិធីសម្របសម្រួលមួយ ដើម្បីរៀបចំផែនការ ត.ត.វ. ប្រមូលទិន្នន័យ វិភាគទិន្នន័យ និងរាយការណ៍ព័ត៌មាន ដើម្បីគាំទ្រដល់ការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ និងការអនុវត្តការកែលម្អនាពេលអនាគត[19]។ ប្រព័ន្ធ ត.ត.វ. នឹងត្រូវបញ្ចូលក្នុងពេលនៃការរៀបចំគោលនយោបាយ គម្រោង ឬផែនការមេផ្សេងៗដែលយើងចង់ធ្វើ ត.ត.វ. ព្រោះវាចំណាយតិច និងសម្រេចនូវគោលបំណងដែលយើងចង់បាន។ ប្រសិនបើកសាងប្រព័ន្ធ ត.ត.វ. ក្រោយការកសាងគម្រោង ផែនការមេ ឬគោលនយោបាយ វានឹងបង្កឱ្យមានបញ្ហាជាច្រើន ព្រោះវាមិនបានផ្តល់ពេលវេលា ធនធាន និងកិច្ចប្រឹងប្រែងគ្រប់គ្រាន់ដល់អ្នកអនុវត្ត ឬអ្នកគ្រប់គ្រងគម្រោងឡើយ។

[19] ESCAP M&E SYSTEM ( 2010 ): Monitoring &Evaluation System Overview and Evaluation Guidelines

## ២.២. គោលការណ៍ទូទៅក្នុងការបង្កើតប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.

គ្រប់ការកសាងប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. យើងគួរតែពិនិត្យលើបរិបទដូចតទៅ[20] ៖

### ២.២.១. តម្លៃបន្ថែម

ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន. មិនគួរណាបង្កើតដើម្បីបន្ថែមការលំបាក ឬបន្ទុកក្នុងការតាមដាន ត្រួតពិនិត្យ និងរាយការណ៍ទេ។ តម្លៃបន្ថែមរបស់វាគឺធ្វើឱ្យមានលក្ខណៈស្តង់ដារ និងងាយស្រួលក្នុងការតាមដាន ត្រួតពិនិត្យ និងរាយការណ៍ជូនក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងវិស័យ វ.ប.ន.។

### ២.២.២. ការតាំងចិត្ត ឬប្តេជ្ញាចិត្ត ដើម្បីបង្ហាញនូវលទ្ធផល

ត.ត.វ. នឹងផ្តោតទៅលើការវាស់វែងលទ្ធផលក្រុមគោលដៅរបស់អនុកម្មវិធី កម្មវិធី គម្រោង ផែនការមេ ឬគោលនយោបាយ វ.ប.ន. ក្នុងដែនសមត្ថកិច្ចរបស់អ្នកគ្រប់គ្រងគ្រប់ផ្នែកដែលកំពុង ឬបានអនុវត្តនៅក្នុងគម្រោង ផែនការមេ និងគោលនយោបាយចាប់តាំងពីថ្នាក់ក្រោម(មន្ត្រី) រហូតដល់ថ្នាក់លើ (រដ្ឋមន្ត្រី) ទៅតាមការទទួលខុសត្រូវឱ្យសម្រេចបាននូវសូចនាករដែលបានកំណត់។

### ២.២.៣. ពង្រឹងការសម្រេចចិត្ត និងគណនេយ្យភាព

ប្រព័ន្ធ ត.ត.វ. នឹងរាយការណ៍ពីសំណុំសូចនាករអប្បបរមា ដែលត្រូវការដើម្បីជំរុញការសម្រេចចិត្តដោយផ្អែកលើភស្តុតាង ឬរបាយការណ៍ដែលបង្ហាញការពិត។ នៅថ្ងៃអនាគតស្ថាប័ន វ.ប.ន. នឹងផ្អែកលើប្រព័ន្ធព័ត៌មានតាមអ៊ីនធើណិតតែមួយ (Online) ដែលទិន្នន័យត្រូវបានបញ្ចូលក្នុងប្រព័ន្ធផ្ទុកទិន្នន័យ (Database)

---

[20] IDEA International PPT, (2021): This information is adopted from the source of How to Build a Monitoring and Evaluation System PowerPoint Presentation.

របស់នាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. ដោយអ្នកអនុវត្តក្នុងអនុកម្មវិធី កម្មវិធី គម្រោង ផែនការមេ ឬ គោលនយោបាយ។ ថ្នាក់ដឹកនាំត្រូវគិតគូរពីគោលការណ៍ ឧបត្ថម្ភធន និងសមត្ថភាពរបស់អ្នកអនុវត្ត ដើម្បីជំរុញប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយនានារបស់ វ.ប.ន. នេះ។

### ២.២.៤. ប្រសិទ្ធភាពចំណាយ

ប្រព័ន្ធ ត.ត.វ. នឹងគិតលើភាពចំណោញទាំងពីរ គឺអត្ថប្រយោជន៍ និងតម្លៃនៃព័ត៌មានបន្ថែម ដើម្បីកំណត់ចំនួនព័ត៌មាន ដែលមានតម្លៃក្នុងការប្រមូល និងដំណើរការ។

### ២.២.៥. ការភ្ជាប់គ្នាគ្រប់កម្រិតផែនការ

ប្រព័ន្ធ ត.ត.វ. នឹងត្រូវបង្កើតឡើងជាបីថ្នាក់ ដើម្បីរាយការណ៍ពីវឌ្ឍនភាពនៅកម្រិតផែនការទាំងបី៖ ១) គោលនយោបាយ ឬយុទ្ធសាស្ត្ររយៈពេលវែង (បច្ចុប្បន្នយើងមានផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា២០៣០ និងផែនទីបង្ហាញផ្លូវផ្សេងៗទៀត) ២) ផែនការរយៈពេលមធ្យម និង ៣) ផែនការសកម្មភាពប្រចាំឆ្នាំ នៃតួអង្គពាក់ព័ន្ធនីមួយៗ ដោយភ្ជាប់ទៅនឹងផែនការថវិការយៈពេលវែង មធ្យម និងខ្លី។

### ២.២.៦. ការផ្សារភ្ជាប់គ្រប់តួអង្គពាក់ព័ន្ធ

ប្រព័ន្ធ ត.ត.វ. ត្រូវគិតពីកម្រិតនៃយុទ្ធសាស្ត្រ កម្រិតស្ថាប័ន និងកម្រិតប្រតិបត្តិ និងអនុលោមតាមវិធីសាស្ត្រ "Three-ones" approach៖ ប្រព័ន្ធផែនការមួយ ប្រព័ន្ធថវិកាមួយ និងប្រព័ន្ធ ត.ត.វ. មួយ។ តួអង្គពាក់ព័ន្ធត្រូវតែអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់រួមគ្នាមួយ។ បច្ចុប្បន្នយើងមានផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ ដែលនឹងធ្វើការតាមដានដោយភ្ជាប់គ្រប់តួអង្គពាក់ព័ន្ធផ្សេងៗ។

### ២.២.៧. ការអភិវឌ្ឍកើនឡើង

ត្រូវចាប់ផ្តើមធម្មតា ប៉ុន្តែធ្វើឱ្យតួនាទីប្រព័ន្ធ ត.ត.វ. ដំណើរការតាំងពីការចាប់ផ្តើម និងមានការអភិវឌ្ឍជាបន្តបន្ទាប់៖ ត្រូវសាកល្បងឱ្យដឹងថាប្រព័ន្ធនឹង

ចាប់ផ្តើមដំណើរការល្អចាប់ពីការប្រមូល ប្រតិបត្តិ និងរាយការណ៍ពីសំណុំសូចនាករ អប្បបរមា។ បន្ទាប់ពីប្រព័ន្ធមានការរីកចម្រើន ត្រូវពង្រឹងសមត្ថភាពអ្នកអនុវត្ត ប្រព័ន្ធ ត.ត.វ. ជាប្រចាំដោយមានការសហការទៅតាមភាពចាំបាច់។

### ២.២.៨. ការរៀនសូត្រ ឬការចែករំលែកបទពិសោធន៍

គោលបំណងនៃ ត.ត.វ. គឺមិនមែនជាសវនកម្មទេ ប៉ុន្តែដើម្បីរកឱ្យឃើញនូវវឌ្ឍនភាព បញ្ហាប្រឈម ភាពរាំងស្ទះ និងដំណោះស្រាយជាមេរៀនសម្រាប់យកទៅអនុវត្តបន្ត។ ការតាមដាន ត្រួតពិនិត្យ អាចប្រាប់ថាការអនុវត្តមិនគ្រប់គ្រាន់នៅដំណាក់កាលដំបូង តាមរយៈអនុសាសន៍ដែលជាដំណោះស្រាយក្នុងការតាមដានដំបូងនេះ អាចជំរុញការអនុវត្តបន្តបន្ទាប់ឱ្យកាន់តែប្រសើរឡើង។

### ២.២.៩. ក្រមសីលធម៌ និងសុចរិតភាព

ដើម្បីធានាបាននូវភាពជឿជាក់ និងអត្ថប្រយោជន៍ ប្រព័ន្ធ ត.ត.វ. មិនត្រូវលម្អៀង និងត្រូវអនុលោមតាមស្តង់ដាណាមួយ (ជាតិ តំបន់ ឬអន្តរជាតិ) ក្នុង ការប្រមូលទិន្នន័យណាដែលមានគុណភាព និងការវិភាគទិន្នន័យ។ ត.ត.វ. ត្រូវរាយការណ៍ដោយឯករាជ្យភាព។ អ្នកវាយតម្លៃគួរតែត្រូវបានគោរព និងជំរុញក្នុងការត្រួតពិនិត្យប្រព័ន្ធ ត.ត.វ. ឱ្យបានត្រឹមត្រូវផងដែរ។

## ២.៣. ធាតុសំខាន់ៗសម្រាប់រៀបចំប្រព័ន្ធតួនាទី ភារកិច្ចរបស់ ត.ត.វ.[21]

### ២.៣.១. ការគ្រប់គ្រង

ត្រូវមានអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រព័ន្ធដោយមានមធ្យោបាយត្រឹមត្រូវ និងកន្លែងរក្សាប្រព័ន្ធ ដើម្បីធានានិរន្តរភាពនៃប្រព័ន្ធ។ ការប្រមូលទិន្នន័យអាចរាំងស្ទះដោយទិន្នន័យជាន់គ្នា ត្រួតស៊ីគ្នាពីក្រសួង ស្ថាប័នផ្សេងៗ និង

[21] (Kusek and Rist, 2004)

ភ្នាក់ងារជាតិស្ថិតិ។ កាលបរិច្ឆេទនៃការប្រមូលទិន្នន័យត្រូវដាក់លាក់ទៅតាមការកំណត់ណាមួយ បើទិន្នន័យដែលទទួលបានយឺត នោះវានឹងជះឥទ្ធិពលដល់ការសម្រេចចិត្ត និងនាំឱ្យអ្នកប្រើប្រាស់ទិន្នន័យមិនជឿជាក់ពីប្រភពរបស់ទិន្នន័យ។

### ២.៣.២. ការថែទាំប្រព័ន្ធ

ការថែទាំប្រព័ន្ធ ត.ត.វ. គឺជាការចាំបាច់ដើម្បីការពារប្រព័ន្ធពីការពុកផុយ និងការដួលរលំ។ យើងត្រូវដឹងថានរណាទទួលបន្ទុកប្រមូលទិន្នន័យ ព័ត៌មានណាដែលត្រូវប្រមូល ត្រូវប្រមូលនៅពេលណា និងត្រូវដឹងប្រាកដថាតើព័ត៌មានត្រូវរត់ជួរដេក ឬជួរឈរនៅក្នុងប្រព័ន្ធ។ ប្រព័ន្ធតាមដាន ក៏ដូចជាប្រព័ន្ធព័ត៌មានរបស់រដ្ឋាភិបាលផ្សេងដទៃទៀតដែរ ដែលត្រូវតែបន្តគ្រប់គ្រង។

### ២.៣.៣. ភាពជឿជាក់

ភាពជឿជាក់មានសារៈសំខាន់ចំពោះប្រព័ន្ធតាមដាន ត្រួតពិនិត្យដែរ។ ទិន្នន័យដែលត្រឹមត្រូវ និងអាចទុកចិត្តបានជួយធានានូវភាពជឿជាក់នៃប្រព័ន្ធ។ ដើម្បីជឿជាក់បាន ប្រព័ន្ធត្រូវតែអាចរាយការណ៍បានគ្រប់ទិន្នន័យ ទាំងល្អ និងអាក្រក់។ ប្រសិនបើព័ត៌មានមិនល្អ ឬព័ត៌មានបង្ហាញពីបរាជ័យក្នុងការសម្រេចនូវលទ្ធផល និងគោលដៅដែលចង់បានមិនត្រូវបានរាយការណ៍ដោយចេតនាណាមួយ ដូច្នេះប្រព័ន្ធនឹងមិនអាចជឿទុកចិត្តបានឡើយ។ ដើម្បីគ្រប់គ្រង ថែរក្សា និងបង្កើនទំនុកចិត្ត យើងត្រូវការផែនការ ត.ត.វ.។

ប្រសិនបើប្រព័ន្ធ ត.ត.វ. មិនត្រូវបានគ្រប់គ្រងឱ្យល្អ នោះប្រព័ន្ធនឹងមានបញ្ហា។ ប្រព័ន្ធ ត.ត.វ. ក៏ដូចជាប្រព័ន្ធផ្សេងទៀតដែរ វាត្រូវការការកសាងជាប្រចាំ រៀបចំថ្មី និងពង្រឹងតាមរយៈការគ្រប់គ្រងល្អ។ ប្រព័ន្ធនេះតម្រូវឱ្យបង្កើតប្រាក់លើកទឹកចិត្តដ៏ត្រឹមត្រូវ ផ្តល់នូវហិរញ្ញវត្ថុ ធនធានមនុស្ស ធនធានបច្ចេកទេសគ្រប់គ្រាន់សម្រាប់អង្គភាព ជាពិសេសអ្នកគ្រប់គ្រង និងបុគ្គលិកដើម្បីអនុវត្តតួនាទី ត.ត.វ.។ គួរកំណត់ការទទួលខុសរបស់បុគ្គល និងអង្គភាពឱ្យបានច្បាស់លាស់

ដើម្បីសម្រេចកិច្ចការធំក្នុងការបង្កើតសកម្មភាពឱ្យសម្រេចនូវលទ្ធផល។ ការថែទាំប្រព័ន្ធបានល្អ គួរពិចារណាពីការគ្រប់គ្រង និងបច្ចេកវិទ្យាឈានមុខ។ ប្រព័ន្ធដំណើរការ និងបច្ចេកវិទ្យា ប្រហែលជាត្រូវធ្វើបច្ចុប្បន្នភាព និងទំនើបកម្ម។ អ្នកអនុវត្តគួរទទួលបាននូវការហ្វឹកហាត់ជាប្រចាំដើម្បីរក្សាបច្ចុប្បន្នភាពនៃជំនាញ។

## ២.៤. ផែនការកសាងប្រព័ន្ធ ត.ត.វ.

ផែនការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. គឺជាឯកសារដែលជួយតាមដាន និងវាយតម្លៃលទ្ធផលនៃអន្តរកម្មក្នុងរយៈពេលអនុវត្តគម្រោង ឬគោលនយោបាយផ្សេងៗ។ ផែនការនេះគឺជាឯកសាររស់ ដែលគួរតែធ្វើបច្ចុប្បន្នភាពតាមភាពបត់បែន និងបរិការណ៍ចាំបាច់ណាមួយ។ ផែនការតាមដាន ត្រួតពិនិត្យកម្មវិធីជាក់លាក់មួយ គួរតែមានទម្រង់មូលដ្ឋាន និងបញ្ចូលធាតុសំខាន់ៗ ដូចៗគ្នានៅក្នុងដំណើរការរៀបចំបង្កើតកម្មវិធីដូចជា៖ តក្កភាពគំរូ/ក្របខ័ណ្ឌតក្កភាព (logical model ឬ logical framework) ទ្រឹស្តីផ្លាស់ប្តូរ (theory of change) និងសូចនាករដែលបានបង្កើតជាមួយធាតុចូលដោយក្រសួង ស្ថាប័ន ម្ចាស់ជំនួយ ឬតួអង្គពាក់ព័ន្ធ[22]។

### ២.៤.១. អ្វីទៅជាផែនការ ត.ត.វ.

ផែនការ ត.ត.វ. គឺកសាងឡើងដើម្បីគាំទ្រអ្នកអនុវត្តប្រព័ន្ធ ឱ្យដឹកនាំអនុវត្តផែនការសម្រេចលទ្ធផលដែលបានគ្រោង និងជាមូលដ្ឋានសម្រាប់ថ្នាក់ដឹកនាំ អ្នកគ្រប់គ្រងគម្រោង ឬអ្នកធ្វើគោលនយោបាយនានាសម្រេចចិត្ត។

---

22 https://www.thecompassforsbc.org/how-to-guides/how-develop-monitoring-and-evaluation-plan, retrieved on 21 Dec, 2021 at 11:25 A.M.

### ២.៤.២. ហេតុអ្វីបានជាត្រូវបង្កើតផែនការ ត.ត.វ.

មុនពេលចាប់ផ្តើមសកម្មភាពតាមដានណាមួយ គួរតែបង្កើតផែនការ ត.ត.វ. ឱ្យច្បាស់លាស់មួយ ព្រោះវាមានសារៈសំខាន់ណាស់ និងមានភាពងាយស្រួលក្នុងការស្វែងរកចម្លើយដែលយើងត្រូវការ។ ផែនការនេះជួយអ្នកអនុវត្តមើលលើកម្មវិធីសម្រេចចិត្តទៅលើប្រភេទទិន្នន័យ និងវិធីសាស្ត្រដែលត្រូវប្រមូល និងវិភាគទិន្នន័យ និងចែករំលែកលទ្ធផលទៅកាន់ម្ចាស់ជំនួយ និងអ្នកអនុវត្តគម្រោងគ្រប់កម្រិតដើម្បីធ្វើឱ្យគម្រោងប្រសើរឡើង។ ផែនការ ត.ត.វ. នឹងជួយធ្វើឱ្យទិន្នន័យដែលបានពីលទ្ធផលចុងក្រោយរបស់កម្មវិធី អាចយកទៅសរសេររបាយការណ៍ផ្សេងៗ ឬប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

## ២.៥. ធាតុសំខាន់នៃផែនការកសាងប្រព័ន្ធ ត.ត.វ.

### ២.៥.១. បរិបទ និងគោលបំណង

ការចូលរួមនៃប្រព័ន្ធ ត.ត.វ. នៅក្នុងបរិបទនៃគម្រោង ឬកម្មវិធី គឺដើម្បីបង្កើតទំនុកចិត្តឱ្យសម្រេចបានតាមការគ្រោងទុក។ ប្រព័ន្ធ ត.ត.វ. នឹងគាំទ្រការគ្រប់គ្រង និងឆ្លើយតបចំពោះតម្រូវការនៃការរាយការណ៍ និងព័ត៌មានពីដៃគូ ឬអ្នកប្រើប្រាស់ផ្សេងៗ។

**រំហូរនៃប្រព័ន្ធមានធាតុដូចតទៅ៖**

- ○ គោលបំណងតាមឋានានុក្រម
- ○ ក្របខ័ណ្ឌតក្កភាព ឬក្របខ័ណ្ឌតក្កភាពអន្តរាគមន៍ ឬទ្រឹស្តីផ្លាស់ប្តូរ
- ○ តារាងម៉ាទ្រីសសម្រាប់ ត.ត.វ. (ដោយផ្អែកលើផែនការ ត.ត.វ.)
- ➢ ការប្រមូលទិន្នន័យ
- ○ ទិន្នន័យបែបបរិមាណវិស័យ
- ○ ទិន្នន័យបែបគុណវិស័យ
- ○ ការគ្រប់គ្រងទិន្នន័យ(ពិភាក្សាពីលទ្ធផល) និងការសម្រេចចិត្តលើការផ្លាស់ប្តូរ
- ➢ សកម្មភាពគាំទ្ររំហូរនៃប្រព័ន្ធ

- ការវិភាគ និងសង្ខេបនៃសិក្ខាសាលា និងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ
- ប្រជុំបុគ្គលិក
- សិក្ខាសាលាជាមួយភាគីពាក់ព័ន្ធ
- ការពិនិត្យឡើងវិញទៅលើគម្រោងប្រចាំឆ្នាំ
- ប្រជុំតាមក្រុមតូចៗ

### ២.៥.២. វិធីសាស្ត្រ និងក្របខ័ណ្ឌក្រសួង ស្ថាប័ន មន្ទីរ

វិធីសាស្ត្រ និងក្របខ័ណ្ឌក្រសួង ស្ថាប័ន មន្ទីរមានដូចតទៅ៖

- ដំណើរការនៃការរៀបចំផែនការ ត.ត.វ. របស់ក្រសួង ស្ថាប័ន មន្ទីរ
- ការពិពណ៌នាពីក្របខ័ណ្ឌស្ថាប័នសម្រាប់ ត.ត.វ.(ថាតើអ្នកអនុវត្ត នឹងចូលរួមដោយមធ្យោបាយណា)
- ការតាក់តែង ឬការបង្កើតផ្នែក ត.ត.វ. រចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន មន្ទីរ
- ការកំណត់តួនាទី និងការទទួលខុសត្រូវនៃផ្នែក ត.ត.វ. (គួរមានជាផ្នែក ឬការិយាល័យ ឬនាយកដ្ឋាន)
- វំហូរព័ត៌មាន ត.ត.វ. (បង្កើតតារាងវំហូរនៃ ត.ត.វ. ដោយយកតាមវំហូររបាយការណ៍)

### ២.៥.៣. កែសម្រួលក្របខ័ណ្ឌតក្កភាព (Logical Framework) និងសូចនាករអនុវត្តន៍

ព័ត៌មាននៃក្របខ័ណ្ឌតក្កភាព និងសូចនាករការអនុវត្តន៍មានដូចតទៅ៖

- ការផ្ទៀងផ្ទាត់ភាពច្បាស់លាស់នៃគោលបំណង
- ការកំណត់ព័ត៌មានដែលត្រូវការ និងការចាប់អារម្មណ៍របស់តួអង្គពាក់ព័ន្ធ
- ការកំណត់ និងសុពលភាពរបស់សូចនាករអនុវត្តន៍ និងចំណុចដៅ (លទ្ធភាពហិរញ្ញវត្ថុ និងបច្ចេកទេស)
- វាយតម្លៃផលជះ
- ការបង្កើតសម្មតិកម្ម និងសំណួរសម្រាប់វាយតម្លៃ

*កំណត់សម្គាល់៖* រៀបចំក្របខ័ណ្ឌតក្កភាព (មាននៅក្នុងជំពូកទី៣ ផ្នែកទី៤)

### ២.៥.៤. ប្រព័ន្ធព័ត៌មាន ត.ត.វ. និងរបាយការណ៍

ចំណុចខាងក្រោមមានសារៈសំខាន់ក្នុងការរៀបចំប្រព័ន្ធ ត.ត.វ. និងរបាយការណ៍៖

- គោលបំណងនៃប្រព័ន្ធ ត.ត.វ.
- របៀបរៀបចំប្រមូលទិន្នន័យ និងការសំយោគទិន្នន័យ
    - សម្រាប់សូចនាករនីមួយៗ៖ នរណា អ្វី មធ្យោបាយណា ពេលណា ឯណា?
    - ព័ត៌មានបង្កើតផែនការការងារ៖ នរណា អ្វី ពេលណា ទៅកាន់ នរណា ហេតុអ្វី?
    - ដំណើរការនៃប្រព័ន្ធ (ដោយកុំព្យូទ័រ ឬសៀវភៅណែនាំ)៖ នរណា ឬទៅនរណា សម្រាប់ទិន្នន័យប្រភេទអ្វី?
    - ការពិពណ៌នានៃតម្រូវការតម្កល់ព័ត៌មាន
    - ផែនការទិន្នន័យទទួលស្គាល់គុណភាព

### ២.៥.៥. ផែនការសកម្មភាព ត.ត.វ.

កំណត់វិធីសាស្ត្រដែលត្រូវប្រើសម្រាប់៖

- ការពិនិត្យតាមដានការអនុវត្ត(ធាតុចូល សកម្មភាព ធាតុចេញ)
- ការពិនិត្យតាមដានលទ្ធផល(លទ្ធផល និងផលជះរយៈពេលវែង)
- ការវាយតម្លៃ
    - ការស្ទង់មតិដែលបានលើកឡើង
    - ការចូលរួមវាយតម្លៃប្រចាំឆ្នាំ(ស្ទង់មតិពីការពេញចិត្ត)
    - ការវាយតម្លៃពាក់កណ្ដាល និងបញ្ចប់
    - វិធីសាស្ត្រដែលអាចអនុវត្តបាន (ទាក់ទងនឹងបច្ចេកវិទ្យា និង ធនធានមនុស្សដែលមាន)

- ○ ផែនការការងារ ត.ត.វ. (ត្រូវបង្កើតតារាងការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ)

### ២.៥.៦. សមត្ថភាព និងលក្ខខណ្ឌចាំបាច់ក្នុងការអនុវត្ត ត.ត.វ.

- ធនធានមនុស្សដែលត្រូវការ៖
  - ○ ចំនួន សមត្ថភាព និងការទទួលខុសត្រូវ
  - ○ ការលើកទឹកចិត្តសម្រាប់ដៃគូផ្សេងៗ
  - ○ តម្រូវការកសាងសមត្ថភាពសម្រាប់ដៃគូ និងបុគ្គលិក
- ធនធានដទៃទៀត
  - ○ សម្ភារៈ
  - ○ ជំនួយបច្ចេកទេស
- ផែនការកសាងសមត្ថភាព ត.ត.វ.

### ២.៥.៧. ថវិកាសម្រាប់ ត.ត.វ.

- សង្ខេបថវិកាលម្អិត (តារាងសង្ខេបថវិកា)

**ឧបសម្ព័ន្ធ៖**

- ក្របខ័ណ្ឌតក្កភាព(ច្បាប់ដើម និងបានកែសម្រួល)
- ក្របខ័ណ្ឌវាស់វែងការអនុវត្ត
- តារាង Excel សម្រាប់ប្រមូលទិន្នន័យ
- ផែនការលម្អិតនៃរបាយការណ៍ដែលត្រូវរៀបចំ
- កម្រងសំណួរដើម្បីស្ទង់មតិមូលដ្ឋាន
- ការពិពណ៌នាអំពីបុគ្គលិក
- លក្ខខណ្ឌយោងសម្រាប់ជំនួយបច្ចេកទេស
- តារាងថវិកាលម្អិតសម្រាប់ ត.ត.វ.

**កំណត់ចំណាំ៖** ផែនការ ត.ត.វ. ជារឿយៗត្រូវបានបំពេញបន្ថែមដោយសៀវភៅណែនាំប្រតិបត្តិការអនុវត្ត ត.ត.វ. (ឬគោលការណ៍ណែនាំ) មានគោលដៅចំពោះអ្នកពាក់ព័ន្ធដោយផ្ទាល់នៅក្នុងប្រព័ន្ធ ត.ត.វ.។

## ២.៦. ដំណាក់កាល និងធាតុសំខាន់ដែលមាននៅក្នុងប្រព័ន្ធ ត.ត.វ.[23]

| ដំណាក់កាលទី១៖ខ្លឹមសារទូទៅ | ដំណាក់កាលទី២៖ការជ្រើសរើសព័ត៌មាន | ដំណាក់កាលទី៣៖ការប្រមូលព័ត៌មាន | ដំណាក់កាលទី៤៖ការវិភាគទិន្នន័យ | ដំណាក់កាលទី៥៖ការប្រើប្រាស់ព័ត៌មាន | ដំណាក់កាលទី៦៖ការវាយតម្លៃ | ដំណាក់កាលទី៧៖និរន្តរភាពប្រព័ន្ធ |
|---|---|---|---|---|---|---|
| - គោលបំណង<br>- គោលការណ៍ស្នូល<br>- គោលការណ៍ដឹកនាំការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ | - ផែនការយុទ្ធសាស្ត្រ<br>- ផែនការមេ ឬគោលនយោបាយ<br>- ក្របខ័ណ្ឌលទ្ធផល<br>- គោលបំណង និងកម្មវត្ថុ<br>- សូចនាករ<br>- ការរៀនសូត្រ ឬសំណួរវាយតម្លៃ<br>- ផែនការសកម្មភាព | - ឧបករណ៍ និងវិធីសាស្ត្រប្រមូលទិន្នន័យ<br>- ទម្រង់ប្រើប្រាស់ដើម្បីកត់ត្រាទិន្នន័យ<br>- មូលដ្ឋានដើម្បីវាយតម្លៃស្ថានភាពនៅពេលចាប់ផ្តើមគម្រោងឬកម្មវិធី<br>- ការប្រមូលទិន្នន័យជាប្រចាំ | - ការវិភាគទិន្នន័យមិនផ្លូវការជាប្រចាំ<br>- ការវិភាគជាផ្លូវការបែបគុណវិស័យឬបរិមាណវិស័យ<br>- ការរៀនសូត្រ និងការចែករំលែកបទពិសោធន៍ | - រាយការណ៍ជាប្រចាំ<br>- វិធីសាស្ត្រសម្រាប់ទំនាក់ទំនងព័ត៌មាន<br>- យន្តការដើម្បីជួយយកលទ្ធផលដែលបានមកពីការតាមដាន ត្រួតពិនិត្យ លើអ្នកសម្រេចចិត្ត | - ការវាយតម្លៃផ្លូវការ<br>- ការពិនិត្យឡើងវិញទាំងផ្លូវការ ឬមិនផ្លូវការ<br>- ការវាយតម្លៃផលជះ<br>- ការស្រាវជ្រាវ | - ប្រព័ន្ធព័ត៌មានវិទ្យា<br>- គ្រប់គ្រងទិន្នន័យ<br>- ថវិកាសម្រាប់កិច្ចការ M&E<br>- តួនាទី និងភារកិច្ចរបស់មន្ត្រីផ្នែក M&E<br>- ការកសាងសមត្ថភាពមន្ត្រី |

**តារាងទី៤៖** ដំណាក់កាល និងធាតុសំខាន់ដែលមាននៅក្នុងប្រព័ន្ធ ត.ត.វ.

[23] ( Simister, 2019 )

# ជំពូកទី៣៖ មធ្យោបាយ និងយន្តការ ត.ត.វ.
# ការអនុវត្តគោលនយោបាយ វ.ប.ន.

មធ្យោបាយ និងយន្តការ ត.ត.វ. គឺជាដំណើរការនៃការវាស់នូវវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ វ.ប.ន. តាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញការប្រើធនធាន ផលិតភាព ទំនើបកម្មនៃបច្ចេកវិទ្យាឱ្យមានប្រសិទ្ធភាព និងបង្កើននូវលទ្ធភាពប្រកួតប្រជែង។ យន្តការនេះបានកំណត់ និងប្រមូលផ្តុំធាតុចូល លទ្ធផលក្នុងឆ្នាំ សមិទ្ធផល គោលការណ៍ និងគោលដៅ តាមគោលនយោបាយ វ.ប.ន. ដែលបានដាក់ឱ្យអនុវត្តទៅតាមវដ្តនៃការរាយការណ៍រយៈពេលវែង មធ្យម បីឆ្នាំរំកិល ឬខ្លី រួមទាំងការច្នៃប្រឌិត និងការផ្តួចផ្តើម តាមគោលនយោបាយ ផែនការរបស់ស្ថាប័នពាក់ព័ន្ធនីមួយៗ។ ដើម្បីធ្វើ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. ត្រូវដំណើរការជា៤ផ្នែកដូចតទៅ៖

## ផ្នែកទី១៖ ផែនការសម្រាប់ ត.ត.វ.

## ៣.១. ផែនការសម្រាប់ ត.ត.វ.

### ៣.១.១. គោលការណ៍សំខាន់ៗសម្រាប់ធ្វើផែនការ

ផែនការការងារគឺជាការសង្ខេបនៃការងារ ឬកិច្ចការ ពេលវេលាកំណត់ និងការទទួលខុសត្រូវ ដែលត្រូវធ្វើក្នុងរយៈពេលមួយឆ្នាំ ឬច្រើនឆ្នាំ។ ផែនការនេះត្រូវបានគេប្រើជាឧបករណ៍តាមដាន ត្រួតពិនិត្យមួយ ដើម្បីប្រាកដថាការបង្កើតធាតុចេញ និងវឌ្ឍនភាពឆ្លើយតបទៅនឹងលទ្ធផលចុងក្រោយដែរឬទេ។ ផែនការសកម្មភាពពណ៌នាពីសកម្មភាពដែលនឹងត្រូវតាមដាន ក៏ដូចជាធាតុចេញ និងលទ្ធផលចុងក្រោយ។ ដំណើរការទូទៅនៃផែនការសកម្មភាព គឺជាឧបករណ៍សព្វគ្រប់ដែលអាចជួយអ្នកអនុវត្តបកប្រែព័ត៌មាន ឬគំនិតទៅជាការប្រតិបត្តិប្រចាំឆ្នាំជាមូលដ្ឋាន។ គ្រប់ផែនការ ឬគោលនយោបាយពាក់ព័ន្ធ វ.ប.ន. ត្រូវតែបញ្ចូលគ្នាប្រសិនបើចង់ធ្វើការ ត.ត.វ. ដោយកំណត់ក្របខ័ណ្ឌពេលវេលាជាក់លាក់ណាមួយ។ ផែនការទាំងនេះមានដូចតទៅ៖




*រូបភាពទី១៖ ផែនការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ*

នៅកម្រិតក្រសួង ផែនការការងារឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរឆ្ពោះទៅរកការគ្រប់គ្រងផ្អែកលើលទ្ធផល ដោយសង្កត់ធ្ងន់លើផែនការ ត.ត.វ.។ ដូច្នេះផែនការនេះត្រូវតែធ្វើឱ្យបានល្អិតល្អន់នៅគ្រប់ផ្នែក ឬកម្រិតដែលពាក់ព័ន្ធ។ នៅគ្រប់កម្រិតនៃតួអង្គពាក់ព័ន្ធ ទាំងក្នុងក្រសួង ស្ថាប័ន និងមន្ទីរ នឹងបញ្ចូលផែនការ ត.ត.វ. ទៅក្នុងប្រព័ន្ធដែលមានស្រាប់ និងរចនាសម្ព័ន្ធ តាមមធ្យោបាយផ្សេងៗ។ តម្រូវការផែនការអប្បរមាមានដូចតទៅ៖

- **ត្រូវកសាងផែនការ ត.ត.វ. ក្នុងពេលតែមួយ** ការវាយតម្លៃ គឺជាឧបករណ៍តាមដានដែលសំខាន់មួយ និងការតាមដាន ត្រួតពិនិត្យ គឺជា

ធាតុចេញដែលសំខាន់ដើម្បីវាយតម្លៃ។ ពីព្រោះពួកវាមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នា។

- **ចាប់យកលទ្ធផល (លទ្ធផល និងធាតុចេញ)** ព័ត៌មានដែលមានអត្ថប្រយោជន៍អំពីលទ្ធផល និងធាតុចេញត្រូវតែចាប់យក ដោយមិនគិតពីផ្នែកដែលត្រូវវិភាគ ប្រើប្រាស់ដោយផែនការ ត.ត.វ. (លទ្ធផល ធាតុចេញ គម្រោង សកម្មភាព កម្មវត្ថុ និងវិស័យ)។
- **កសាងផែនការវាយតម្លៃ** ផែនការវាយតម្លៃមួយមានលទ្ធផលសម្រាប់កម្មវិធីរបស់ស្ថាប័ន ឬប្រទេសក្នុងរយៈពេលណាមួយ។ គ្រប់ផ្នែក ឬការិយាល័យប្រតិបត្តិ រៀបចំផែនការវាយតម្លៃដែលចាំបាច់តាមផ្លូវច្បាប់ទៅតាមពេលវេលា និងវដ្តនៃកម្មវិធីរបស់គម្រោង ឬគោលនយោបាយផ្សេងៗរបស់ វ.ប.ន.។ ផែនការនេះគឺជាធាតុដ៏សំខាន់សម្រាប់វាយតម្លៃការអនុវត្ត។
- **ធ្វើផែនការតាមជម្រើសយុទ្ធសាស្ត្រ** ផែនការមិនមែនដូចជាការកំណត់កាលវិភាគទេ វាគឺជាការកំណត់មធ្យោបាយដែលល្អបំផុតដោយអាស្រ័យលើតម្រូវការ និងចរិតនៃអ្វីដែលនឹងត្រូវ ត.ត.វ. ។

**ផែនការការងារនៅកម្រិតក្រសួង**

ផែនការ ត.ត.វ. ចាប់ផ្តើមស្របពេលដែលបង្កើតកម្មវិធីរបស់គម្រោង ឬគោលនយោបាយណាមួយរបស់ វ.ប.ន.។ ផែនការត្រូវតែធ្វើបច្ចុប្បន្នភាពជាប្រចាំទៅតាមឆ្នាំ ឬពេលណាមួយតាមតម្រូវការចាំបាច់គ្រប់កម្រិត តាមផែនការដែលបានដាក់ និងអនុម័ត។ ផែនការទាំងនេះ ឈានទៅរកការសម្រេចចិត្តក្នុងការជ្រើសរើសយុទ្ធសាស្ត្រ ដើម្បីវាយតម្លៃ អ្វីមួយ នៅពេលណា និងហេតុអ្វីបានជាត្រូវវាយតម្លៃ។ ការវាយតម្លៃត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យកម្មវិធី និងគោលនយោបាយប្រសើរឡើង។ លទ្ធផលបានមកនឹងអាចជួយឱ្យផែនការគ្រប់កម្រិតប្រសើរឡើងទាំងផលវិជ្ជមាន និងអវិជ្ជមាន។ ដើម្បីកសាងផែនការទាំងនេះត្រូវពិនិត្យលើ៖

- ជម្រើសយុទ្ធសាស្ត្រសម្រាប់ ត.ត.វ. និងពណ៌នាពីការរៀបចំ។ កំណត់មធ្យោបាយទូទៅសម្រាប់ ត.ត.វ. ដែលនឹងត្រូវអនុវត្តដោយបង្ហាញពីលទ្ធផលដែលត្រូវវាយតម្លៃ ឬដំណើរការដែលត្រូវប្រើប្រាស់សម្រាប់ធ្វើ

ការសម្រេចចិត្ត និងបង្ហាញលទ្ធផលពីកម្មវិធី ឬគម្រោងដែលនឹងត្រូវតាមដាន និងត្រួតពិនិត្យជាទូទៅ។

- ពេលធ្វើផែនការវាយតម្លៃលទ្ធផល ត្រូវជ្រើសរើសលទ្ធផលច្បាស់លាស់ (លទ្ធផល ឬការផ្លាស់ប្តូរទៅរកការអភិវឌ្ឍ) ដើម្បីវាយតម្លៃ និងកំណត់ពេលវេលាសម្រាប់ការវាយតម្លៃ។
- ធ្វើផែនការសម្រាប់តាមដាន ត្រួតពិនិត្យលទ្ធផល ហើយបង្កើតប្រព័ន្ធសម្រាប់តាមដាន។ ការវាយតម្លៃវឌ្ឍនភាព ដើម្បីសម្រេចបាននូវលទ្ធផលត្រូវតែផ្អែកលើការប្រមូលទិន្នន័យជាប្រចាំ ដោយប្រើប្រាស់យន្តការ ឬបង្កើតក្រុមប្រឹក្សាយោបល់ទៅលើលទ្ធផល និងកំណត់ថាតើសូចនាករណា ឬទិន្នន័យណាដែលត្រូវប្រមូល ដោយពិភាក្សាផ្តោតទៅលើការតាមដានត្រួតពិនិត្យ។
- នៅពេលដែលផែនការទាំងនោះត្រូវបានអនុម័ត និងការអនុវត្តនៅកម្រិតក្រសួង ស្ថាប័នចាប់ផ្តើម ត្រូវរៀបចំផែនការតាមដាន ត្រួតពិនិត្យតាមឆ្នាំ ដោយពិនិត្យទៅលើវឌ្ឍនភាពនៃកម្មវិធី ឬគម្រោង ដើម្បីសម្រេចនូវលទ្ធផល។

### ៣.១.២. ផែនការសម្រាប់តាមដាន

ផែនការសម្រាប់តាមដាន ត្រួតពិនិត្យ ជាទូទៅកើតឡើងនៅកម្រិតក្រសួង ស្ថាប័ន នៅដំណាក់កាលបង្កើតកម្មវិធី ឬគម្រោងប្រចាំឆ្នាំ។ ផែនការសម្រាប់តាមដានត្រួតពិនិត្យ ផ្តោតលើគម្រោង កម្មវិធី ក៏ដូចជាលទ្ធផលដែលបានមកពីការផ្លាស់ប្តូរតាមរយៈការអនុវត្ត (លទ្ធផល)។ គម្រោង កម្មវិធី សកម្មភាពថ្មីៗដែលបានបង្កើតឡើង ឬចាប់ផ្តើមនៅវគ្គនៃកម្មវិធី។ ផែនការទាំងនេះត្រូវធ្វើឡើងដើម្បីតម្រូវក្របខ័ណ្ឌ ត.ត.វ. ដែលមានជាស្រេចទៅតាមកម្រិត។ នៅពេលធ្វើផែនការសម្រាប់ ត.ត.វ. វឌ្ឍនភាពឱ្យសម្រេចនូវលទ្ធផល (តាមដានលទ្ធផល) ត្រូវបានលើកទឹកចិត្តតាមមធ្យោបាយដូចតទៅ៖

- **វាយតម្លៃតម្រូវការ** វាយតម្លៃចរិតនៃលទ្ធផល កម្មវិធី និងគម្រោងដែលរំពឹងថាសម្រេចលទ្ធផល។

- **វាយតម្លៃការតាមដានជាប្រចាំ** វាយតម្លៃការតាមដានថ្មី ពិនិត្យឧបករណ៍តាមដាន ដែលប្រើប្រាស់នៅគ្រប់គម្រោង កម្មវិធី ដើម្បីសម្រេចលទ្ធផលគ្រោងទុក។
- **ពិនិត្យឡើងវិញពីឧបករណ៍ ឬទំហំនៃការតាមដាន ត្រួតពិនិត្យ** ស្វែងរកឧបករណ៍ ឬទំហំការងារដែលសម្រេចបាននូវកម្មវិធីឬគម្រោង។
- **សម្រប និង/ឬ បង្កើតយន្តការតាមដាន ត្រួតពិនិត្យ** យន្តការដែលបានប្រើប្រាស់គួរតែផ្តល់នូវការវិភាគសមម្សទៅលើលទ្ធផល និងបំពេញនូវចន្លោះខ្វះខាត រវាងព័ត៌មានដែលត្រូវការ និងព័ត៌មានដែលអាចប្រមូលបាន។

ផែនការខាងក្រោមនឹងផ្តល់ទិដ្ឋភាពទាំងមូលនៃទិន្នន័យដែលនឹងត្រូវប្រមូល និងវិធីសាស្ត្រក្នុងការប្រមូល ដោយផ្អែកលើការស្ទង់មតិ ឬវិធីសាស្ត្រប្រមូលទិន្នន័យផ្សេងៗដែលអាចតាក់តែងលម្អិត ឧទាហរណ៍៖ ការចូលរួមកិច្ចការតាមដានត្រួតពិនិត្យ ការពិភាក្សាជាក្រុមគោលដៅ។ល។ ផែនការតាមដាន ត្រួតពិនិត្យ ជួយឱ្យដឹងពីការប្រមូលទិន្នន័យជាន់គ្នាពីរដង ឬប្រើធនធានមិនត្រឹមត្រូវ។

**តារាងទី៥៖** តារាងផែនការសម្រាប់ការតាមដាន

| សូច-នាករ | បន្ទាត់មូល-ដ្ឋាន | ទិន្នន័យជាក់-លាក់ដែលត្រូវប្រមូល | វិធី-សាស្ត្រប្រមូលទិន្នន័យ | ការទទួលខុសត្រូវសម្រាប់ការប្រមូលទិន្នន័យ | ពេលវេលា | តម្លៃ | អ្នកប្រើ | ប្រើទិន្នន័យដើម្បីអ្វី |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

### ៣.១.៣. ផែនការសម្រាប់វាយតម្លៃ

ការវាយតម្លៃមានសារៈសំខាន់ខ្លាំងសម្រាប់សុពលភាពលទ្ធផល ការរៀនសូត្រ និងការសម្រេចចិត្ត។ នាយកដ្ឋាន ត.ត.វ.គ. រំពឹងទុកថានឹងដឹកនាំការវាយតម្លៃលទ្ធផលក្នុងចំនួនកំណត់ណាមួយនៅអំឡុងវដ្តនៃកម្មវិធី និងដើម្បីអភិវឌ្ឍផែនការវាយតម្លៃសម្រាប់កម្មវិធី គម្រោងវាយតម្លៃ ឬផែនការដែលទាក់ទងនឹង វ.ប.ន.។ ផែនការវាយតម្លៃ គឺភ្ជាប់ជាមួយនឹងវដ្តនៃកម្មវិធីរបស់គម្រោង ឬគោលនយោបាយ។ ផែនការវាយតម្លៃ គឺផ្អែកលើយុទ្ធសាស្ត្រ និងការសម្រេចចិត្តដែលបានជ្រើសរើសដោយថ្នាក់ដឹកនាំរបស់នាយកដ្ឋាន អគ្គនាយកដ្ឋាន រដ្ឋលេខាធិការទទួលបន្ទុក ឬរដ្ឋមន្ត្រី ថាតើត្រូវវាយតម្លៃអ្វី នៅពេលណា។ ផែនការត្រូវបានប្រើដើម្បីប្រាកដថាសកម្មភាពវាយតម្លៃ គឺស្ថិតនៅក្នុងផែនការតាមដាន និងត្រួតពិនិត្យ។ នៅពេលរៀបចំផែនការសម្រាប់ការវាយតម្លៃមួយ គឺចំបាច់ត្រូវគិតពីផែនការត្រឡប់ដោយពិនិត្យមើលលើកាលបរិច្ឆេទសម្រាប់ការវាយតម្លៃ ប៉ាន់ស្មានពីពេលវេលាដែលត្រូវការរៀបចំដឹកនាំការវាយតម្លៃនោះ។ ពេលរៀបចំផែនការតាមដានលទ្ធផល នាយកដ្ឋានបច្ចេកទេស គួរជ្រើសរើសលទ្ធផល និងកំណត់ចំនួនលទ្ធផលណាមួយដែលចាំបាច់ដើម្បីវាយតម្លៃ។ ការធ្វើផែនការវាយតម្លៃជាមុន គឺមានសារៈសំខាន់ណាស់ដើម្បីចរចាជាមួយក្រុមការងារវាយតម្លៃ និងអះអាងនូវអ្វីដែលនឹងត្រូវធ្វើការវាយតម្លៃ។ លក្ខខណ្ឌសម្រាប់ជ្រើសរើសលទ្ធផល ដើម្បីធ្វើការវាយតម្លៃមានដូចតទៅ៖

- **ព័ត៌មាននាំមុខ៖** ចាប់ផ្តើមប្រមូលឯកសារ និងព័ត៌មានជាមុនពីកន្លែងដែលត្រូវវាយតម្លៃ។
- **គោលបំណងនៃការជ្រើសរើសការវាយតម្លៃលទ្ធផល** គឺដើម្បីបំពេញតម្រូវការផ្សេងៗមួយចំនួនដូចជា៖ ការផ្តល់ព័ត៌មានដំបូងអំពីភាពត្រឹមត្រូវនៃយុទ្ធសាស្ត្រ ការកំណត់អត្តសញ្ញាណឧបសគ្គដែលប៉ះពាល់ដល់លទ្ធផល ការបង្ហាញពីការកែតម្រូវពាក់កណ្តាល ការប្រមូលបទពិសោធន៍ និងមេរៀនសម្រាប់ការកសាងនៅពេលក្រោយ ហើយត្រូវកំណត់ទំហំនៃសំណួរ។

○ **ដំណើរការនៃការធ្វើផែនការ៖** កំណត់ និងសម្រេចអ្នកដែលពាក់ព័ន្ធទៅនឹងផែនការវាយតម្លៃ និងមធ្យោបាយអនុវត្តន៍។

○ **កម្រិតនៃធនធាននាយកដ្ឋានបច្ចេកទេស ដែលតាមដានលទ្ធផល៖** ពេលជ្រើសរើសលទ្ធផលសម្រាប់វាយតម្លៃ ត្រូវពិនិត្យលើធនធានសំខាន់ៗ ដែលគាំទ្រដល់ការសម្រេចនូវគោលបំណង។ ចៀសវាងការជ្រើសរើសលទ្ធផលណា ដែលមានធនធានធម្មតាពេកនៅពីខាងក្រោយ។

○ **លទ្ធភាពនៃការធ្វើអន្តរាគមន៍ពេលអនាគត៖** ការវាយតម្លៃលទ្ធផល គឺជាមធ្យោបាយដ៏សំខាន់ក្នុងការបង្កើតអនុសាសន៍ណែនាំការងារពេលអនាគត។ នៅពេលជ្រើសរើសលទ្ធផលសម្រាប់វាយតម្លៃ សូមរកមើលផ្នែកមួយដែលនាយកដ្ឋានបច្ចេកទេសគាំទ្រ។

○ **ប្រមើលមើលពីលទ្ធផល៖** ការវាយតម្លៃអាចជួយការពារបញ្ហា និងផ្តល់ការគិតឯករាជ្យមួយលើបញ្ហា។ នៅពេលជ្រើសរើសលទ្ធផលសម្រាប់វាយតម្លៃ សូមរកមើលប្រភពដែលបង្កឱ្យមានបញ្ហា ឬកន្លែងដែលផលវិបាកទំនងជាកើតឡើងដោយសារតែលទ្ធផល គឺស្ថិតនៅក្នុងកន្លែងដែលរសើប។

○ **តម្រូវការសម្រាប់ការរៀនសូត្រ៖** ការវាយតម្លៃលទ្ធផល គឺមិនត្រឹមតែទាក់ទងប្រធានបទក្នុងផ្នែកមួយទេ តែក៏បង្ហាញពីមេរៀនទូទៅ សម្រាប់ប្រធានបទផ្សេងទៀតផងដែរ។ គួរពិនិត្យលទ្ធផលណាដែលអាចផ្តល់មេរៀនបានទូលំទូលាយ និងវិសាលភាពធំធេង។

○ **ពេលវេលា៖** នាយកដ្ឋានបច្ចេកទេសកំណត់ពេលវេលានៃការវាយតម្លៃ ដោយផ្អែកលើបន្ទុកការងារដែលរំពឹងទុកក្នុងឆ្នាំណាមួយ។ ត្រូវគិតពីទំហំការងារ និងពេលវេលា មុនជ្រើសរើសការវាយតម្លៃលទ្ធផល។

○ **ថវិកា៖** ស្មានពីតម្លៃនៃការវាយតម្លៃ និងធនធានដែលត្រូវការ ថាតើវាមានតុល្យការដែរឬទេ។

○ **វិធីសាស្ត្រ៖** ត្រូវជ្រើសរើសប្រភេទទិន្នន័យវាយតម្លៃដែលចាំបាច់ និងត្រូវគិតពីវិធីសាស្ត្រដែលសមស្របបំផុតសម្រាប់ការប្រមូលទិន្នន័យវាយតម្លៃ។

○ **ការចូលរួមវាយតម្លៃ៖** ត្រូវគិតឱ្យគ្រប់ជ្រុងជ្រោយថានរណាគួរចូលរួមក្នុងការវាយតម្លៃ តាមមធ្យោបាយណា និងគិតពីសមាជិកក្រុម និងសមត្ថភាពរបស់ពួកគាត់។

○ **ការព្រាងតួនាទីភារកិច្ចសម្រាប់ការសិក្សាវាយតម្លៃ៖** ត្រូវព្រាងតួនាទីភារកិច្ចដើម្បីសុំយោបល់ពីតួអង្គពាក់ព័ន្ធ ឬចាប់ផ្ដើមចូលរួមក្នុងដំណើរការព្រាងកាន់តែប្រសើរ។

### ៣.១.៤. ផែនការការងារគម្រោង

ផែនការការងារគម្រោង គឺជាឧបករណ៍មួយដែលត្រូវបានប្រើដើម្បីកំណត់គោលដៅសម្រាប់ការចែកចាយលទ្ធផល និងបង្កើតយុទ្ធសាស្ត្រសម្រាប់ការរួមចំណែកជាអប្បបរមានៃគម្រោង និងសកម្មភាពដែលពាក់ព័ន្ធឱ្យសម្រេចបាននូវគោលដៅ។ ដំណើរការរៀបចំផែនការការងារជួយកសាងការឯកភាពគ្នារវាងអ្នកគ្រប់គ្រងគម្រោង និងតួអង្គពាក់ព័ន្ធផ្សេងៗលើយុទ្ធសាស្ត្រដ៏ល្អបំផុតសម្រាប់ការបង្កើតលទ្ធផល។ ប្រសិនបើឯកភាពយកកម្មវិធីផ្អែកលើលទ្ធផលនៃការងារហើយនោះការពិនិត្យមើលឡើងវិញនូវផែនការការងារជាទៀងទាត់គឺជាការចាំបាច់។ ត្រូវផ្ដោតលើគោលដៅទូលំទូលាយសំខាន់ៗ ជាជាងផ្ដោតលើគោលដៅរបស់គម្រោង។ ផែនការការងារនេះបម្រើជាយន្តការមួយដើម្បីភ្ជាប់ធាតុចូល ថវិកា សកម្មភាព និងលទ្ធផល។ វិធីសាស្ត្រដែលបត់បែនបានកាន់តែច្រើនក្នុងការអនុវត្តគម្រោងត្រូវការជាចាំបាច់ ដើម្បីជួយសម្រួលការកែតម្រូវជាប្រចាំ។ អ្នកគ្រប់គ្រងគម្រោងប្រើផែនការការងារគម្រោងជាមូលដ្ឋានសម្រាប់តាមដាន ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង។ ផែនការការងារគម្រោងអាចជួយប្រធានគម្រោង និងតួអង្គពាក់ព័ន្ធផ្សេងៗយល់ព្រមលើលទ្ធផល និងប្រាកដថាលទ្ធផលទាំងនោះ ឆ្លើយតបទៅនឹងលទ្ធផល និងគោលដៅដែលបានគ្រោង។ អ្នកគ្រប់គ្រងគម្រោងគួររួមបញ្ចូលសកម្មភាព ត.ត.វ. សំខាន់ៗរបស់គម្រោងទៅក្នុងផែនការការងារ ជាពិសេសដោយកត់សម្គាល់ពីរបៀបផលិតទិន្នផល និងទិន្នន័យដែលត្រូវបានតាមដាន ត្រួតពិនិត្យ។ ផែនការក៏អាចរួមបញ្ចូលរបៀបកសាងផងដែរ។ ត្រូវមានការត្រួតពិនិត្យ ប្រមូលទិន្នន័យ និងព័ត៌មានជាក់លាក់ជាប្រចាំ ដូចជារាល់ការប្រជុំគ្រប់តួអង្គពាក់ព័ន្ធ។

## ផ្នែកទី២៖ ការតាមដាន ត្រួតពិនិត្យ

## ៣.២. ដំណើរការនៃការតាមដាន ត្រួតពិនិត្យ

ការតាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយ វ.ប.ន. គឺដើម្បីបង្កើនប្រសិទ្ធភាពនៃការងារ ដែលបង្កើតទំនាក់ទំនងស្អិតរមួតរវាងលទ្ធផល និងអន្តរាគមន៍ពីអតីត បច្ចុប្បន្ន និងអនាគត។ ការតាមដាន ត្រួតពិនិត្យ គឺជាការទទួលខុសត្រូវដែលសំខាន់បំផុតរបស់អ្នកគ្រប់គ្រងគោលនយោបាយ ឬគម្រោងក្នុងការតាមដាន ត្រួតពិនិត្យវឌ្ឍនភាពនៃសកម្មភាពរបស់គោលនយោបាយ និងគម្រោង ឬកម្មវិធីឱ្យសម្រេចលទ្ធផលដែលគ្រោងទុក ឬចង់បាន និងជ្រើសរើសមធ្យោបាយតាមដាន ត្រួតពិនិត្យផ្សេងៗដើម្បីអនុវត្ត។ ក្នុងផ្នែកនេះនឹងណែនាំពីការតាមដាន ត្រួតពិនិត្យលទ្ធផលដែលជោគជ័យបំផុត ដោយបូកបញ្ចូលរបាយការណ៍ ការវិភាគ និងវឌ្ឍនភាពផ្សេងៗដែលឈានទៅសម្រេចបាននូវលទ្ធផលនិងការចូលរួម។ ការតាមដាន ត្រួតពិនិត្យ គឺផ្អែកលើផែនការគ្រប់គ្រាន់ និងអាចដើរតួជាការវាយតម្លៃបឋមបាន។

### ៣.២.១. គោលការណ៍សំខាន់ៗសម្រាប់តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយ វ.ប.ន.

ការតាមដាន ត្រួតពិនិត្យដែលល្អ គឺជាការតាមដានជាប្រចាំជាមួយគ្រប់តួអង្គពាក់ព័ន្ធដើម្បីសម្រេចលទ្ធផល។ ការតាមដាន ត្រួតពិនិត្យ ផ្តល់ជាមូលដ្ឋានសម្រាប់របាយការណ៍វឌ្ឍនភាព លទ្ធផលប្រចាំឆ្នាំ និងការវាយតម្លៃ។ ការតាមដាន ត្រួតពិនិត្យដែលល្អ គឺមិនគ្រាន់តែបង្ហាញការបង្កើតរបាយការណ៍ ដែលពណ៌នាល្អ ហើយមិនឆ្លុះបញ្ចាំងការពិតនោះទេ ត្រូវមានឧបករណ៍ចម្រុះដែលបង្ហាញពីតុល្យភាពនៃការវិភាគរបាយការណ៍ ពិនិត្យឡើងវិញ សុពលភាព និងការចូលរួម។ គ្រប់ផ្នែកពាក់ព័ន្ធត្រូវរៀបចំឧបករណ៍ ទម្រង់ និងកាលវិភាគ ដែលនឹងផ្តល់ជាតុចូលជូនថ្នាក់ដឹកនាំដើម្បីគ្រប់គ្រងលទ្ធផល។

**ការដឹកនាំតាមដាន ត្រួតពិនិត្យ៖** គុណភាពលទ្ធផលនៃការស្រាវជ្រាវ ឬការវាស់វែង អាស្រ័យលើការដឹកនាំ ត.ត.វ. ។ គោលការណ៍សំខាន់នៃការតាមដានត្រួតពិនិត្យ មានដូចតទៅ៖

- ផ្ដោតលើលទ្ធផល និងការតាមដានជាប្រចាំ ដើម្បីប្រាកដថាសកម្មភាពដែលបានអនុវត្ត ឈានទៅសម្រេចបាននូវលទ្ធផលដែលគ្រោងទុក និងបានកត់ត្រានៅក្នុងរបាយការណ៍វឌ្ឍនភាព ដើម្បីផ្ដល់ជាអនុសាសន៍ និងតាមដានជាប្រចាំបន្តទៀត។ ដោយមានប្រព័ន្ធត្រួតពិនិត្យជាប្រចាំ (ប្រចាំខែ ឬរៀងរាល់បីខែតាមភាពចាំបាច់)។
- ផ្ដោតលើការកសាងគោលនយោបាយ ឬគម្រោងផ្សេងៗ ដែលភ្ជាប់ផែនការសកម្មភាពដោយបង្ហាញពីខ្សែច្រវាក់លទ្ធផល និងសកម្មភាពដែលគាំទ្រជាក់ស្ដែង។
- មន្ត្រីអនុវត្តពិនិត្យ ឬចុះផ្ទាល់ជាប្រចាំដោយផ្ដោតលើលទ្ធផល ការតាមដានដើម្បីផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពវឌ្ឍនភាព។ អ្នកគ្រប់គ្រងគោលនយោបាយ ឬគម្រោង ត្រូវធ្វើការប្រជុំជាប្រចាំ ដូចជាប្រជុំគ្រប់ភាគីអនុវត្តគោលនយោបាយ ឬគម្រោងជារៀងរាល់ ២សប្ដាហ៍ ១ខែ ១ត្រីមាស ឬ១ឆ្នាំម្ដងដើម្បីតាមដានពីវឌ្ឍនភាព បញ្ហាប្រឈម ភាពរាំងស្ទះ និងស្វែងរកដំណោះស្រាយឱ្យទាន់ពេលវេលា។
- វិភាគរបាយការណ៍ជាប្រចាំដូចជារបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆ្នាំ ឬពាក់កណ្ដាលអាណត្តិ។ របាយការណ៍ទាំងនោះរៀបចំដោយអ្នកគ្រប់គ្រងគម្រោង ឬគោលនយោបាយសម្រាប់រដ្ឋមន្ត្រី ក្រុមប្រឹក្សាជាតិ វ.ប.ន. និងតួអង្គពាក់ព័ន្ធផ្សេងៗ ក្រោមការវិភាគរបស់មន្ត្រី ត.ត.វ.គ.។
- បង្កើនយន្តការចូលរួមតាមដាន ត្រួតពិនិត្យគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីបញ្ជាក់ពីការប្រឹងប្រែង ភាពជាម្ចាស់លើការតាមដាន និងការផ្ដល់ព័ត៌មានត្រឡប់លើការអនុវត្តការងារ។
- ស្វែងរកមធ្យោបាយដើម្បីវាស់វែងវឌ្ឍនភាពនៃការអនុវត្ត ដោយផ្អែកលើប្រព័ន្ធវាយតម្លៃការអនុវត្ត ដោយបង្កើតសូចនាករ និងបន្ទាត់មូលដ្ឋានច្បាស់លាស់(ឧទាហរណ៍៖ ក្របខ័ណ្ឌ ត.ត.វ.)។

- ត្រូវជំរុញការតាមដាន ត្រួតពិនិត្យ ព្រោះលទ្ធផលដែលបានពីការវាយតម្លៃពីភាពពាក់ព័ន្ធ ការអនុវត្ត និងជោគជ័យនៃគោលនយោបាយ ឬគម្រោងផ្សេងៗរបស់ រ.ប.ន. នឹងមានសារៈសំខាន់សម្រាប់ថ្នាក់ដឹកនាំសម្រេចចិត្តក្នុងការកសាងគោលនយោបាយ ឬគម្រោងផ្សេងៗ និងស្វែងរកការគាំទ្រ។
- ផ្ដល់ការរៀនសូត្រ និងបទពិសោធន៍សម្រាប់អ្នកអនុវត្តគ្រប់កម្រិតក្រសួងស្ថាប័នតាមរយៈឧបករណ៍តាមដាន ការប្រើប្រាស់ ឬការកែលម្អយុទ្ធសាស្ត្រ និងការចៀសវាងនូវកំហុសដដែលៗ។

### ៣.២.២. ទំហំនៃការតាមដាន ត្រួតពិនិត្យ

ការតាមដាន ត្រួតពិនិត្យ មានគោលបំណងបញ្ជាក់ថាវឌ្ឍនភាពអាចឈានទៅសម្រេចលទ្ធផល។ ដោយប្រើប្រាស់ព័ត៌មានដែលបានមកពីការតាមដានត្រួតពិនិត្យ នាយកគម្រោង ឬថ្នាក់ដឹកនាំអនុវត្តគោលនយោបាយ វិភាគ ចាត់វិធានការទៅលើកម្មវិធី សកម្មភាពគាំទ្រ ដើម្បីសម្រេចនូវលទ្ធផលតាមយុទ្ធសាស្ត្រដែលបានអនុម័តដោយគាំទ្រតាមរយៈក្របខ័ណ្ឌលទ្ធផល។ រាល់ ត.ត.វ. គួរលើកបង្ហាញដូចតទៅ៖

- **វឌ្ឍនភាពដែលឈានទៅសម្រេចលទ្ធផល៖** វិភាគគ្រប់ជ្រុងជ្រោយដើម្បីស្វែងរកថាតើសម្រេចលទ្ធផលយ៉ាងដូចម្ដេច និងពេលណា។
- **កត្តាដែលចូលរួមក្នុងការសម្រេចនូវលទ្ធផល៖** តាមដានទៅលើបរិបទប្រទេសដូចជា សេដ្ឋកិច្ច សង្គម នយោបាយ និងបច្ច័យផ្សេងៗ ដែលនាំឱ្យសម្រេចលទ្ធផល។
- **យុទ្ធសាស្ត្រតួអង្គពាក់ព័ន្ធ៖** តម្រូវឱ្យតាក់តែងយុទ្ធសាស្ត្រតួអង្គពាក់ព័ន្ធព្រោះវាជួយឱ្យប្រាកដថាតួអង្គណាដែលព្រួយបារម្ភពីលទ្ធផល បញ្ហា និងតម្រូវការ។

ការតាមដាន ត្រួតពិនិត្យ មើលលើគម្រោងប្រតិបត្តិ ការវាស់វែង វឌ្ឍនភាព និងការគាំទ្រផ្សេងៗ ដើម្បីសម្រេចលទ្ធផល និងព័ត៌មានបឋមក្នុងការសម្រេចចិត្ត និងការចាត់វិធានការផ្សេងៗ។ *ត្រូវផ្ដល់ធនធានថវិកាគ្រប់គ្រាន់សម្រាប់ការតាមដាន ត្រួតពិនិត្យ។*

### ៣.២.៣. ការទទួលខុសត្រូវសម្រាប់ការតាមដាន ត្រួតពិនិត្យ

កម្រិតនៃការទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យដើម្បីឱ្យសម្រេចបាននូវលទ្ធផលខ្ពស់តាមកម្រិតទទួលខុសត្រូវដូចជា៖ ថ្នាក់ដឹកនាំជាន់ខ្ពស់ទទួលកម្រិតគោលបំណង ឬគោលដៅ ថ្នាក់អគ្គនាយកទទួលខុសត្រូវការអនុវត្តទូទៅ និងការបង្កើតចំណុចដៅ ថ្នាក់នាយកដ្ឋាន(នាយកគម្រោង) ទទួលបន្ទុកក្របខ័ណ្ឌលទ្ធផល និងលទ្ធផល ចំណែកឯអ្នកអនុវត្តផ្ទាល់ផ្តោតលើឯកសារនិងធាតុចេញ។

**តារាងទី៦៖** ការទទួលខុសត្រូវតាមកម្រិតសម្រាប់ការតាមដាន ត្រួតពិនិត្យ

| កម្រិត | អ្វី? | នរណា? | ពេលណា? | មធ្យោបាយណា? |
|---|---|---|---|---|
| ក្រសួង | ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ គោលនយោបាយ ផែនការមេ (គោលបំណង/ គោលដៅ) | (រដ្ឋមន្ត្រី/ រដ្ឋលេខាធិការ /អនុរដ្ឋលេខាធិការ) | វដ្តនៃការអនុវត្តគម្រោង (ចាប់ពីឆ្នាំ ២០២២) | ការតាមដានប្រចាំឆមាស/ឆ្នាំ/ រៀងរាល់បីឆ្នាំម្តង |
| អគ្គនាយកដ្ឋាន/ នាយកដ្ឋានថ្នាក់កណ្តាល | កម្មវិធី/គម្រោង (លទ្ធផលតាមឆ្នាំ/ចុងក្រោយ) | អគ្គនាយក/ ប្រធាននាយកដ្ឋាន | តាមតម្រូវការ | ការតាមដានជាប្រចាំ |
| មន្ទីរ | កម្មវិធី/គម្រោង (លទ្ធផលតាមឆ្នាំ/ធាតុចេញ/ ធាតុចូល) | ប្រធានមន្ទីរ | តាមតម្រូវការ | ការតាមដានជាប្រចាំ |

ថ្នាក់ដឹកនាំកំពូល (រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការទទួលបន្ទុកអនុវត្តគោលនយោបាយ) ពាក់ព័ន្ធនឹងការជ្រើសរើសជម្រើសយុទ្ធសាស្ត្រនៃយន្តការតាមដាន ត្រួតពិនិត្យ។ តួនាទីរបស់ថ្នាក់ដឹកនាំកំពូលត្រូវជានាថាកម្មវិធីដែលបង្កើត រួមចំណែកដល់ការសម្រេចបាននូវគោលបំណង ឬគោលដៅកម្មវិធីកម្រិតណា។ លទ្ធផលសម្រេចបានលុះត្រាតែមានការចូលរួមពីតួអង្គពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់ក្រសួង។ ថ្នាក់ដឹកនាំកំពូលដឹកនាំការសរសេររបាយការណ៍ប្រចាំឆ្នាំ និងដំណើរការពិនិត្យឡើងវិញប្រចាំឆ្នាំ ឬពាក់កណ្តាលអាណត្តិ បង្កើតការតស៊ូមតិ និងស្វែងរកការគាំទ្រ បង្កើតយុទ្ធសាស្ត្រ បង្កើនការតាមដាន ត្រួតពិនិត្យលទ្ធផល ជំរុញការរៀនសូត្រពីលទ្ធផលដែលអវិជ្ជមាន ឬភាពរាំងស្ទះ។ កំណត់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងលទ្ធផល និងកំណត់អាទិភាពក្នុងផែនការការងារ និងចម្រាញ់តួអង្គពាក់ព័ន្ធ។

ថ្នាក់អគ្គនាយកដ្ឋាន ឬនាយកដ្ឋាន ទទួលគ្រប់គ្រងកម្រិតកម្មវិធី ឬអនុកម្មវិធីតាមការចាត់តាំង។ នាយកកម្មវិធីទទួលខុសត្រូវការតាមដាន ត្រួតពិនិត្យទូទៅពីវឌ្ឍនភាព ដែលឈានសម្រេចលទ្ធផល(outcomes) និងធាតុចេញ (outputs)។ ត្រូវប្រាកដថាការតាមដាន ត្រួតពិនិត្យ និងរបាយការណ៍នៅគ្រប់កម្រិតកម្មវិធី និងពីប្រភពផ្សេងៗ គឺត្រូវដាក់បញ្ចូលគ្នាដើម្បីផ្តល់នូវព័ត៌មានឱ្យសម្រេចបាននូវលទ្ធផល (outcomes) ។ ផែនការតាមដានលទ្ធផលនឹងសម្រួលការងារនេះ។

មន្ទីរ (ប្រធានមន្ទីរពិនិត្យកម្រិតកម្មវិធី ឬអនុកម្មវិធី) គ្រប់គ្រងគម្រោង ឬកម្មវិធី វ.ប.ន. ជាទូទៅ គឺទទួលខុសត្រូវផ្តល់ធាតុចេញនៃការអនុវត្តគម្រោង ឬកម្មវិធីជាក់ស្តែង ការគ្រប់គ្រងធាតុចូល និងការគ្រប់គ្រងរដ្ឋបាលគម្រោង និងតាមដានត្រួតពិនិត្យការអនុវត្តការងារពីអ្នកម៉ៅការផ្សេងៗ(Contractors)។ អ្នកគ្រប់គ្រងគម្រោង ឬកម្មវិធី បង្កើតផែនការការងារ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ។ របាយការណ៍គម្រោងប្រចាំឆ្នាំ គឺបង្កើតឡើងដោយបុគ្គលិកគម្រោងដែលមានបទពិសោធន៍ជាច្រើនដោយផ្តោតលើធាតុចេញដើម្បីសម្រេចនូវលទ្ធផល និងដើម្បីផ្តល់ធាតុចូលដល់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ។

### ៣.២.៤. ការជ្រើសរើសឧបករណ៍ និងយន្តការ ដែលត្រឹមត្រូវ សម្រាប់តាមដាន ត្រួតពិនិត្យ

មធ្យោបាយ និងឧបករណ៍ដែលពណ៌នាអាចយកទៅប្រើប្រាស់ក្នុង គោលនយោបាយ គម្រោង កម្មវិធី លទ្ធផល និងសកម្មភាពដែលអាចតាមដាន ត្រួតពិនិត្យ។ ដោយផ្អែកលើក្របខ័ណ្ឌលទ្ធផល អ្នកគ្រប់គ្រងត្រូវតែកំណត់ការ បញ្ចូលគ្នានៃឧបករណ៍តាមដាន ត្រួតពិនិត្យ និងវិធីសាស្ត្រ សម្រាប់គោលនយោបាយ គម្រោង កម្មវិធី ឬលទ្ធផលឱ្យបានត្រឹមត្រូវ។ ឧបករណ៍ទាំងនោះរួមមានៈ

- **របាយការណ៍ ឬការវិភាគៈ** របាយការណ៍ប្រចាំខែ ត្រីមាស ប្រចាំឆ្នាំ របាយការណ៍វឌ្ឍនភាព ផែនការការងារ របាយការណ៍អនុវត្តគម្រោង ឬ កម្មវិធី និងរបាយការណ៍អនុវត្តផ្សេងៗដែលបញ្ចូលគ្នា
- **សុពលភាពៈ** (ពិនិត្យលើឯកសារដែលមានស្រាប់ ការអង្កេត និងបទសម្ភាសន៍)
- **ការចូលរួមៈ** (ការប្រជុំក្រុមតូច ឬក្រុមធំ ការពិភាក្សាទៅលើលទ្ធផលរួម ការប្រជុំជាមួយតួអង្គពាក់ព័ន្ធ)

#### ៣.២.៤.១ ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺជាដំណើរការប្រមូលដោយប្រើវិធីសាស្ត្រផ្សេងៗ ដោយមានឧបករណ៍ជាក់លាក់ណាមួយ។ ក្នុងការប្រមូលទិន្នន័យមានវិធីសាស្ត្រ ចំនួន ៣ ដែលគេនិយមប្រើដូចតទៅៈ

**ក. ពិនិត្យឯកសារដែលមានស្រាប់ៈ** ការពិនិត្យឯកសារដែលមានស្រាប់ អាចហៅបានថាជាការពិនិត្យលើឯកសារ ឬប្រភពផ្សេងៗដែលបានបោះពុម្ពរួចជា ស្រេច។ វាបង្កើតមូលដ្ឋានព័ត៌មានដំបូងសម្រាប់ការកសាងគោលនយោបាយ ឬគម្រោង និងអ្នកអាចសន្សំពេលវេលាច្រើនក្នុងការស្វែងរកទិន្នន័យដែលមានរួច ជាស្រេច។ ឧទាហរណ៍ដូចជារបាយការណ៍គោលនយោបាយ ប្រជុំគោលនយោបាយ ឬគម្រោង សំណើស្នើគោលនយោបាយ ឬសុំគម្រោងច្បាប់ដើមក្នុងវិស័យ វ.ប.ន. ។ល។

**ខ. ការអង្កេត៖** ដោយអង្កេតផ្ទាល់ជាប្រព័ន្ធទៅលើវត្ថុ ព្រឹត្តិការណ៍ មនុស្ស និងកត់ត្រានូវអ្វីដែលបានឃើញ។ ការអង្កេតដោយផ្ទាល់ គឺតែងតែពាក់ព័ន្ធនៅពេលដែលធ្វើការវាយតម្លៃ។ ការអង្កេតជាមធ្យោបាយដ៏ល្អសម្រាប់ផ្ទៀងផ្ទាត់ចម្លើយ ដែលអ្នកទទួលបានពីកិច្ចសម្ភាសន៍ និងការពិភាក្សាជាក្រុមតូច ឬក្រុមធំ និងការប្រជុំផ្សេងៗ។ ការអង្កេតមានសារៈសំខាន់ណាស់ដោយប្រើប្រាស់តារាងត្រួតពិនិត្យ ដើម្បីធ្វើការអង្កេតជាប្រព័ន្ធ ដូច្នេះលទ្ធផលអាចប្រៀបធៀបជាមួយគ្នាបាន។ វិធីសាស្ត្រ និងឧបករណ៍ដែលអាចប្រើប្រាស់អង្កេតមានដូចជា៖ ការវាស់វែង ការកត់ត្រា និងសូចនាករផ្សេងទៀតដែលបានកំណត់ក្នុងតារាងដើម្បីអង្កេត។

**គ. បទសម្ភាសន៍៖** ការធ្វើសម្ភាសន៍ គឺជាឧបករណ៍ដ៏សំខាន់មួយដែលត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ។ ការសម្ភាសអាចធ្វើតាមការរៀបចំ (very structured សំណួរទាំងឡាយបានរៀបចំ និងមានចម្លើយខ្លះរួចជាស្រេចដើម្បីជ្រើសរើស និងមិនចាកឆ្ងាយពីកម្រងសំណួរឡើយ) ឬមិនមានការរៀបចំ (unstructured) ដោយការសួរសំណួរ និងសម្រេចអ្វីដែលនឹងសួរបន្ទាប់ដោយផ្អែកលើចម្លើយ ឬសួរប្រដេញដើម្បីរកចម្លើយបន្ថែម។ ការធ្វើសម្ភាសន៍មាន៤ប្រភេទ ដូចតទៅ៖

**១. ការសម្ភាសបុគ្គល៖** វិធីសាស្ត្រនេះត្រូវបានគេប្រើដើម្បីប្រមូលព័ត៌មានជាក់លាក់។ ធ្វើការសម្ភាសបុគ្គលម្នាក់ ពីចំនួនប្រជាជនដែលបានជ្រើសរើសសម្រាប់គោលបំណងតាមដាន។ ការធ្វើសម្ភាសន៍បុគ្គលម្នាក់ៗគឺស័ក្តិសមដើម្បីប្រមូលព័ត៌មានអំពីប្រធានបទរសើប ឬប្រធានបទដែលចម្រូងចម្រាស ឬកិច្ចការមិនត្រូវគ្នាណាមួយ។

**២. ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ ឬអ្នកឯកទេស៖** អ្នកផ្តល់ព័ត៌មានសំខាន់ម្នាក់ គឺជាមនុស្សដែលមានចំណេះដឹងឯកទេសពិសេសអំពីប្រធានបទ ដែលយើងនឹងត្រូវការព័ត៌មានដើម្បីតាមដាន ត្រួតពិនិត្យ។

**៣. ការសម្ភាសជាក្រុម៖** ការសម្ភាសជាក្រុមត្រូវបានរៀបចំដើម្បីទទួលព័ត៌មានពីគ្រប់ក្រុម ឬកម្រិត។ កិច្ចការនេះមានអត្ថប្រយោជន៍ក្នុងការទទួលបានព័ត៌មានច្រើន ហើយអាចផ្ទៀងផ្ទាត់ភ្លាមៗ ព្រោះពួកគេអាចកែតម្រូវគ្នាទៅវិញទៅមកបាន។ ការសម្ភាសនេះ មិនអាចត្រូវបានប្រើប្រាស់ដើម្បីប្រមូលព័ត៌មានរសើប

ហើយប្រើពេល និងកម្លាំងច្រើនដើម្បីរៀបចំទេ។ ការសម្ភាសនេះត្រូវការអ្នកសម្របសម្រួលដើម្បីដឹកនាំការពិភាក្សា។ នៅពេលដែលក្រុមមានគ្នាលើសពី ២០ នាក់ឡើងទៅ ត្រូវបំបែកជាក្រុមតូចៗ។

៤. **ការពិភាក្សាជាក្រុមដែលផ្តោតលើប្រធានបទរួម៖** ត្រូវធ្វើឡើងដើម្បីពិភាក្សាប្រធានបទជាក់លាក់ទាំងឡាយដោយលម្អិតជាមួយក្រុមមនុស្សដែលមានចំណេះដឹង បទពិសោធន៍ និងមានការចាប់អារម្មណ៍ដូចៗគ្នា ហើយការសម្ភាសជាក្រុមនេះក៏ត្រូវការអ្នកសម្របសម្រួលផងដែរ។ ការពិភាក្សាជាក្រុមនេះ តម្រូវឱ្យមានចំនួនមនុស្សចន្លោះពី ៦ ទៅ ១២ នាក់ គឺល្អបំផុត។

### ៣.២.៤.២ បង្កើតទម្រង់ប្រមូលទិន្នន័យ

ត្រូវកសាងទម្រង់សម្រាប់កត់ត្រាទិន្នន័យដូចជា៖ របាយការណ៍វឌ្ឍនភាព តារាងផ្ទៀងផ្ទាត់ការអង្កេត តារាងទិន្នន័យកត់ត្រាការវាស់វែង កម្រងសំណួរសម្រាប់សម្ភាសបុគ្គលម្នាក់ៗ និងសម្ភាសក្រុមមនុស្ស។ ត្រូវពិភាក្សាជាច្រើនលើកច្រើនសាជាមួយតួអង្គពាក់ព័ន្ធលើទម្រង់សម្រាប់កត់ត្រាទិន្នន័យ ឬប្រមូលទិន្នន័យដោយចាប់ផ្តើមពីការរៀបចំសេចក្តីព្រាងរហូតដល់ការសាកល្បង និងអនុម័តឱ្យប្រើប្រាស់ដោយក្រសួង ស្ថាប័ន អ្នកដឹកនាំសម្របសម្រួលការអនុវត្តគោលនយោបាយ។ មិនត្រូវបង្កើតទម្រង់ដែលល្អសម្រាប់តែមួយពេលទេ ត្រូវពិនិត្យឱ្យបានវែងឆ្ងាយ។

- ឯកភាពលើប្រភេទទម្រង់ និងព័ត៌មានដែលត្រូវការ
- ពិនិត្យទម្រង់ដែលគេប្រើសម្រាប់វាយតម្លៃពីមុនៗដែលប្រហាក់ប្រហែលគ្នា ដើម្បីយកគំនិត ឬគំរូតាមសម្រាប់អនុវត្ត
- ធ្វើការជាក្រុមតូច ឬនាយកដ្ឋាន ឬមន្ទីរ ដើម្បីប្រមូលសំណួរ ទម្រង់ប្រមូលព័ត៌មាន និងរៀបចំសេចក្តីព្រាងទីមួយដើម្បីប្រមូលគំនិត និងសួរអ្នកដទៃដែលមានចំណេះដឹង ឬបទពិសោធន៍លើបញ្ហាដើម្បីទទួលបាននូវយោបល់កែលម្អបន្ថែម (អាចសួរនៅក្នុងក្រុម)
- កែលម្អសេចក្តីព្រាងទី១ ដោយផ្អែកលើយោបល់ដែលទទួលបាន នោះនឹងក្លាយជាសេចក្តីព្រាងទី២ រួចតេស្តសេចក្តីព្រាងទី២នេះជាមុន
- ពិនិត្យសេចក្តីព្រាងទី២ ឡើងវិញ និងរៀបចំសេចក្តីព្រាងចុងក្រោយ។

- *ឧទាហរណ៍៖ (តារាងប្រមូលទិន្នន័យផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០)*[24]

### ៣.២.៥. ការផ្តល់ ផ្សព្វផ្សាយ ឬប្រើប្រាស់ព័ត៌មានតាមដាន ត្រួតពិនិត្យ

ទិន្នន័យដែលមិនទាន់វិភាគ និងព័ត៌មាន គឺជាទូទៅមិនគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋានសម្រេចចិត្តទេ។ ព័ត៌មានគឺជាការបូកបញ្ចូលគ្នានូវទិន្នន័យចាប់ពីពីរឡើងទៅ និងមានសេចក្តីអាចស្តាប់បាន។ ទិន្នន័យ ឬព័ត៌មានទាំងនោះត្រូវតែបានចងក្រង ប្រមូលផ្តុំ វិភាគ ផ្ទៀងផ្ទាត់ ប្រៀបធៀប និងដាក់ក្នុងបរិបទដែលមានប្រយោជន៍ក្នុងការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ និងសម្រាប់ការរៀនសូត្រ។ ផែនការតាមដាន ត្រួតពិនិត្យ អាចជាកស្តុតាងសម្រាប់ធ្វើការវិភាគ ប៉ុន្តែវាក៏មិនគ្រប់គ្រាន់ក្នុងការបញ្ចូលព័ត៌មាននៅក្នុងតារាង ឬក្រាហ្វដែរ។ ព័ត៌មានត្រូវតែបកស្រាយ (វិភាគ) រហូតដល់ពេញចិត្ត (វិភាគ) ដែលឈានទៅសម្រេចលទ្ធផលត្រួតពិនិត្យដើម្បីប្រាកដថាកិច្ចការនេះអាចត្រូវបានអនុវត្តល្អបំផុត។

## ផ្នែកទី៣៖ ការវាយតម្លៃ[25]

### ៣.៣.១. គោលបំណង និងគោលការណ៍នៃការវាយតម្លៃ

ការវាយតម្លៃ គឺដើម្បីពិនិត្យឡើងវិញនូវការអនុវត្តតាមឆ្នាំ ឬការបញ្ចប់គោលនយោបាយ ឬគម្រោង និងវាស់វែងថាតើកម្មវិធី ឬអនុកម្មវិធីមានហានិភ័យអ្វីខ្លះដែលមិនអាចសម្រេចគោលដៅ ឬគោលបំណងបាន។

**ដើម្បីធ្វើការវាយតម្លៃ គួរត្រូវគោរពតាមគោលការណ៍ដូចតទៅ៖**

- ការវាយតម្លៃគឺជាការរៀនសូត្រដែលគាំទ្រដល់ការគ្រប់គ្រងផ្អែកលើលទ្ធផល ហើយលទ្ធផលគួរត្រូវបានវាយតម្លៃពីភាពពាក់ព័ន្ធ និងមានប្រយោជន៍

---

[24] ពិនិត្យតារាងប្រមូលទិន្នន័យរបស់ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០

[25] គំនិតនៅក្នុងការសរសេរនេះគឺយកលំនាំតាម (IDEA, Evaluation Concepts and Process , 2021)

ហើយវាគួរត្រូវបានបង្ហាញក្នុងវិធីសាស្ត្រមួយយ៉ាងច្បាស់លាស់។ ការវាយតម្លៃមិនមែនជាសវនកម្មទេ។

- ការវាយតម្លៃមិនលម្អៀង ឯករាជ្យ ដើម្បីគាំទ្រការសម្រេចចិត្ត និងការគ្រប់គ្រង ហើយភាពជឿជាក់នៃការវាយតម្លៃ អាស្រ័យទៅលើជំនាញ និងឯករាជ្យភាពនៃអ្នកវាយតម្លៃ និងកម្រិតតម្លាភាពនៃដំណើរការវាយតម្លៃដោយអ្នកវាយតម្លៃត្រូវមានក្រមសីលធម៌ និងវិជ្ជាជីវៈ។ ម៉្យាងវិញទៀតត្រូវតែអនុញ្ញាតឱ្យស្ថាប័ន និងបុគ្គលដើម្បីផ្តល់ព័ត៌មានដោយសម្ងាត់ និងគួរផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ។
- តួអង្គពាក់ព័ន្ធ និងអ្នកទទួលផលគួរចូលរួមក្នុងដំណើរការនៃការវាយតម្លៃប្រសិនបើសមស្រប ឬអាចធ្វើទៅបាន។
- ការឯកភាពគ្នានៃវិធីសាស្ត្រវាយតម្លៃ គួរតែត្រូវបានលើកទឹកចិត្ត ដោយរក្សាទុកនូវទម្រង់របាយការណ៍ វិធីសាស្ត្រ ឬមធ្យោបាយ និងការចែករំលែកព័ត៌មានដូចគ្នា។
- ផែនការវាយតម្លៃគួរត្រូវបានបង្កើតឡើងដើម្បីចាត់ថ្នាក់ កំណត់អាទិភាព និងធ្វើអន្តរាគមន៍ពេលដែលត្រូវវាយតម្លៃ។
- ការវាយតម្លៃនីមួយៗគួរតែត្រូវបង្កើត និងរៀបចំផែនការ និងលក្ខខណ្ឌនៃឯកសារយោង។ ការវាយតម្លៃគួរតែត្រូវបានពន្យល់លម្អិត ដើម្បីកំណត់គោលបំណង និងវិសាលភាពនៃការវាយតម្លៃ ពិពណ៌នាអំពីវិធីសាស្ត្រ កំណត់ស្តង់ដារ ធនធាន និងពេលវេលាដែលត្រូវការដើម្បីបញ្ចប់ការវាយតម្លៃ។
- ព័ត៌មានដែលប្រមូលបានគួរតែអនុលោមតាមបទដ្ឋានបច្ចេកទេស ស្តង់ដានីតិវិធី វិធីសាស្ត្រគំរូ និងការបង្កើតកម្រងសំណួរមគ្គុទ្ទេសក៍សម្ភាសន៍ជាដើម។
- ផលប្រយោជន៍ដែលទទួលបាន គួរតែច្រើនជាងតម្លៃនៃការធ្វើការវាយតម្លៃ។

## លក្ខខណ្ឌចំបាច់ដើម្បីវាយតម្លៃ

**ភាពពាក់ព័ន្ធ** (Relevance) មើលសកម្មភាព ធាតុចេញ លទ្ធផល គោលបំណងនៃកម្មវិធី ការផ្លាស់ប្តូរ ដែលឆ្លើយតបទៅនឹងគោលបំណងជាតិ ឬអនុវិស័យតាមរយៈ

កម្រិតអន្តរាគមន៍ ទៅលើគោលនយោបាយ គោលដៅអាទិភាព បច្ចេកទេស និងដៃគូហិរញ្ញវត្ថុ។

**ការចុះសម្រុងគ្នា** (Coherence) វាស់វែងវិសាលភាពនៃអន្តរាគមន៍ផ្សេងទៀត (ជាពិសេសគោលនយោបាយ ឬកម្មវិធី) គាំទ្រ ឬធ្វើឱ្យអន្តរាយដល់កិច្ចអន្តរាគមន៍។ គ្រប់កម្រិតនៃភាគីពាក់ព័ន្ធត្រូវមានទំនាក់ទំនងល្អនឹងគ្នា ដើម្បីគាំទ្រដល់ការសម្រេចបាននូវលទ្ធផល។ ដើម្បីវាយតម្លៃការចុះសម្រុងគ្នា ត្រូវបង្កើតសំណួរដូចតទៅ៖

- តើការគាំទ្រផ្នែកបច្ចេកទេសទាំងក្នុង និងក្រៅដល់កម្រិតណា?
- តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ភាពស៊ីសង្វាក់គ្នានៃការគាំទ្របច្ចេកទេស?

**ប្រសិទ្ធផល** (Efficiency) ពិនិត្យថាតើការប្រើប្រាស់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុបានត្រឹមត្រូវ និងចំគោលដៅដើម្បីអនុវត្តសកម្មភាពឱ្យសម្រេចបាននូវធាតុចេញ ដោយសហការជាមួយតួអង្គពាក់ព័ន្ធដែរឬទេ។ ជាទូទៅការគណនាប្រសិទ្ធផលត្រូវការចំណុចប្រៀបធៀប (bench-marking) ជាមួយជម្រើសមធ្យោបាយសម្រាប់ផលិតផលដែលផ្តល់នូវធាតុចេញដូចគ្នា (ផលិតផល ឬសេវាកម្ម)។ ដើម្បីវាយតម្លៃប្រសិទ្ធផល ត្រូវចងក្រងបង្កើតសំណួរដូចតទៅ៖

- តើធាតុចូលត្រូវបានបំប្លែងទៅជាទិន្នផលកម្រិតណា?
- តើសកម្មភាពត្រូវបានអនុវត្តដោយចំណាយតិចបំផុតទេ?
- តើធាតុចូលត្រូវបានប្រើក្នុងវិធីមួយដើម្បីបង្កើនប្រសិទ្ធភាព ទិន្នផលឬទេ?
- តើបរិមាណនៃធាតុចូលអាចត្រូវបានកាត់បន្ថយដើម្បីផលិតបរិមាណទិន្នផលដូចគ្នាឬទេ?

**ប្រសិទ្ធភាព** (Effectiveness) វាស់វែងគោលបំណង (លទ្ធផល) និងទិន្នផល (ធាតុចេញ)។ ដើម្បីវាយតម្លៃលើប្រសិទ្ធភាព ត្រូវសួរសំណួរដូចតទៅ៖

- តើលទ្ធផលដែលបានដៅ បានសម្រេចកម្រិតណា?
- តើលទ្ធផលរំពឹងទុក នឹងសម្រេចដូចការព្យាករនៅចុងបញ្ចប់នៃគម្រោង ឬកម្មវិធីឬទេ?

- តើមានធាតុចេញណាខ្លះ (ផលិតផល ឬសេវាកម្ម) ដែលគួរកែលម្អ ដើម្បីសម្រេចលទ្ធផលជាគោលដៅ?
- តើការកាត់បន្ថយធាតុចេញអាចគំរាមកំហែងដល់លទ្ធផល គោលដៅ ឬទេ?

**និរន្តរភាព** (sustainability) ចង់ដឹងពីអត្ថប្រយោជន៍អន្តរាគមន៍ថាតើបន្ទាប់ពីចប់គម្រោងឬ គោលនយោបាយ ណាមួយហើយ នៅតែអាចបន្តអនុវត្តបានឬមិនបាន។ ហិរញ្ញវត្ថុ និងនិរន្តរភាពបរិស្ថានគួរតែពិនិត្យ ដើម្បីធ្វើឱ្យគម្រោង ឬ គោលនយោបាយផ្សេងៗមាននិរន្តរភាព។ សំណួរដែលគួរពិចារណាមានដូចតទៅនេះ៖

- តើក្រសួង ស្ថាប័នអាចរក្សាផលជះ វិជ្ជមានទាំងនេះដល់កម្រិតណា បន្ទាប់ពីបញ្ចប់គម្រោង ឬគោលនយោបាយ?
- តើកត្តាសំខាន់អ្វីខ្លះដែលជះឥទ្ធិពលដល់និរន្តរភាព បន្ទាប់ពីបញ្ចប់គម្រោង ឬគោលនយោបាយ?
- តើអន្តរាគមន៍មាននិរន្តរភាព និងសមស្របដែរឬទេ?

**ផលជះ** (Impact) ផលជះគឺសំដៅដល់ការផ្លាស់ប្តូរជាវិជ្ជមាន ឬ អវិជ្ជមាន ដែលបានមកពីអន្តរាគមន៍ដោយផ្ទាល់ ឬប្រយោល ដោយការតាំងចិត្ត ឬមិនតាំងចិត្ត។ ការវាយតម្លៃផលជះមានឈ្មោះដូចគ្នាជាច្រើន ដូចជា ការវាយតម្លៃចុងក្រោយ (quasi-experment, randomized experiments, and case study)។[26] ការវាយតម្លៃនេះធ្វើឡើងដោយអ្នកវាយតម្លៃពីខាងក្រៅ ដោយមានការចូលរួមពីក្រុមគម្រោង ឬកម្មវិធីដែរ (ប្រធាន/អនុប្រធាន/អ្នកតំណាង)។ ការវាយតម្លៃនេះត្រូវបានប្រើប្រាស់ជាផ្នែកមួយរបស់ប្រព័ន្ធតាមដាន និងកម្មវិធីប្រមូលទិន្នន័យរបស់ស្ថាប័នដូចនេះត្រូវតែមានការជ្រើសរើស និងតាក់តែងច្បាស់លាស់។ ការវាយតម្លៃនេះផ្តោតលើលទ្ធផល និងជួយអ្នកគ្រប់គ្រង ធ្វើការសម្រេចចិត្ត ថាតើត្រូវបន្ត ត្រូវកែលម្អ ត្រូវបញ្ចប់ និងចែករំលែកការទទួលខុសត្រូវតាមរបៀបណា។

---

[26](IDEA, Management of Evaluations of Development Policies Programs and Project, 2021)

មានវិធីសាស្ត្រពីរក្នុងការវាយតម្លៃផលជះគឺ វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ។ លទ្ធផលនេះ ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់រៀបចំផែនការថវិកា បង្កើតគោលនយោបាយ គ្រប់គ្រង និងចាត់ចែងសេវារបស់រដ្ឋាភិបាល និងពង្រឹងគណនេយ្យភាព។ គុណវិបត្តិនៃការវាយតម្លៃផលជះ គឺចំណាយពេល និងថវិកាច្រើន ជាពិសេសប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យតែម្តង។ ការវាយតម្លៃផលជះរកឃើញថាមានការពិបាកសម្រាប់អ្នកសម្រេចចិត្ត ដើម្បីផ្លាស់ប្តូរគោលនយោបាយ ឬផែនការព្រោះប្រើពេលយូរដើម្បីមើលឱ្យឃើញនូវលទ្ធផល។ ភ្នាក់ងាររបស់រដ្ឋាភិបាលជាច្រើនបានលើកឡើងថា ការវាយតម្លៃគឺជាការគំរាមកំហែង ឬជាការណ៍ដែលត្រូវការពេលវេលាច្រើនដើម្បីគ្រប់គ្រង ហើយមិនបានបង្កើតនូវលទ្ធផល (ការរកឃើញ) ដែលមានប្រយោជន៍។[27] ការវាយតម្លៃត្រូវមានផែនការ និងផែនការថវិកាច្បាស់លាស់ហើយអាទិភាពរយៈពេល ខ្លី មធ្យម និងវែង បើមិនដូច្នេះទេ មិនអាចជោគជ័យបានទេ។ យុទ្ធសាស្ត្រតម្រូវឱ្យបង្កើតការលើកទឹកចិត្ត ទណ្ឌកម្ម និងសារ ឬពាក្យពេចន៍វិជ្ជមានពីអ្នកសំខាន់ៗ និងត្រូវប្រឹងប្រែងអភិវឌ្ឍសមត្ថភាព និងវិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការស្ថាប័នជាជាងម្ចាស់ជំនួយ។ ដើម្បីវាយតម្លៃលើផលជះ យើងត្រូវពិនិត្យលើសំណួរ ភាពខ្លាំង និងការព្រួយបារម្ភ៖

**សំណួរ៖**

- តើមានផលជះអវិជ្ជមានឬទេ ? បើមាន តើផលជះទាំងនោះអាចកាត់បន្ថយបានឬទេ ?
- តើមានផលជះជាវិជ្ជមានទេ ? ប្រសិនបើមាន តើផលជះនោះអាចពង្រីកបានដែរឬទេ ?
- តើអន្តរាគមន៍បានបង្កើតភាពខុសគ្នាអ្វីខ្លះដល់អ្នកទទួលផល ?
- តើមានមនុស្សប៉ុន្មាននាក់ដែលរងផលប៉ះពាល់ ឬទទួលបានអត្ថប្រយោជន៍ពីផលប៉ះពាល់នេះ ?
- តើអន្តរាគមន៍បានចូលរួមចំណែកដល់ការសម្រេចបាននូវគោលបំណងរយៈពេលវែងដល់កម្រិតណា ?

---

[27] (Acevedo, Rivera, Lima, & Hwang, 2010)

- តើផលជះនេះត្រៀមខ្លួនហើយឬនៅក្នុងការប្រកួតប្រជែងផ្នែកនយោបាយ សង្គម សេដ្ឋកិច្ច និងស្ថាប័ន លើការកែលម្អនេះ?

**ភាពខ្លាំងនិងការព្រួយបារម្ភ**

ការវាយតម្លៃផលជះ៖ ភាពខ្លាំង(មានអ្វីខ្លះ) និង ការព្រួយបារម្ភ (មានអ្វីខ្លះ) បន្ទាប់ពីការបញ្ចប់គោលនយោបាយ គម្រោង ឬកម្មវិធី ការវាយតម្លៃផលជះត្រូវធ្វើតាមខ្លឹមសារបច្ចេកទេសដូចតទៅ៖

១. ប្រើប្រាស់វិធីសាស្ត្រមួយដែលអាចសម្រេចលទ្ធផលជាក់លាក់ណាមួយរបស់គម្រោង/កម្មវិធី ឬសកម្មភាព (បរិមាណវិស័យឬគុណវិស័យឬទាំងពីរ)

២. ប្រាប់ព័ត៌មានរបស់តម្លៃមូលដ្ឋាន និងចុងក្រោយនៃសូចនាករលទ្ធផល និងផលជះ

៣. ត្រូវធ្វើឡើងនូវតំណាងសំណាកគំរូនៃក្រុមទទួលផល និងក្រុមមិនទទួលផលនៃគម្រោង ប៉ុន្តែស្រដៀងគ្នាទៅនឹងក្រុមគោលដៅ

៤. បូកបញ្ចូលការវិភាគនៃលទ្ធផលគម្រោង ឬកម្មវិធីដែលមិនបានគិតទុក

៥.បូកបញ្ចូលការវិភាគនិរន្តរភាពនៃលទ្ធផលគម្រោង ឬកម្មវិធី ដោយរាប់បញ្ចូលផលជះសង្គម និងបរិស្ថាន

៦. បូកបញ្ចូលការវិភាគនៃផ្លូវបុព្វហេតុផ្សេងៗ

៧. រាប់បញ្ចូលអនុសាសន៍សម្រាប់សកម្មភាពនាពេលអនាគត។

**ការវាយតម្លៃផលជះ៖** ត្រូវវិនិយោគថវិកា អ្នកឯកទេសដែលមានជំនាញចាស់ទុំដែលធ្វើការលើការវាយតម្លៃ និងអន្តរាគមន៍ដែលប្រើពេលវេលាយូរដើម្បីសង្កេតកិច្ចការនេះ។




*រូបភាពទី២៖ លទ្ធផល និងការវាយតម្លៃផលជះ*

**សេដ្ឋកិច្ច៖** ប្រៀបធៀបរវាងធាតុចូលដែលផ្តល់ឱ្យដូចជា៖ សម្ភារៈ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ និងការប្រើប្រាស់ធនធានដែលជាក់ស្តែង។

**ប្រសិទ្ធភាពចំណាយ៖** លក្ខខណ្ឌនៃប្រសិទ្ធភាពចំណាយគឺដូចគ្នាទៅនឹងប្រសិទ្ធផល ដោយខុសគ្នាត្រង់ការវាស់លទ្ធផល (លទ្ធផល និងធាតុចេញ) ដោយទំនាក់ទំនងទៅនឹងធាតុចេញ។ គោលបំណងគឺ ដើម្បីចង់ដឹងថាតើគម្រោង កម្មវិធីប្រើប្រាស់ធនធានតិច និងសម្រេចបាននូវគោលបំណងឬលទ្ធផលដែលចង់បាន/ឬធំជាងការគិត។ ការចំណាយលើការវាយតម្លៃត្រូវតែតិច ប៉ុន្តែត្រូវទទួលបានលទ្ធផលច្រើន ទើបការវាយតម្លៃមានផលប្រយោជន៍។

**កំណត់ចំណាំ៖ ភាពផ្សេងគ្នារវាងប្រសិទ្ធភាព និងប្រសិទ្ធផល**

ប្រសិទ្ធភាពគឺដើម្បីសម្រេចគោលដៅតាមពេលវេលាគ្រោង ចំណែកឯប្រសិទ្ធផលត្រូវសម្រេចតាមគោលដៅ តាមពេលវេលាកំណត់ដោយចំណាយតិច និងចំគោលដៅ។

➢ **រូបមន្តក្នុងការគណនាប្រសិទ្ធភាព និងប្រសិទ្ធផល**

**១. ទិន្នន័យដែលត្រូវការដើម្បីគណនាប្រសិទ្ធភាព**

**តារាងទី៧៖** រូបមន្តគណនាប្រសិទ្ធភាព

| | សម្រេចបាន (Achieved) | តាមផែនការ (Planned) |
|---|---|---|
| ពេលវេលា (Time) | ពេលវេលាដែលសម្រេចបាន (Ta) | ពេលវេលាតាមផែនការ (Tp) |
| តម្លៃ (value) | តម្លៃដែលសម្រេចបាន (Va) | តម្លៃតាមផែនការ (Vp) |

Ta= Time achieved Tp= Time planed Va= Value achieved

Vp= Value planned

**រូបមន្ត៖ Effectiveness = (Va x Tp)/(Vp x Ta)**

**២.ទិន្នន័យដែលត្រូវការដើម្បីគណនាប្រសិទ្ធផល**

**តារាងទី៨៖** រូបមន្តគណនាប្រសិទ្ធផល

| | សម្រេចបាន (Achieved) | តាមផែនការ (Planned) |
|---|---|---|
| ពេលវេលា (Time) | ពេលវេលាដែលសម្រេចបាន (Ta) | ពេលវេលាតាមផែនការ (Tp) |
| តម្លៃគោលដៅ (Target) | តម្លៃដែលសម្រេចបានតាមគោលដៅ (Va) | តម្លៃតាមផែនការ (Vp) |
| តម្លៃ (Cost) | តម្លៃដែលសម្រេចបាន (Ca) | តម្លៃដែលធ្វើផែនការ (Cp) |

Ta= Time achieved Tp= Time planned Va= Value achieved

Vp= Value planned (target) Ca= Cost achieved Cp=Cost planned

**រូបមន្ត៖ Efficiency= (Va x Tp x Cp)/(Vp x Ta x Ca)**

ការបកស្រាយៈ

- ប្រសិទ្ធភាព/ប្រសិទ្ធផល=១ នោះគោលដៅនឹងសម្រេចតាមផែនការ។ គម្រោង (ឬផ្នែកណាមួយ) គឺមានប្រសិទ្ធភាពឬប្រសិទ្ធផល។
- ប្រសិទ្ធភាព/ប្រសិទ្ធផលស្មើ>១ នោះគោលដៅបានសម្រេចលើសពីអ្វីដែលបានគ្រោងទុក។
- ប្រសិទ្ធភាព/ប្រសិទ្ធផលស្មើ<១ នោះគោលដៅដែលសម្រេចបានគឺតូចជាងអ្វីដែលបានគ្រោងទុក។ គម្រោង/ផ្នែកណាមួយរបស់គម្រោងគឺមិនមានប្រសិទ្ធភាព ឬមានប្រសិទ្ធភាព។ ស្តង់ដា ឬគោលដៅដែលបានកំណត់ពីគម្រោង ឬសមាសភាគ នឹងត្រូវបានវិនិច្ឆ័យថាគ្មានប្រសិទ្ធភាព ឬប្រសិទ្ធផល។

### ៣.៣.២. ទំហំនៃការវាយតម្លៃ

គ្រប់ការវាយតម្លៃត្រូវគិតពីការកំណត់ទំហំ និងវិសាលភាពដែលត្រូវអនុវត្ត។ ការវាយតម្លៃអាចអនុវត្តគ្រប់កម្រិតដូចជាៈ គោលនយោបាយជាតិ ផែនការអភិវឌ្ឍជាតិ ផែនទីបង្ហាញផ្លូវ គោលនយោបាយ យុទ្ធសាស្ត្រ អនុវិស័យ កម្រិតកម្មវិធី កម្មវិធីតាមផ្នែក និងផ្នែកចម្រុះកម្រិតគម្រោង ឬបុគ្គលម្នាក់ៗ។ល។

- គម្រោងៈ អន្តរាគមន៍មួយនៅក្នុងមួយទីតាំង ឬគម្រោងតែមួយដែលបានអនុវត្តនៅក្នុងទីតាំងច្រើន។
- កម្មវិធីៈ អន្តរាគមន៍ដែលរួមបញ្ចូលសកម្មភាព ឬគម្រោងផ្សេងៗដែលមានគោលបំណងដើម្បីរួមចំណែកដល់គោលដៅរួម។
- គោលនយោបាយៈ ស្តង់ដា ការណែនាំ ឬច្បាប់បង្កើតឡើងដោយក្រសួង ស្ថាប័ន ដើម្បីគ្រប់គ្រង/ក្រឹត្យក្រមការសម្រេចចិត្តអភិវឌ្ឍ។
- ក្រសួង ឬស្ថាប័នៈ កម្មវិធីអន្តរាគមន៍ច្រើនផ្តល់ដោយអង្គភាពនានា។
- វិស័យៈ អន្តរាគមន៍លើផ្នែកគោលនយោបាយជាក់លាក់មួយដូចជាការអប់រំ កសិកម្ម សុខាភិបាល។

### ៣.៣.៣. បង្កើតកម្រងសំណួរដើម្បីវាយតម្លៃ

កម្រងសំណួរវាយតម្លៃ គឺជាធាតុដ៏សំខាន់ដែលផ្តល់ទិសដៅ និងបែបផែនសម្រាប់វាយតម្លៃ។ គ្រប់សំណួរទាំងអស់ត្រូវបង្កើតដោយប្រុងប្រយ័ត្នដោយដាក់ធាតុចូលគ្រប់គ្រាន់ និងគិតគ្រប់និយមន័យរបស់ពាក្យដើម្បីប្រមូលគ្រប់ព័ត៌មាន ឬទិន្នន័យដែលត្រូវការ និងត្រូវគិតអំពីសំណួរអាទិភាព។ បញ្ហាប្រឈមជារឿយៗក្នុងការបង្កើតសំណួរ គឺសន្មត់ថាអ្នករាល់គ្នាដែលចូលរួមក្នុងការបង្កើតសំណួរគឺយល់ដឹងពីគោលដៅអន្តរាគមន៍រួម។ ដើម្បីបង្កើតកម្រងសំណួរត្រូវពិនិត្យនូវចំណុចដូចខាងក្រោម៖

- **ចំណុចទី១៖** បង្កើតបញ្ជីសំណួរបឋមដោយយោងទៅតាមតក្កភាពអន្តរាគមន៍ គោលបំណងនៃការវាយតម្លៃ និងតម្រូវការរបស់តួអង្គពាក់ព័ន្ធដែលត្រូវវាយតម្លៃ ។
- **ចំណុចទី២៖** គិតថានរណានឹងវិភាគចម្លើយដែលនឹងទទួលបាន ហើយដោយមធ្យោបាយណា និងគិតពីពេលវេលា និងតម្លៃបន្ថែមរបស់ចម្លើយ។
- **ចំណុចទី៣៖** ត្រូវប្រាកដថាចម្លើយនឹងមានសុពលភាពនិងអាចជឿជាក់បានដោយផ្អែកលើវិធីសាស្ត្រ (និងថវិកា) ដែលមាន។
- **ចំណុចទី៤៖** ពិភាក្សាជម្រើសនៃសំណួរពេលដែលពន្យល់ពាក្យគន្លឹះ។ បង្កើតតារាងសំណួរវាយតម្លៃចុងក្រោយ។

**សំណួរចែកជាបីផ្នែក៖** ១. សំណួរពិពណ៌នា (Descriptive Questions) ២. សំណួរធម្មតា (Normative Questions) ៣. សំណួររកមូលហេតុ និងផលប៉ះពាល់ (Cause-and-Effect questions)

**តារាងទី៩៖** ការបង្កើតកម្រងសំណួរដើម្បីវាយតម្លៃ

| **សំណួរពិពណ៌នា** (Descriptive) | **សំណួរធម្មតា** (Normative) | **សំណួររកមូលហេតុ និងផលប៉ះពាល់** (Cause and Effect) |
|---|---|---|
| - តើតំណាងអ្វី? "តើជាអ្វី"<br>- ស្វែងយល់ឬ ពណ៌នាពីកម្មវិធី ឬដំណើរការឬឥរិយាបទទៅលើអ្វីមួយ<br>- ផ្តល់ចំណុចដៅនៃអ្វីមួយ<br>- តើជាសំណួរដោយផ្ទាល់ឬ (នរណា? អ្វី? កន្លែងណា? ពេលណា? មធ្យោបាយណា? ចំនួនប៉ុន្មាន?)<br>- អាចត្រូវបានប្រើប្រាស់ដើម្បីពណ៌នា៖ ធាតុចូល សកម្មភាព និងធាតុចេញ<br>- ជារឿយៗត្រូវបានស្វែងរកគំនិតពីអ្នកដែលទទួលផលប្រយោជន៍<br>-បើតាមការយល់ឃើញរបស់តួអង្គពាក់ព័ន្ធ តើគោល-បំណងនៃកម្មវិធីជាអ្វីខ្លះ?<br>- តើសកម្មភាពចម្បងរបស់កម្មវិធីគឺអ្វីខ្លះ?<br>- តើឧបសគ្គ/ភាពរាំងស្ទះអ្វីខ្លះដែលកម្មវិធីប្រឈម? | - ប្រៀបធៀប"តើជាអ្វី" ជាមួយនិង "តើគួរជាអ្វី"<br>- ប្រៀបធៀប ស្ថានភាពបច្ចុប្បន្ន ជាមួយនិងគោលដៅ ជាក់លាក់ គោលបំណង ឬចំណុចដៅមូលដ្ឋាន (Benchmark)<br>- តើយើងចំណាយច្រើនដូចដែលយើងគ្រោងថវិកាដែរឬទេ?<br>- តើការចំណាយមានប្រសិទ្ធភាពដែរឬទេ?<br>- តើការចំណាយឆ្លើយតបទៅនឹងលទ្ធផលដែរឬទេ? | -ស្វែងរកដើម្បីកំណត់ភាពខុសគ្នានៃអន្តរាគមន៍ដែលកើតឡើង<br>- សួរថាតើលទ្ធផលដែលចង់បានត្រូវបានសម្រេច និងថាតើវាជាអន្តរាគមន៍ដែលបង្កឱ្យមានលទ្ធផល<br>- បញ្ជាក់មុននិងក្រោយមាននិងមិនមានការប្រៀបធៀប<br>- ការវាយតម្លៃផលជះដែលផ្តោតលើសំណួរហេតុនិងផល |

## ៣.៣.៤. ការរៀបចំការវាយតម្លៃ

ត្រូវកំណត់គោលបំណង ក្រុមការងារវាយតម្លៃ បង្កើតតារាងម៉ាទ្រីសតក្កភាពសម្រាប់វាយតម្លៃ។ តាមបទពិសោធន៍នៃការអនុវត្តកន្លងមកគឺត្រូវបង្ហាញ និងពិភាក្សាពីការតាក់តែងជាមួយអ្នកដែលត្រូវធ្វើការវាយតម្លៃ និងតួអង្គពាក់ព័ន្ធផ្សេងៗមុនពេលបញ្ចប់ការរៀបចំវាយតម្លៃ។ ធ្វើដូច្នេះនឹងនាំឱ្យមានការគាំទ្រ និងប្រើប្រាស់សេវាវាយតម្លៃនេះ។

- សម្រេចលើការរៀបចំរបស់ក្រសួង ស្ថាប័ន មានដូចជា៖ គណៈកម្មាធិការវាយតម្លៃ អ្នកគ្រប់គ្រងការវាយតម្លៃ ក្រុមវាយតម្លៃ គណៈកម្មាធិការផ្តល់យោបល់ (ជម្រើស)
- សម្រេចលើកម្មវត្ថុ ប្រភេទនៃការវាយតម្លៃ និងការផ្តល់ការវាយតម្លៃ
- កំណត់អត្តសញ្ញាណតួអង្គពាក់ព័ន្ធ
- កំណត់ប្រតិទិនវាយតម្លៃ និងថវិកា

គោលបំណងនៃការរៀបចំតារាងម៉ាទ្រីសសម្រាប់វាយតម្លៃ គឺដើម្បីរៀបចំគោលបំណងនៃការវាយតម្លៃ និងសំណួរដើម្បីឱ្យស៊ីសង្វាក់គ្នាជាមួយនឹងអ្វីដែលនឹងធ្វើការវាយតម្លៃ និងវិធីសាស្ត្រប្រមូលទិន្នន័យដែលសមរម្យណាមួយ។ តារាងនោះមានធាតុដូចតទៅ៖

**តារាងទី១០៖** តារាងម៉ាទ្រីសសម្រាប់វាយតម្លៃ

| ល.រ | លក្ខខណ្ឌ | សំណួរ | សំណួរបន្ទាប់ | ប្រភេទសំណួរ (ពិពណ៌នាធម្មតា/ ប្រៀបធៀប និងហេតុ និងផល | ឧបករណ៍ប្រមូលទិន្នន័យ | |
|---|---|---|---|---|---|---|
| | | | | | បរិមាណ-វិស័យ | គុណ-វិស័យ |
| | | | | | | |
| | | | | | | |

## ៣.៣.៥ ដំណើរការនៃការវាយតម្លៃ

**តារាងទី១១៖** ដំណើរការនៃការវាយតម្លៃ

### ១. ទំហំនៃការវាយតម្លៃ

- ជួបអ្នកដែលត្រូវវាយតម្លៃ និងត្រូវស្គាល់និងជួបតួអង្គពាក់ព័ន្ធផ្សេងៗ
- ប្រមូលមូលដ្ឋានសម្ភារៈ និងស្វែងរកការវាយតម្លៃដែលទាក់ទង និងសម្គាល់បញ្ហា បង្កើតយុទ្ធសាស្ត្រប្រមូលទិន្នន័យដែលប្រើប្រាស់
- ពិនិត្យឡើងវិញ សម្រិតសម្រាំងនិងបង្កើតទ្រឹស្តីផ្លាស់ប្តូរ
- ពិនិត្យការវាយតម្លៃពីមុនឡើងវិញ

### ២. បង្កើត/តាក់តែង

- គិតពីសំណួរ និងបញ្ហា
- ស្គាល់ និងជួបតួអង្គពាក់ព័ន្ធនិងអ្នកដែលត្រូវវាយតម្លៃដើម្បីសម្គាល់បញ្ហា និងការបារម្ភសម្រាប់ការបូកសរុប ឬការវាយតម្លៃ
- គិតពីធនធានដែលមានសម្រាប់វាយតម្លៃដូចជា ថវិកា ទីប្រឹក្សាបច្ចេកទេស ក្រុម និងជំនាញក្រុម
- វាស់វែងតម្រូវការតួអង្គពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងពេលវេលា
- រៀបចំបំណែងចែកតួនាទីភារកិច្ចសម្រាប់ក្រុម

### ៣. ដឹកនាំការវាយតម្លៃ

- ព្រាងអ្នកដែលត្រូវវាយតម្លៃ និងតួអង្គពាក់ព័ន្ធសំខាន់ៗ ទៅលើការតាក់តែងវាយតម្លៃ
- រៀបចំផែនការការងារ ដោយបញ្ចូលការពិនិត្យ និងសាកល្បងវិធីសាស្ត្រ ឧបករណ៍ និងបង្រៀនពីការប្រមូលទិន្នន័យ និងបង្កើតប្រូតិកូល
- ប្រមូល វិភាគទិន្នន័យ បង្កើតក្រាហ្វិក និងបង្កើត/ពូនផ្តុំលទ្ធផល/ការរកឃើញ

### ៤. រាយការណ៍ពីការរកឃើញ

- កត់សម្គាល់លទ្ធផលដែលសំខាន់ និងបែបផែនថាតើដំណើរការឬមិនដំណើរការ តើមានអ្វីត្រូវកែលម្អដែរឬទេ?
- សរសេររបាយការណ៍
- ព្រាងប្រាប់អ្នកដែលត្រូវវាយតម្លៃនូវការរកឃើញដែលពិត
- ព្រាងប្រាប់អ្នកអនុវត្តកម្មវិធី និងតួអង្គសំខាន់ៗពីលទ្ធផល
- អនុញ្ញាតឱ្យអ្នកអនុវត្តកម្មវិធីពិនិត្យឡើងវិញ និងផ្តល់យោបល់លើរបាយការណ៍
- បង្កើតអនុសាសន៍(នរណាគួរធ្វើអ្វី និងនៅពេលណា?)
- ពិនិត្យអនុសាសន៍ ថាតើភ្ជាប់ជាមួយនឹងភស្តុតាងឬទេ?

## ផ្នែកទី៤៖ យន្តការ ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន.

ការបកប្រែគោលនយោបាយឱ្យទៅជាប្រព័ន្ធ ត.ត.វ. នៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ របស់ក្រសួង ឧ.វ.ប.ន. ចែកចេញជាបីផ្នែកដូចតទៅ៖ តក្កភាពអន្តរាគមន៍ ទ្រឹស្តីផ្លាស់ប្តូរ និងក្របខ័ណ្ឌតក្កភាព។

### ៣.៤.១. ក្របខ័ណ្ឌតក្កភាពនៃអន្តរាគមន៍




*រូបភាពទី៣៖ ក្របខ័ណ្ឌតក្កភាពនៃអន្តរាគមន៍*

### ៣.៤.២. ខ្សែច្រវាក់លទ្ធផល ឬទ្រឹស្តីផ្លាស់ប្តូរ

ខ្សែច្រវាក់លទ្ធផល (Results Chains) គឺមានប្រវត្តិពីការបង្កើតទម្រង់នៃបុព្វហេតុ ដែលបង្កើតឡើងដោយលោក **Suchman** ក្នុងឆ្នាំ១៩៦៧[28] ជាជម្រើសដើម្បីយល់អំពីគំរូក្របខ័ណ្ឌតក្កភាព ដែលមានទំនាក់ទំនងរវាងធាតុចូល ផលិតផល និងលទ្ធផល។ ក្រោយឡើងក៏បញ្ចូលការផ្លាស់ប្តូរដោយបញ្ចូលពាក្យសកម្មភាពដើម្បីបង្កើតធាតុចេញ (ផលិតផលនិងសេវាកម្ម)។ ក្រោយមកទៀតក៏បង្កើតលទ្ធផលតាមឆ្នាំ ឬពាក់កណ្តាលឆ្នាំមកជំនួសពាក្យផ្លាស់ប្តូរដើម្បីសម្រេចគោលដៅ និងផលជះដែលមានរយៈពេលវែង។ ខ្សែច្រវាក់លទ្ធផល (Results Chains) បង្ហាញពីទំនាក់ទំនងចាប់ពីការប្រើប្រាស់ធាតុចូល (inputs) ដូចជាធនធានមនុស្សដើម្បីបង្កើត និងដឹកនាំសកម្មភាពទាំងឡាយ (activities) នៅក្នុងស្ថាប័នដើម្បីគាំទ្រគម្រោង ឬគោលនយោបាយ ក្នុងន័យបង្កើតធាតុចេញ (outputs) ដើម្បីសម្រេចលទ្ធផល (outcomes) និងផលជះ (impact) ក្នុងរយៈពេលវែង។ ការបង្កើតខ្សែច្រវាក់លទ្ធផល ពិព័ណ៌នាពីរំហូរនៃសកម្មភាពទំនាក់ទំនងរវាងហេតុនិងផល ដែលកើតឡើងដោយសារតែអន្តរាគមន៍ ដើម្បីសម្រេចបាននូវផលជះ។ ខ្សែច្រវាក់លទ្ធផលនេះត្រូវបានបង្កើតឡើងក្នុងដំណាក់កាលវិភាគ និងផ្តល់ជាមូលដ្ឋានក្នុងដំណាក់កាលតាមដាន ត្រួតពិនិត្យ ឱ្យឆ្លើយតបទៅនឹងទស្សនវិស័យសម្រាប់ការផ្លាស់ប្តូរ ដែលសម្រេចលទ្ធផល។

---

[28] (IDEA, Result-Based Monitoring and Evaluation Framework Within a Results Based Management Approach , 2021)




*រូបភាពទី៤៖ ខ្សែប្រវាក់លទ្ធផល*

### ៣.៤.៣. ក្របខ័ណ្ឌតក្កភាព នៃយន្តការ ត.ត.វ. នៃ ការអនុវត្ត គោលនយោបាយ វ.ប.ន.

ដើម្បីធានា និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយ វ.ប.ន. ក្របខ័ណ្ឌតក្កភាពនៃយន្តការ ត.ត.វ. ត្រូវបានកសាងឡើងដោយផ្អែកលើគោលគំនិត ដែលនឹងត្រូវសម្រេចបានតាមលទ្ធផលចុងក្រោយ លទ្ធផលក្នុងឆ្នាំ ជាតុចូលរួម និងផែនការសកម្មភាពនានា ក្នុងការជំរុញការអនុវត្តគោលនយោបាយ វ.ប.ន.។




*រូបភាពទី៥៖ ក្របខ័ណ្ឌតក្កភាព នៃយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ*

### ៣.៤.៣.១. គោលបំណងទូទៅ

យោងទៅតាមគោលនយោបាយជាតិស្តីពី វ.ប.ន. គោលដៅចម្បងគឺជំរុញការអភិវឌ្ឍវិស័យ វ.ប.ន. ឱ្យមានភាពរីកចម្រើនប្រកបដោយប្រសិទ្ធភាព កសាងប្រព័ន្ធអេកូនវានុវត្តន៍ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឱ្យប្រសើរឡើងនៅគ្រប់កម្រិត និងវិស័យឈានទៅជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយបរិយាបន្នភាព និងចីរភាព ស្របតាមចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ក្របខ័ណ្ឌតក្កភាពនៃយន្តការ ត.ត.វ. រៀបចំឡើងដើម្បីធានាឱ្យសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ នេះ។

### ៣.៤.៣.២. លទ្ធផលចុងក្រោយ

គ.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. តម្រូវឱ្យមានលទ្ធផលចុងក្រោយរៀងរាល់ឆ្នាំ ដើម្បីជារង្វាស់សមិទ្ធកម្ម ចំពោះគោលការណ៍ខាងលើរបស់អង្គភាពអនុវត្ត។ ឧទាហរណ៍លទ្ធផលចុងក្រោយរបស់ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ ដូចខាងក្រោម៖

- ចំនួន ៥០% នៃនិស្សិតសាកលវិទ្យាល័យ នឹងសិក្សាលើមុខវិជ្ជាទាក់ទងទៅនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ដែលក្នុងចំណោមនិស្សិតទាំងនោះ មាន៤០% គឺជានិស្សិតភេទស្រី ។
- វិស័យឯកជននឹងចូលខ្លួនយ៉ាងសកម្មក្នុងការផ្តល់ថវិកាដែលមានចំនួនស្មើនឹងពាក់កណ្តាល (០.៥% នៃផ.ស.ស.) នៃការចំណាយសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងប្រទេស ។
- សកម្មភាពស្រាវជ្រាវលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅគ្រប់កម្រិត និងវិស័យ នឹងរីកចម្រើនទៅមុខប្រកបដោយគុណភាព ប្រសិទ្ធភាព និងផលិតភាព ដែលនឹងមានការចូលរួមពីសហគ្រាសឧស្សាហកម្មយ៉ាងសកម្ម។
- ការស្រាវជ្រាវនិងអភិវឌ្ឍន៍ (Research and Development) នៅត្រឹមឆ្នាំ ២០៣០ នឹងទទួលបានថវិកាចំនួន ១% នៃផលិតផលក្នុងស្រុកសរុបនៃប្រទេសកម្ពុជា ។

### ៣.៤.៣.៣. ធាតុចេញ ឬលទ្ធផលក្នុងឆ្នាំ

ដើម្បីសម្រេចបាននូវគោលដៅនៃគោលនយោបាយ វ.ប.ន. ការតាមដានត្រួតពិនិត្យរាល់លទ្ធផលតាមឆ្នាំនីមួយៗ គប្បីត្រូវបានធ្វើឡើងជាបន្តបន្ទាប់សម្រាប់តាមដានរាល់សកម្មភាពបាននិងកំពុងអនុវត្ត ដើម្បីធានាឱ្យបានថារាល់លទ្ធផលដែលសម្រេចបានកន្លងមក ស្របទៅតាមគោលដៅក៏ដូចជាលទ្ធផលចុងក្រោយ។ លទ្ធផលក្នុងឆ្នាំនេះ នឹងជួយរកឱ្យឃើញនូវការរីកចម្រើនរបស់ផែនការ និងសកម្មភាព។ លើសពីនេះទៅទៀត វានឹងអាចកំណត់បញ្ហាដែលជាដំណើរការមិនល្អ ហើយអាចដោះស្រាយបញ្ហា និងការប្រឈមក្នុងការអនុវត្តទាន់ពេលវេលា។ បន្ថែមពីនេះ វាក៏

ជួយកែសម្រួលការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដែលជាហេតុធ្វើឱ្យលទ្ធផលកាន់តែមានគុណភាព។ ឧទាហរណ៍លទ្ធផលក្នុងឆ្នាំរបស់ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០៖

- ○ បណ្ណាល័យវិទ្យាសាស្ត្រចំនួន ៣ ត្រូវបានបង្កើត និងបើកឱ្យដំណើរការប្រើប្រាស់សម្រាប់សាធារណជនក្នុងឆ្នាំ២០២៣
- ○ ចំនួនគ្រឹះស្ថានឧត្តមសិក្សាចំនួន ៧ ត្រូវបានបង្កើតផ្តោតលើការស្រាវជ្រាវជាចម្បង ឬមជ្ឈមណ្ឌលស្រាវជ្រាវឆ្នើមត្រឹមឆ្នាំ២០២៥
- ○ ចំនួនការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសចំនួន ៥ ត្រូវបានបង្កើត និងមានដំណើរការនៅក្នុងសាកលវិទ្យាល័យទូទាំងប្រទេសត្រឹមឆ្នាំ២០២៣។

### ៣.៤.៣.៤. សកម្មភាព

សកម្មភាពសំដៅដល់ការងារដែលបង្កើតឡើងដូចជាសកម្មភាពដែលមាននៅក្នុងផែនការទូទៅ ផែនការថវិកា ផែនការ ត.ត.វ. ដើម្បីជួយក្នុងការសម្រេចបាននូវធាតុចេញ (outputs) លទ្ធផល (outcomes) និងផលជះ (impacts)។ ឧទាហរណ៍សកម្មភាពរបស់ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០៖

- ○ បណ្តុះបណ្តាលមន្ត្រីក្រសួង ឧ.វ.ប.ន. លើការតាក់តែងគោលនយោបាយ វ.ប.ន. និងត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ វ.ប.ន.
- ○ ពង្រឹងស្ថាប័នប្រមូលទិន្នន័យ វ.ប.ន. ដើម្បីបង្កើតគោលនយោបាយ និងបង្កើតជាដៃគូជាមួយវិទ្យាស្ថានជាតិស្ថិតិ
- ○ បញ្ចូលមុខវិជ្ជាទាក់ទងនឹងវិទ្យាសាស្ត្រ ឌីជីថល និងសហគ្រិនភាពទៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សា និងមធ្យមសិក្សា
- ○ ផ្តល់កម្មសិក្សាដល់និស្សិតជំនាញស្នែមក្នុងវិស័យឧស្សាហកម្ម។

### ៣.៤.៣.៥ ធាតុចូល

ធាតុចូលសំដៅដល់រង្វាស់លើសម្ភារៈ ពេលវេលា ថវិកា ឬធនធានមនុស្សដែលគាំទ្រដំណើរការរបស់គោលនយោបាយ ឬផែនការសកម្មភាព ដែល

មាននាយកដ្ឋាន ត.ត.វ.គ. ជាតួអង្គតាមអង្កេតមើល ដើម្បីជានាការសម្រេចបានលទ្ធផលដូចបានគ្រោងទុក។ ជាតុចូលដែលសំខាន់ជាងគេ គឺធនធានមនុស្សដែលផ្តល់ជាគំនិត និងបញ្ញាស្មារតីក្នុងការអភិវឌ្ឍវិស័យ វ.ប.ន.។ ជាតុចូលដែលសំខាន់បន្ទាប់មកទៀតគឺធនធានហិរញ្ញវត្ថុដែលសម្រាប់យកទៅចំណាយប្រកបដោយប្រសិទ្ធភាពលើសកម្មភាពក្នុងផែនការរបស់គម្រោងនៃនាយកដ្ឋាន ត.ត.វ.គ. ។

### ៣.៤.៤. ទំនាក់ទំនងលទ្ធផល និងប្រព័ន្ធ ត.ត.វ.

តារាងខាងក្រោម ពណ៌នាអំពីទំនាក់ទំនងលទ្ធផលរបស់គម្រោង និងប្រព័ន្ធ ត.ត.វ. ។

**តារាងទី១២៖** ទំនាក់ទំនងលទ្ធផលរបស់គម្រោង និងប្រព័ន្ធ ត.ត.វ.

| | |
|---|---|
| ជាតុចេញ/លទ្ធផលក្នុងឆ្នាំ (Output) | ការតាមដាន ត្រួតពិនិត្យ |
| សកម្មភាព (Activity) | |
| ជាតុចូល (Input) | |
| ផលជះ (Impact) | ការវាយតម្លៃ |
| លទ្ធផលចុងក្រោយ (Outcome) | |

ការតាមដាន ត្រួតពិនិត្យ នឹងធ្វើឡើងក្នុងដំណាក់កាលជាតុចូល សកម្មភាពរបស់គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ឬគម្រោង និងលទ្ធផលចុងឆ្នាំប៉ុណ្ណោះ។ ការវាយតម្លៃនឹងធ្វើឡើងសម្រាប់ដំណាក់កាលលទ្ធផលចុងក្រោយ និងផលជះរបស់គម្រោង។

### ៣.៤.៥. ការជ្រើសរើសសូចនាករ

ការជ្រើសរើសសូចនាករសម្រាប់ប្រព័ន្ធទិន្នន័យ ត្រូវបានបង្កើតឡើងដើម្បីរៀបចំសូចនាករស្តង់ដារសម្រាប់សកម្មភាព និងលទ្ធផលរំពឹងទុកលើ វ.ប.ន.។ ប្រព័ន្ធទិន្នន័យនេះត្រូវបានរៀបចំឡើងសម្រាប់បច្ចុប្បន្នភាពជាប្រចាំឆ្នាំ។ សូចនាករដែលបានលើកឡើងជាសូចនាករដែលអាចប្រមូលផ្តុំគ្នាពីសកម្មភាព និងលទ្ធផល

រំពឹងទុកនៅក្នុង ត.ត.វ. នៃគោលនយោបាយដោយផ្អែកទៅលើគោលការណ៍ វ.ប.ន.។ តាមប្រភពជាច្រើនបានណែនាំឱ្យជ្រើសរើសសូចនាករតាមរបៀប SMART[29]។

### ៣.៤.៥.១. សូចនាករកម្រិតផលជះ

សំដៅដល់ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន បឋម មធ្យម និង រយៈពេលវែង ដែលបានបង្កើតឡើងដោយការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម-វប្បធម៌ ស្ថាប័ន បរិស្ថាន បច្ចេកវិទ្យា និងបញ្ហាផ្សេងៗដោយផ្ទាល់ ឬប្រយោល តាំងចិត្ត ឬមិនតាំងចិត្ត[30]។ ដើម្បីជានាការអនុវត្តគោលនយោបាយ និងបង្កើនប្រសិទ្ធភាពក្នុងការ ត.ត.វ. នៃគោលនយោបាយ វ.ប.ន. ដោយបានគ្រោងសកម្មភាពគោល និងសូចនាករ ដែលនឹងជាឧបករណ៍សម្រាប់ ត.ត.វ. លើការអនុវត្តផ្ទាល់របស់ស្ថាប័ន ក៏ដូចជាអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយឱ្យកាន់តែប្រសើរ។

### ៣.៤.៥.២. សូចនាករកម្រិតលទ្ធផលចុងក្រោយ (Outcome Indicator)

សូចនាករកម្រិតលទ្ធផលចុងក្រោយ សំដៅដល់លទ្ធផលតាមឆ្នាំដែលកើតឡើងពីធាតុចេញជាច្រើន ដែលមានឥទ្ធិពលលើអ្នកទទួលផលពីគម្រោង ផែនទីបង្ហាញផ្លូវ ឬគោលនយោបាយ វ.ប.ន.។ ដើម្បីកំណត់សូចនាករប្រភេទនេះត្រូវពិនិត្យលក្ខណៈដូចតទៅ៖

- កំណើនសេដ្ឋកិច្ចជាតិ ដែលមានភាពសមស្រប និងធន់ជាមួយនឹងវិបត្តិដែលកើតឡើងទៅតាមគោលនយោបាយនៃ វ.ប.ន.
- មានគោលនយោបាយ ដែលស្របទៅតាមគោលនយោបាយនៃ វ.ប.ន. ក្នុងការវាយតម្លៃលើស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

---

[29] SMART indicators are strongly recommded unsing in these sources: JICA, 2005, UNDP 2009, Department of Technical Cooperation, International Atomic Energy Agency, 2013, UNESCAP, 2017

[30] (Austrian Development Agency, 2009)

- ទទួលបានការបង្កើតនូវប្រព័ន្ធអេកូឡូស៊ីនវានុវត្តន៍ជាតិដែលជាប្រយោជន៍ដល់វិស័យនានា
- ក្របខ័ណ្ឌជាឯកសារសម្រាប់ចំណេះដឹង ឬក៏ការស្រាវជ្រាវបន្តក្នុង ត.ត.វ. នៃការអនុវត្តគោលនយោបាយបន្តលើស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយនិរន្តរភាព។

### ៣.៤.៥.៣. សូចនាករកម្រិតជាតុចេញ ឬលទ្ធផលក្នុងឆ្នាំ (Output Indicator)

សូចនាករកម្រិតជាតុចេញសំដៅដល់ផលិតផល ឬសេវាកម្ម ដែលបង្កើតចេញ ឬមានឥទ្ធិពលពីសកម្មភាពដែលកំណត់ក្នុងផែនការ ឬគោលនយោបាយណាមួយ [31] ។ ដើម្បីតាក់តែងសូចនាករកម្រិតនេះ ត្រូវពិនិត្យលក្ខណៈដូចខាងក្រោម៖

- លទ្ធផលជាក់ស្តែងនៃកំណើនលទ្ធភាពនៃការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា
- លទ្ធផលនៃកំណើនការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍បន្ថែមលើធនធានមនុស្ស
- កំណើន និងវំហូរចូលនៃបច្ចេកវិទ្យាអន្តរជាតិ។

### ៣.៤.៥.៤. សូចនាករកម្រិតសកម្មភាព (Activity Indicator)

សូចនាករកម្រិតសកម្មភាព សំដៅដល់ការកំណត់ពីសកម្មភាពទាំងឡាយដែលដឹកនាំអនុវត្តដោយគោលនយោបាយ វ.ប.ន. កម្មវិធីថវិកា និងជំនួយគម្រោងផ្នែក វ.ប.ន.។ ឧទាហរណ៍៖ ការកសាងសមត្ថភាពរបស់បុគ្គលនីមួយៗផ្នែក វ.ប.ន . ការកសាងសមត្ថភាពស្ថាប័ន វ.ប.ន. ការគាំទ្រការបង្កើត ឬអនុវត្តគោលនយោបាយ វ.ប.ន. ផ្សេងៗ។

---

[31] (OECD, 2002)

### ៣.៤.៥.៥. សូចនាករកម្រិតធាតុចូល (Input Indicator)

ក្នុងការកំណត់ធាតុចូលក្នុងយន្តការ ត.ត.វ. ការអនុវត្តគោលនយោបាយ វ.ប.ន. របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ គឺផ្អែកលើកម្រិតធាតុចូលដែលមានដូចជា៖

- ទិន្នន័យដែលធ្លាប់មានរួច ដើម្បីជាជំនួយក្នុង ត.ត.វ. នៃគោលនយោបាយ វ.ប.ន.
- ជំរុញ និងចូលរួមសហការដោយផ្អែកលើវិធីសាស្ត្រផ្សេងៗ ជាមួយស្ថាប័នពាក់ព័ន្ធ
- ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានមនុស្ស
- ហិរញ្ញវត្ថុដែលត្រូវប្រើប្រាស់ជាក់ស្តែង
- ឧបករណ៍ សម្ភារៈ និងមធ្យោបាយក្នុង ត.ត.វ.។

តារាងសូចនាករ និងទំនាក់ទំនងនេះដកស្រង់ចេញពីផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០។




*រូបភាពទី៦៖ សូចនាករនិងទំនាក់ទំនងសកម្មភាព*

**១.ផលជះ៖** ការបង្កើតកិច្ចសហការ និងបណ្តាញក្នុងចំណោមតួអង្គពាក់ព័ន្ធនៅក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ ចំនួនសហគ្រាសធុនតូច និងមធ្យមកើនឡើង និងចំនួនប៉ាតង់កើនឡើង។ល។

**២.លទ្ធផលចុងក្រោយ៖** ៥០% នៃការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសត្រូវបានបង្កើត និងមានដំណើរការនៅក្នុងសាកលវិទ្យាល័យទូទាំងប្រទេសត្រឹមឆ្នាំ២០៣០។

**៣.ធាតុចេញ ឬលទ្ធផលក្នុងឆ្នាំ៖** ចំនួនការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសត្រូវបានបង្កើត និងមានដំណើរការនៅក្នុងសាកលវិទ្យាល័យ។

**៤.សកម្មភាពទី១៖** សហការជាមួយក្រសួងដែលបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ដើម្បីបើកសិក្ខាសាលាផ្សព្វផ្សាយពីការបង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ សូចនាករ៖ ចំនួនសិក្ខាសាលាផ្សព្វផ្សាយពីការបង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសនៅតាមគ្រឹះស្ថានឧត្តមសិក្សាត្រូវបានរៀបចំ។

**សកម្មភាពទី២៖** សហការជាមួយក្រសួងបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ដើម្បីពិនិត្យស្ថានភាពរបស់ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ចំនួនបេសកកម្មដើម្បីពិនិត្យស្ថានភាពរបស់ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាស នៅតាមគ្រឹះស្ថានឧត្តមសិក្សាត្រូវបានអនុញ្ញាត។

**សកម្មភាពទី៣៖** ចុះតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពសាកល្បងរបស់ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាសនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ចំនួនបេសកកម្មដើម្បីចុះតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពសាកល្បងរបស់ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាស នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលត្រូវបានអនុញ្ញាត្ត។

**៥.ធាតុចូល៖** ចំនួនសិក្ខាកាមដែលបានចូលរួម ចំនួនថវិកាដែលប្រើប្រាស់ក្នុងមួយសិក្ខាសាលា ចំនួនគ្រូឧទ្ទេស។ល។

### ៣.៥.៦. ក្របខ័ណ្ឌលទ្ធផលដើម្បីពិនិត្យតាមដាន

នៅក្នុងក្របខ័ណ្ឌលទ្ធផលរួមមានសូចនាករ ដែលភ្ជាប់ជាមួយនិយមន័យ ឬការពន្យល់ត្រូវបានសង្ខេបបង្ហាញក្នុងតារាងសម្រាប់ ត.ត.វ. នៃការអនុវត្តគោលនយោបាយ/គម្រោងផ្សេងៗ។ ក្របខ័ណ្ឌនេះបង្ហាញអំពីស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធ បន្ទាត់មូលដ្ឋានដែលមានឆ្នាំគោល ជាមួយតម្លៃគោល និងចំណុចដៅចុងក្រោយដែលមានឆ្នាំដៅជាមួយចំណុចដៅ។ សូមពិនិត្យមើលឧទាហរណ៍ក្របខ័ណ្ឌលទ្ធផលផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០។

**តារាងទី១៣៖** ក្របខ័ណ្ឌលទ្ធផលផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០

| ល.រ. | សូចនាករ | និយមន័យ | ឯកតា | ស្ថាប័ន/ អង្គភាពពាក់ព័ន្ធ | បន្ទាត់មូលដ្ឋាន | | ចំណុចដៅចុងក្រោយ | |
|---|---|---|---|---|---|---|---|---|
| | | | | | ឆ្នាំគោល | តម្លៃដៅ | ឆ្នាំដៅ | ចំណុចដៅ |
| **សរសរស្តម្ភទី១៖** ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ | | | | | | | | |
| ១ | ចំនួនប្រជុំក្នុងការកំណត់ និង/ឬ អនុម័តទិសដៅ វ.ប.ន. ដោយ ក.ជ.វ.ប.ន. | ជាការប្រជុំសាមញ្ញ( ពីរដងក្នុងមួយឆ្នាំ ) និងកិច្ចប្រជុំវិសាមញ្ញតាមការកោះប្រជុំពីប្រធាន ក.ជ.វ.ប.ន. ដើម្បីកំណត់ និង/ឬ អនុម័តទិសដៅ វ.ប.ន. | ចំនួន | NCSTI, MISTI | ២០២១ | ២ | ២០៣០ | ២០ |
| ២ | ចំនួនគោលនយោបាយពាក់ព័ន្ធ វ.ប.ន. ដែលដឹកនាំ និង សម្របសម្រួលដោយ ក្រសួង ឧ.វ.ប.ន. | ឯកសារ ឬលិខិតូបករណ៍ទាំងឡាយណា ដែលពាក់ព័ន្ធនឹង វ.ប.ន. ស្ថិតក្រោមការដឹកនាំ និង សម្របសម្រួលដោយក្រសួង ឧ.វ.ប.ន. | ចំនួន | NCSTI MISTI | ២០២១ | ១ | ??? | ??? |

### ៣.៤.៧. ការបញ្ចូលទិន្នន័យ

#### ៣.៤.៧.១. ទម្រង់នៃការបញ្ចូលទិន្នន័យ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់យន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. នឹងបង្កើតឡើងសម្រាប់បញ្ចូលទិន្នន័យសកម្មភាពគោលសូចនាកររយៈពេលមធ្យម និងការអនុវត្តផ្ទាល់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលត្រូវមានការចាត់តាំងបុគ្គល ឬក្រុមការងារបង្គោលផ្ទៃក្នុងដើម្បីសម្របសម្រួលប្រមូល និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធឌីជីថលដោយបុគ្គល ឬក្រុមការងារនឹងមានគណនី និងលេខសម្ងាត់ដើម្បីចុះឈ្មោះក្នុងប្រព័ន្ធ និងមានសិទ្ធិបញ្ចូល ឬបន្ថែមទិន្នន័យទៅតាមស្ថាប័នរៀងៗខ្លួនដោយមានការកំណត់ព្រំដែនក្នុងការមានសិទ្ធិចូលទៅកែប្រែ ឬមើលទិន្នន័យពីស្ថាប័នផ្សេងៗ ។

ទិន្នន័យនឹងបង្ហាញក្នុងផ្ទាំងព័ត៌មានអន្តរសកម្ម ដែលអាចជួយប្រមូលផ្ទៀងផ្ទាត់ទិន្នន័យឱ្យស្របទៅតាមកម្មវត្ថុ និងបញ្ជាក់ឱ្យច្បាស់ពីស្ថាប័នពាក់ព័ន្ធឱ្យមានភាពងាយស្រួល និងសមស្របតាមពេលវេលា។ ហើយផ្ទាំងព័ត៌មានអន្តរសកម្មនឹងបង្កើតគំរូរបាយការណ៍របស់សូចនាករសំខាន់ៗក្នុងយន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.។ ផ្ទាំងបញ្ចូលទិន្នន័យ និងផ្ទាំងរាយការណ៍ នឹងបង្កើតដោយធ្វើការសិក្សាសំយោគសម្រាំងឱ្យបានហ្មត់ចត់ និងបានស្របតាមតម្រូវការរបស់យន្តការ ត.ត.វ.។

#### ៣.៤.៧.២. គុណភាពទិន្នន័យ

ស្ថាប័ន ឬអង្គភាពរាយការណ៍ នឹងត្រូវធានាឱ្យបានត្រឹមត្រូវនិងច្បាស់លាស់ពេញលេញនូវរាល់ព័ត៌មាន និងទិន្នន័យបានបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងយន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.។ ហើយក្រសួងស្ថាប័នដែលបង្កើត នឹងមានតួនាទីទទួលខុសត្រូវលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នឹងត្រូវ

ពិនិត្យទិន្នន័យនិងព័ត៌មានដែលបានបញ្ចូលក្នុងប្រព័ន្ធ ដោយផ្អែកលើគោលការណ៍ជានាគុណភាពទិន្នន័យចំនួន ៦ ជាបឋម រួមមានៈ

- ភាពត្រឹមត្រូវ និងសុពលភាព ដែលអាចវាស់វែងស្របនឹងគោលបំណងបាន
- ភាពជឿជាក់ដែលបានវាស់វែង និងប្រមូលក្នុងវិធីសាស្ត្រដូចគ្នា ជាមួយឧបករណ៍បច្ចេកទេស ឬមូលដ្ឋានវិទ្យាសាស្ត្រត្រឹមត្រូវ
- ភាពពេញលេញទាំងស្រុង ដែលមិនមានបាត់ទិន្នន័យណាមួយ
- ភាពច្បាស់លាស់ដែលមានព័ត៌មានលម្អិតគ្រប់គ្រាន់
- ភាពទាន់ពេលវេលា ដែលមានបច្ចុប្បន្នកម្មហើយត្រូវបានបញ្ជូនទាន់ពេលវេលា និងអាចប្រើប្រាស់បាននៅពេលត្រូវការ
- សុចរិតភាពដែលមិនត្រូវមានភាពលម្អៀង ឬកែសម្រួលដោយចេតនានោះទេ ។

### ៣.៤.៧.៣. ការកំណត់នៃការបញ្ចូលទិន្នន័យ

ស្ថាប័ន អង្គភាពរាយការណ៍ មានរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីការបញ្ចប់វដ្តនៃរបបរាយការណ៍នីមួយៗដើម្បីបញ្ចូលព័ត៌មាន និងទិន្នន័យទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

### ៣.៤.៧.៤. ការគ្រប់គ្រងទិន្នន័យ

ការគ្រប់គ្រងទិន្នន័យ ជាផ្នែកមួយយ៉ាងចម្បងក្នុងយន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន.។ ការគ្រប់គ្រងទិន្នន័យត្រូវគិត និងអនុវត្តដោយប្រុងប្រយ័ត្នហ្មត់ចត់ តាំងពីដំណាក់កាលប្រមូលទិន្នន័យដំបូងដោយស្ថាប័នអង្គភាពរាយការណ៍ ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការវិភាគ ការបកស្រាយពន្យល់ និងដំណាក់កាលបង្ហាញទិន្នន័យ។ ការគ្រប់គ្រងទិន្នន័យត្រូវតែសំខាន់សម្រាប់ផែនការអនុវត្តលើការរក្សាទុក ការរៀបចំ និងការរំលឹកទិន្នន័យ និងព័ត៌មានសម្រាប់គោលដៅគ្រប់គ្រងគម្រោង និងទិន្នន័យដែលប្រព្រឹត្តទៅដោយប្រសិទ្ធភាពខ្ពស់ និងត្រូវតែមានការលះបង់ និងការចំណាយពេលវេលា ការប្តេជ្ញា និងការគាំទ្រផ្នែកហិរញ្ញវត្ថុ។

ការគ្រប់គ្រងទិន្នន័យសម្រាប់យន្តការ ត.ត.វ. នៃការអនុវត្តគោលនយោបាយ វ.ប.ន. ត្រូវផ្គត់ផ្គង់ដោយប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលអាចជួយសម្រួលឱ្យក្រសួង ស្ថាប័នគ្រប់គ្រងគម្រោង គោលនយោបាយ ដោយប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ យ៉ាងងាយស្រួល។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវជានាគ្រប់គ្រងព័ត៌មានដែលទទួលបានពីក្រសួង ស្ថាប័នរាយការណ៍នីមួយៗ ក្នុងប្រព័ន្ធយន្តការ ត.ត.វ. ដោយមានលក្ខណៈទាន់ពេលវេលា និងប្រសិទ្ធភាពខ្ពស់ ។

**ការគ្រប់គ្រងទិន្នន័យដែលមានប្រសិទ្ធភាព ត្រូវមានលក្ខណៈដូចខាងក្រោម៖**

- ប្រមូល និងរក្សាទុកព័ត៌មានតាមនីតិវិធី និងសេចក្តីណែនាំដែលមានស្រាប់
- អភិវឌ្ឍ ឬបង្កើតសៀវភៅលេខកូដទិន្នន័យ ដែលមានភាពសមស្រប
- មានការបម្រុងទុក ដើម្បីការពារភាពយឺតយ៉ាវនៃការប្រមូលទិន្នន័យ
- ចែករំលែកទិន្នន័យសមស្របជារបាយការណ៍តាមរយៈសិក្ខាសាលា ដើម្បីទទួលមតិកែលម្អពីស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ។

## ៣.៤.៨. តួនាទី និងប្រព័ន្ធរាយការណ៍តាមអង្គភាពរាយការណ៍[32]

### ៣.៤.៨.១. តួនាទីអង្គភាពរាយការណ៍

អង្គភាពរាយការណ៍នៃស្ថាប័នជាតិ និងក្រោមជាតិមានតួនាទីដូចខាងក្រោម៖

- បញ្ជូនឈ្មោះរបស់សមាជិក ឬក្រុមការងារបង្គោលផ្ទៃក្នុង មកកាន់នាយកដ្ឋាន ត.ត.វ.គ. នៃអគ្គនាយកដ្ឋាន វ.ប.ន. ដើម្បីកត់ត្រា និងសម្របសម្រួល ក្នុងការតាមដាន ការវាយតម្លៃ តាមវដ្តនីមួយៗ ដែលបានកំណត់។

[32] ទម្រង់របាយការណ៍និងប្រភេទរបាយការណ៍គឺយកពីក្របខ័ណ្ឌ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ របស់អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

- បញ្ជូនឈ្មោះរបស់សមាជិក ឬក្រុមការងារបង្គោលផ្ទៃក្នុងត្រូវបញ្ចូលទិន្នន័យតាមអង្គភាពរាយការណ៍តាមប្រព័ន្ធដែលបានកំណត់តាមសូចនាករដែលមាន។
- អង្គភាពរាយការណ៍ត្រូវបញ្ចូលទិន្នន័យដែលមានចាប់ពីឆ្នាំ២០២០ បញ្ជាក់ពីការអនុវត្តគោលនយោបាយ វ.ប.ន. ដែលជាឆ្នាំគោលសម្រាប់ប្រៀបធៀបតាមពេលបន្តបន្ទាប់ ហើយសូមធ្វើការរាយការណ៍ផ្ទៃក្នុងសម្រាប់ឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងសម្រាប់ស្វ័យកែតម្រូវមុនពេលដល់វដ្តរាយការណ៍បានកំណត់។
- ក្នុងករណីអង្គភាពរាយការណ៍ពុំបានបញ្ចូលទិន្នន័យតាមវដ្តរាយការណ៍គឺតម្រូវឱ្យជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬអ៊ីម៉ែលផ្លូវការ មកកាន់នាយកដ្ឋាន ត.ត.វ.គ. នៃអគ្គនាយកដ្ឋាន វ.ប.ន.។
- ក្នុងករណីអង្គភាពរាយការណ៍ត្រូវកែព័ត៌មានដែលបានបញ្ចូលហើយត្រូវស្នើសុំជាលាយលក្ខណ៍អក្សរ ឬអ៊ីម៉ែលផ្លូវការ យ៉ាងយូរ១៤ ថ្ងៃប្រតិទិន ក្រោយពេលបញ្ចូលទិន្នន័យ។

#### ៣.៤.៨.២. ប្រភេទនៃរបាយការណ៍

របាយការណ៍គឺជាឯកសារមួយដែលបង្ហាញពីបណ្តុំនៃទិន្នន័យដែលបង្កើតជាព័ត៌មានក្នុងទម្រង់មួយ ដែលបានរៀបចំសម្រាប់អ្នកអានជាមួយគោលបំណងជាក់លាក់។ ទោះបីជាការសង្ខេបនៃរបាយការណ៍ទាំងឡាយប្រហែលជាត្រូវបានរាយការណ៍ផ្ទាល់មាត់ ប៉ុន្តែរបាយការណ៍ដែលសរសេរជាលាយលក្ខណ៍អក្សរចប់សព្វគ្រប់ ទើបយកជាផ្លូវការបាន។ ដើម្បីធ្វើការ ត.ត.វ. នៃគោលនយោបាយផែនទីបង្ហាញផ្លូវ និងគម្រោងនានាឱ្យមានប្រសិទ្ធភាព ប្រព័ន្ធនិងរំហូររបាយការណ៍ជាក់លាក់ដែលឆ្លុះបញ្ចាំងពីការពិតត្រូវតែមាន។ គេសង្កេតឃើញមានរបាយការណ៍ជាច្រើនដែលចេញពីប្រព័ន្ធ ត.ត.វ. ដែលមានគោលបំណងខុសៗគ្នា និងឆ្លើយសំណួរផ្សេងៗគ្នា ប៉ុន្តែគ្រប់របាយការណ៍ត្រូវតែមានសង្គតិភាព និងមានន័យខ្លឹមសារច្បាស់លាស់។ របាយការណ៍ទាំងនោះរួមមាន៖

### ៣.៤.៨.២.១. របាយការណ៍វឌ្ឍនភាពប្រចាំឆមាស

របាយការណ៍ប្រចាំឆមាស (៦ខែ) វាយតម្លៃពីការរីកចម្រើននៃគោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងនានា ដើម្បីដឹងពីការវិវឌ្ឍនៃដំណើរការ សកម្មភាព និងលទ្ធផល។ របាយការណ៍នេះមានទម្រង់ដូចតទៅៈ ១) សេចក្តីសង្ខេបវឌ្ឍនភាពសំខាន់ៗនៅក្នុងឆមាស ដោយបង្ហាញពីការរីកចម្រើននៃការសម្រេចសូចនាករគោលដៅនៅក្នុងឆមាសតាមការគ្រោងទុក និងឈានទៅរកការសម្រេចបាននូវក្រុមគោលដៅនៃសូចនាករផលសម្រេចប្រចាំឆ្នាំ ២)វិភាគលទ្ធផលដើម្បីឱ្យដឹងពីប្រសិទ្ធភាព ប្រសិទ្ធផល ផលិតផល គុណភាព និងគោលដៅ នៃផលិតផល និងសេវាកម្មដែលបានផ្តល់ដោយផែនការ/កម្មវិធី/គម្រោង ៣) បញ្ហាប្រឈមដោយផ្តោតលើគុណភាព និងការទទួលខុសត្រូវតាមកម្រិតរចនាសម្ព័ន្ធ និងសកម្មភាពជាដំណោះស្រាយ ៤)ទិន្នន័យក្នុងរបាយការណ៍ត្រូវមានសុក្រឹតភាព និងសង្គតិភាព ដោយរក្សាខ្លឹមសារនិងអត្ថន័យដើមនៃទិន្នន័យ ទោះបីទិន្នន័យទាំងនោះទទួលបានពីប្រភពផ្សេងគ្នាក៏ដោយ។ ចំណែកឯខ្លឹមសារនៃរបាយការណ៍មានលក្ខណៈដូចតទៅៈ ១)សំយោគសកម្មភាពសំខាន់ៗដែលបានអនុវត្តដើម្បរកឱ្យឃើញនូវឧបសគ្គ ចន្លោះប្រហោង និងវឌ្ឍនភាពក្នុងអំឡុងពេលរាយការណ៍ ២) លទ្ធផលដែលសម្រេចបានគ្រប់ផ្នែកនៃផែនការផ្សេងៗរួមមានៈ ប្រសិទ្ធភាពសម្រេចបានទាក់ទងនឹងផែនការការងារប្រចាំឆ្នាំ ផែនការថវិកា និងស្តង់ដារដែលបានជ្រើសរើស គោលដៅ ក្រាហ្វិក និងតារាងដែលចាំបាច់ដើម្បីបង្ហាញពីទំនោរ ៣) អនុសាសន៍ជាក់លាក់ និងទូទៅ និង ៤) ការបង្ហាញពីអន្តរាគមន៍។ របាយការណ៍នេះមានគោលបំណងដើម្បីពង្រឹង និងជំរុញប្រសិទ្ធភាព ផលិតផល និងការរីកចម្រើននៃការអនុវត្តគោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងនានាទៅតាមផែនការដែលបានគ្រោងទុក និងពង្រឹង និងជំរុញប្រសិទ្ធភាព ប្រសិទ្ធផល គណនេយ្យភាព តម្លាភាព នៃការគ្រប់គ្រងការអនុវត្តថវិកាក្នុងអំឡុងពេលអនុវត្តឱ្យសម្រេចគោលដៅរបស់អង្គភាពពាក់ព័ន្ធ។

### ៣.៤.៨.២.២. របាយការណ៍ប្រចាំឆ្នាំ

របាយការណ៍ប្រចាំឆ្នាំ ត្រូវពិនិត្យទៅលើលទ្ធផល ឬផលសម្រេច និងគោលនយោបាយ ឬគោលនយោបាយចម្រុះ។ របាយការណ៍មានទម្រង់និងខ្លឹមសារដូចតទៅៈ ១) សេចក្តីសង្ខេប/តារាងផលសម្រេចដែលឆ្លើយតបទៅនឹងលទ្ធផលក្នុងឆ្នាំដែលមាននៅក្នុងក្របខ័ណ្ឌលទ្ធផល ២) ស្ថានភាពនៃផលសម្រេចប្រចាំឆ្នាំដូចជា យុទ្ធសាស្ត្រ (ទ្រឹស្តីផ្លាស់ប្តូរច្បាស់លាស់ទាក់ទងនឹងស្ថាប័ន សមត្ថភាព និងហិរញ្ញវត្ថុ) ដំណើរការអនុវត្តការងារ (ប្រសិទ្ធភាព ប្រសិទ្ធផល និងការពេញចិត្ត) ការរៀនសូត្រ ៣) បញ្ហាប្រឈម ៤) ដំណោះស្រាយជាអនុសាសន៍ និង ៥) អាទិភាពសម្រាប់ឆ្នាំបន្ទាប់។

### ៣.៤.៨.២.៣. របាយការណ៍អនុវិស័យ (អគ្គនាយកដ្ឋាន/មន្ទីរពាក់ព័ន្ធ)

របាយការណ៍អនុវិស័យ មានគោលបំណងតាមដានវឌ្ឍនភាពនៃការអនុវត្តតាមអនុវិស័យដោយផ្តោតលើការប្រែប្រួលនៃបរិមាណ គុណភាព និងបញ្ហាប្រឈម។ របាយការណ៍អនុវិស័យបង្ហាញលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកលើក្របខ័ណ្ឌលទ្ធផលរបស់គោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងនានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ របាយការណ៍នេះពណ៌នាអំពីលទ្ធផលដែលសម្រេចបាន និងមិនបានសម្រេចនៃសកម្មភាពនៅក្នុងតារាងម៉ាទ្រីសលទ្ធផលអនុវិស័យ (អគ្គនាយកដ្ឋាន/មន្ទីរពាក់ព័ន្ធ) ធៀបជាមួយផែនការប្រតិបត្តិការប្រចាំឆ្នាំ ចំនួនសាច់ប្រាក់ ភាគរយនៃថវិកា និងការចំណាយថវិកា វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ បញ្ហាប្រឈម និងសកម្មភាពជាដំណោះស្រាយនិងអនុសាសន៍។

### ៣.៤.៨.២.៤. របាយការណ៍ពិនិត្យពាក់កណ្តាល និងចុងបញ្ចប់អាណត្តិ

គោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងនានារបស់ វ.ប.ន. នឹងត្រូវពិនិត្យពាក់កណ្តាលអាណត្តិ ដើម្បីវាយតម្លៃលទ្ធផលទាំងអស់នៃគោលនយោបាយ និងគោលនយោបាយចម្រុះ និងយុទ្ធសាស្ត្រគាំទ្រ។ របាយការណ៍ពិនិត្យពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ នឹងត្រូវរៀបចំទៅតាមគោលបំណងដូចតទៅៈ ពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងរយៈពេលពាក់កណ្តាលអាណត្តិទៅតាមភាពប្រែប្រួលជាក់ស្តែង និងពិនិត្យមើលវឌ្ឍនភាពនៃ

ផែនការហិរញ្ញប្បទាន កំណត់អាទិភាពកំណែទម្រង់ ធ្វើបច្ចុប្បន្នភាពគោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងនានា យុទ្ធសាស្ត្រគាំទ្រ សកម្មភាព សូចនាករ គោលដៅ និងផែនការហិរញ្ញប្បទានសម្រាប់ឆ្នាំបន្ទាប់ដើម្បីរៀបចំគោលនយោបាយ ផែនទីបង្ហាញផ្លូវ និងគម្រោងនានាសម្រាប់ដំណាក់កាលបន្ទាប់ក្នុងគោលបំណងបន្តអនុវត្តកំណែទម្រង់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

### ៣.៤.៨.២.៥. ក្របខ័ណ្ឌពេលវេលាសម្រាប់ការផ្តល់របាយការណ៍

**តារាងទី១៤៖** ក្របខ័ណ្ឌពេលវេលាសម្រាប់ការផ្តល់របាយការណ៍

| ល.រ. | ប្រភេទរបាយការណ៍ | ក្របខ័ណ្ឌពេលវេលាសម្រាប់ការផ្តល់របាយការណ៍ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ត្រីមាសទី១ | | | ត្រីមាសទី២ | | | ត្រីមាសទី៣ | | | ត្រីមាសទី៤ | | |
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | របាយការណ៍ប្រចាំខែ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | របាយការណ៍ប្រចាំត្រីមាស/ឆមាស | | | ✓ | | | ✓ | | | ✓ | | | ✓ |
| ៣ | របាយការណ៍ប្រចាំឆ្នាំ | | | | | | | | | | | | ✓ |
| ៤ | របាយការណ៍ពាក់កណ្តាលអាណត្តិ | ពាក់កណ្តាលអាណត្តិនៃគម្រោង/គោលនយោបាយ | | | | | | | | | | | |
| ៥ | របាយការណ៍គួអង្គពាក់ព័ន្ធ | | | | | | ✓ | | | | | | ✓ |
| ៦ | របាយការណ៍ថ្នាក់ក្រោមជាតិ/មន្ទីរ | | | ✓ | | | ✓ | | | ✓ | | | ✓ |

### ៣.៤.៨.៣. រំហូរនៃរបាយការណ៍




*រូបភាពទី៧៖ រំហូរនៃរបាយការណ៍*

**កំណត់សម្គាល់៖** មន្ទីរ នាយកដ្ឋានជំនាញ និងស្ថាប័ន/អង្គភាពពាក់ព័ន្ធ ត្រូវរៀបចំរបាយការណ៍ប្រចាំឆមាស ឬឆ្នាំ និងផ្ញើមកនាយកដ្ឋាន ត.ត.វ.គ. នៃអគ្គនាយកដ្ឋាន វ.ប.ន. នៃក្រសួង ឧ.វ.ប.ន. ។

### ៣.៤.៨.៤. ការវាយតម្លៃ និង ការផ្តល់អនុសាសន៍

ក្រោយពេលទទួលបានរបាយការណ៍តាមវដ្តរាយការណ៍ មន្ត្រីទទួលបន្ទុកតាមមុខការក្រសួង និងស្ថាប័នរាយការណ៍ ត្រូវពិនិត្យមើលរបាយការណ៍ដោយផ្ទៀងផ្ទាត់នូវសង្គតិភាពពីរបាយការណ៍ដែលបានធ្វើនៅវដ្តមុន និងគោលដៅដែលបានកំណត់ ហើយប្រសិនបើរកឃើញនូវចំណុចត្រូវការពន្យល់ ឬបញ្ជាក់បន្ថែមនោះ មន្ត្រីទទួលបន្ទុកត្រូវទាក់ទងទៅមន្ត្រីអង្គភាពរាយការណ៍ដើម្បីបកស្រាយពីរបាយការណ៍។ ប្រសិនបើអង្គភាពរាយការណ៍ពុំអាចធ្វើការកែតម្រូវ និងទាមទារឱ្យមានការផ្តល់យោបល់ នោះមន្ត្រីទទួលបន្ទុកក្នុងនាយកដ្ឋាន ត.ត.វ.គ. ត្រូវពិភាក្សាក្នុងនាយកដ្ឋាន ហើយត្រូវឆ្លើយតបជាមួយអនុសាសន៍ផ្សេងៗជាលាយលក្ខណ៍អក្សរ ឬតាមរយៈអ៊ីម៉ែលប្រសិនបើអាចធ្វើទៅបាន។

ចំពោះការវាយតម្លៃប្រចាំឆ្នាំ នាយកដ្ឋាន ត.ត.វ.គ. ត្រូវរៀបចំជាគណៈកម្មការវាយតម្លៃ ដោយប្រើប្រាស់នូវធនធានដែលមាននៅក្នុងអគ្គនាយកដ្ឋាន និងអាចមានការសម្របសម្រួលជាមួយអគ្គនាយកដ្ឋានផ្សេង ប្រសិនបើអង្គភាពរាយការណ៍នោះទាមទារឱ្យមានសមាសភាគច្រើនក្នុងការចុះវាយតម្លៃ។ ការវាយតម្លៃប្រចាំឆ្នាំត្រូវផ្អែកលើរបាយការណ៍ដែលបានទទួលតាមវដ្តរាយការណ៍នីមួយៗ និងផ្ទៀងផ្ទាត់ជាមួយសូចនាករដែលបានកំណត់។

នាយកដ្ឋាន ត.ត.វ.គ. ត្រូវធ្វើរបាយការណ៍សង្ខេប ដែលរាប់បញ្ចូលជាមួយការផ្តល់អនុសាសន៍មកកាន់អគ្គនាយកដ្ឋាន វ.ប.ន. ដើម្បីពិនិត្យ និងបញ្ជូនរបាយការណ៍រកឃើញមកកាន់អង្គភាពរាយការណ៍ជាលាយលក្ខណ៍អក្សរ មិនឱ្យលើសពីរយៈពេល៣០ថ្ងៃ។

## វដ្តនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ[33]




Resource: STED Results Base Management and M&E Manual, 2016

*រូបភាពទី៨៖ វដ្តនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ*

---

33 ( Sida, 2016 )

# ឯកសារយោង

ADAPTATION FUND BOARD OECD. (2011, May 21). *PROJECT LEVEL RESULTS FRAMEWORK AND.* https://www.oecd.org/env/cc/48332155.pdf

CHAB DAI. (2018). *Project Monitoring and Evaluation* . Phnom Penh: CHAB DAI.

Daniel A. Wagner, Bob Day, Tina James, Robert B. Kozma, Jonathan Miller, & Tim Unwin. (2005). *Monitoring and Evaluation ICT in Eduation Project.* Washington DC: The World Bank.

Gita Busjeet. (2013). *Planning, Monitoring and Evaluation: Methods and Tools for Poverty and Inequality Reduction Programs.* Washington, D.C.: World Bank . https://openknowledge.worldbank.org/handle/10986/16449: https://openknowledge.worldbank.org/handle/10986/16449

Gladys Lopez Acevedo, Katia Rivera, Lycia Lima, & Helena Hwang. (2010). *Challenges in Monitoring and Evaluation: An opportunity to Institutionalize M&E Systems.* Washington, D.C.: 2010.

Government of Nepal. (2013). *National Monitoring and Evaluation Guidelines* . Singha, Durbar, Kathmandu,: Government of Nepal National Planning Commission Secretariat.

IDEA. (2021). Evaluation Concepts and Process . *Master Certificate in Results-Based M&E and Information Systmes.* IDEA International .

IDEA. (2021). Management of Evaluations of Development Policies Programs and Project. *Masters Certificate in Results-Based M&E and Information Systems* . IDEA International .

IDEA. (2021). Result-Based Monitoring and Evaluation Framework Within a Results Based Management Approach . *Master Certificate in Results-Based M&E and Inforamtion Systems Certification 1.* IDEA International .

IDEA. (2021). This information is adopted from the source of How to Build a Monitoring and Evaluation System PowerPoint Presentation. . *Master Certificates in Results-Based M&E and Inforamtion Systems Certificate.* IDEA International .

M&E Unit Austrian Development Agency. (2009, July). *យកមកវិញពី* https://www.oecd.org/development/evaluation/dcdndep/47069197.pdf?_ga=2.212263252.1940568525.1657704111-1447009376.1657704111

Miall Marriott, & Hugh Goyder. (2009). *Manual for Monitoring and Evaluation Eduation Partnerships.* Paris : International Institute for Educational Planning, UNESCO .

MISTI. (2020). *Prakas on Department of Policy Formation .* Phnom Penh: MISTI.

MISTI. (2020). *Prakas on Formation of the Department of Policy Monitoring Inspection and Evaluation .* Phnom Penh: MISTI.

MISTI/GD_STI. (2021). *Cambodia's Science, Technology & Innovation Roadmap 2030.* Phnom Penh: MISTI/GD_STI.

MISTI_GD/STI_D/MIE. (2022). *សៀវភៅណែនាំពីការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០.* Phnom Penh: MISTI.

NCSTI. (2019). *National Policy on Science Technology and Innovation 2020-2030.* Phnom Penh: NCSTI.

Nigel Simister. (2019). *M&E SYSTEMS.* Intrac.

OECD. (2002). *យកមកវិញពី* https://www.oecd.org/gov/budgeting/1851320.pdf

OECD. (2002). *យកមកវិញពី* https://www.oecd.org/gov/budgeting/1851320.pdf

Ray C. Rist, & Jody Zall Kusek. (2004). *Ten Steps to a Results-Based Monitoring and Evaluation System .* Washington, DC: The World Bank.

Sida. (2016). *STED Results Base Managment and M&E Manual.* Turin: International Labour Organization .

UNCTAD. (2019). *A Framework for Science, Technology and Innovation Policy Reviews:Harnessing innovation for sustainable development.* Geneva : United Nation.

UNDP. (2002). *Handbook on Monitoring and Evaluating for Results .* New York: Evaluation Office .

UNESCAP. (2010). *ESCAP M&E SYSTEM: Monitoring & Evaluation System Overview and Evaluation Guidelines.* Bangkok: United Nationa publication.

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ISBN 978-9924-600-06-0